Decalssified to Public
06 September 2012



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber
Chambre de la Court Suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Mar-2011, 14:01
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចប្រជុំរៀបចំសវនាការបណ្តឹងសាទុក្ខ
# សម្ងាត់

**ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១**

**ម៉ោង ០៩:០២នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រ៊ឹម ជាប្រធាន

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម ម៉ូតូ ណូហ្គុជិ

*(Judge Motoo NOGUCHI)*

ចៅក្រម សោម សិរីវុឌ្ឍ

ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត

*(Judge Agnieszka KLONOWIECKA-MILART)*

ចៅក្រម យ៉ា ណារិន

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហ៍

*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មន្នីចរិយា (បម្រុង)

ចៅក្រម ផ្លរិន ម៉ុមបា (បម្រុង)

*(Judge Florence Mumba)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន

*(Mr. Christopher Mark Ryan)*

លោក ផន ធឿន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក ពេជ សម្បត្តិ

លោក សេង ប៊ុនឃាង

**មេធាវីការពារជនត្រូវចោទ កាំង ហ្គេកអ៊ាវ:**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា *(Ms. Elisabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក គាំ ច័ន្ទមុន្នី

កញ្ញា ស៊ូហ្សាន វ៉ូ *(Ms. Susan VO)*

លោក អ៊ុំច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម គង់ ស្រ៊ឹម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ូតូ ណូហ្គូជិ | អង់គ្លេស |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត | អង់គ្លេស |
| ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហ៍ | អង់គ្លេស |
| ចៅក្រម សោម សិរិវឌ្ឍ | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក អាន់ឌ្រូ ខេលី | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក កង ឫទ្ធារី | ខ្មែរ |
| លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា | បារាំង |
| លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី | អង់គ្លេស |
| លោក ផន ធឿន (ក្រឡាបញ្ជី) | ខ្មែរ |
| លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន (មន្ត្រីច្បាប់) | អង់គ្លេស |
| លោក គាំ ច័ន្ទមុន្នី (ប្រធានអង្គភាពបកប្រែ) | ខ្មែរ |
| កញ្ញា ស៊ូហ្សាន វ៉ូ | អង់គ្លេស |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោកស្រី ទី ស្រ៊ុនណា | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០២:៥០]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមចាប់ផ្តើមកិច្ចប្រជុំរបស់យើង។ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកត់សម្គាល់ឃើញថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានសហព្រះរាជអាជ្ញា ជនជាប់ចោទ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ក្រុមពីរ និងក្រុមបី បានធ្វើបណ្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អង្គជំនុំជម្រះតុលាការកំពូលបានកំណត់កាលបរិច្ឆេទសវនាការជំនុំជម្រះលើបណ្តឹងសាទុក្ខនេះចំនួនបីថ្ងៃ គឺចាប់ពីថ្ងៃទី២៨ ខែ-- ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ និងបម្រុងទុកមួយថ្ងៃ គឺនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១ សម្រាប់បន្តសវនាការ ប្រសិនបើការជំនុំជម្រះ ដែលគ្រោងនឹងធ្វើចំនួនបីថ្ងៃមិនអាចបញ្ចប់បាន។ ការកំណត់នេះ អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងដល់គ្រប់ភាគីរួចហើយ កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១១ មុននេះ។

[០៩:០៤:២៩]

យោងតាមវិធាន១០៤ស្ទួន និងវិធាន៧៩ នៃវិធានផ្ទៃក្នុង ក្នុងគោលបំណងសម្របសម្រួលដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីសវនាការប្រកបដោយយុត្តិធម៌និងឆាប់រហ័សនោះ អង្គជំនុំជម្រះតុលាការកំពូលប្រកាសបើកសវនាការ ប្រកាសបើកកិច្ចប្រជុំក្នុងរយៈពេលមួយថ្ងៃនៃថ្ងៃនេះ និងអនុញ្ញាតឲ្យមានការផ្លាស់ប្តូរមតិយោបល់គ្នារវាងសហព្រះរាជអាជអាជ្ញា និងមេធាវីដែលបានចូលរួមក្នុងពេលនេះ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទសវនាការ និងពិនិត្យជាមុននូវបញ្ហានានាដែលអាចនឹងកើតឡើងក្នុងពេលសវនាការ ដូចដែលឧបសម្ព័ន្ធរបស់អង្គជម្រះតុលាការកំពូលបានជូនកាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១១។

សមាសភាពរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលនៅក្នុងថ្ងៃនេះ គឺរួមមាន ខ្ញុំឈ្មោះ គង់ ស្រ៊ីម ជាប្រធាននៃអង្គជំនុំជម្រះតុលាការកំពូល។ ទីពីរ លោកចៅក្រម ម៉ូតូ ណូហ្គូជិ។ ទីបី លោកចៅក្រម សោម សិរីវឌ្ឍ។ ទីបួន លោកចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត។ ប្រាំ លោកចៅក្រម ស៊ិន រិទ្ធ។ ប្រាំមួយ លោកចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញ្ញហ៍។ ប្រាំពីរ លោកចៅក្រម យ៉ា ណារិន។

និងចៅក្រមបម្រុង មានលោកចៅក្រម ម៉ុង មុន្នីចរិយា និង លោកស្រីចៅក្រម ផ្លូរិនស៍ ម៉ុមបា។

ក្នុងពេលនេះដែរ គឺក្រឡាបញ្ជី គឺមានលោក ស៊ា ម៉ៅ, លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន, និងលោក ផន ធឿន។

បន្តទៅនេះ គឺមានភាគីចូលរួមនៅក្នុងពេលអង្គប្រជុំនេះ។

សូមអញ្ជើញលោកក្រឡាបញ្ជីធ្វើសេចក្តីរាយការណ៍អំពីសមាសភាពដែលចូលរួមនៅក្នុងពេលនេះ។ សូមអញ្ជើញ!

**លោក ផន ធឿន៖**

សូមជម្រាបលោកប្រធាន, ភាគីដែលចូលរួមមាន ខាងសហព្រះរាជអាជ្ញា លោកស្រី ជា លាង មីស្ទ័រ អាន់ឌ្រូ ខេលី, មីស្ទ័រ សេង ប៊ុនឃាង សហព្រះរាជអាជ្ញារង, លោក ពេជ សម្បត្តិ ជំនួយការជាន់ខ្ពស់, លោក កូលីន ហ្គែល មន្ត្រីច្បាប់រង និងលោក ផាន់ សុជា ជាក្រឡាបញ្ជី។

ក្រុមមេធាវីគាំពាការពារក្តី លោក ការ សាវុត្ថ មេធាវី, លោក កង ឫទ្ធារី មេធាវី, លោក អ៊ឹម វិបុល *លីហ្គល ខនសាលថិន* , លោក ចាន់ រ៉ាវុធ ជាអ្នកគ្រប់គ្រងសំណុំរឿង។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានលោកស្រី ទី ស្រ៊ីនណា តំណាងដើមបណ្តឹងប្បវេណីក្រុម១, លោក ខារីម ខាន (អវត្តមាន), លោកស្រី ស៊ីលឃី ស្ទួតស៊ីនស្គី តំណាងដើមបណ្តឹងប្បវេណីក្រុម២, លោក ហុង គីមសួន តំណាងដើមបណ្តឹងប្បវេណីក្រុម២ និង លោកស្រី អេលីហ្សាប៊េត សាន់ជ្រាតាណា តំណាងដើមបណ្តឹងប្បវេណីក្រុម៣, លោកស្រី ម៉ុច សុវណ្ណារី តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣។

ផ្នែកគ្រប់គ្រងតុលាការមាន ប្រតិចារឹក លោកស្រី លី សុផល និងលោកមន្ត្រីច្បាប់តុលាការ លោក អ៊ុច អរុណ។ សូមអរគុណ។

[០៩:០៨:៥៩]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបជូនអង្គប្រជុំថា នៅថ្ងៃនេះ គឺយើងមានរបៀបវារៈដែលហ្នឹងលើកមកពិភាក្សាហើយ ប្រហែលជាអស់លោក លោកស្រីគឺមាននៅក្នុងដៃស្រាប់ហើយ។ គឺមួយ អំពីសុន្ទរកថារបស់ប្រធានកិច្ចប្រជុំ ដែលខ្ញុំធ្វើអំម្បាញ់មិញនេះ។ ទីពីរ តារាងកាលវិភាគ សម្រាប់សវនាការបណ្តឹងសាទុក្ខ។ ទីបីគឺ ទម្រង់បែបបទសវនាការបណ្តឹងសាទុក្ខនៅក្នុងនោះគឺមានចំណុច(ក) គឺបទបញ្ជាផ្ទៃក្នុង។ ចំណុច

(ខ) ការកំណត់ពេលវេលា។ (គ) កន្លែងអង្គុយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ (ឃ) បទបង្ហាញរបស់អាយ.ធី.យូ។

[០៩:០៩:៥០]

បទបង្ហាញទីបួន គឺសំណើសុំដាក់ភស្តុតាងបន្ថែម។ ចំណុច(ក) គឺជនជាប់ចោទ។ ចំណុច(ខ) គឺដើមបណ្តឹងរដ្ឋប្បវេណី។ ទីប្រាំ គឺបញ្ហាផ្សេងៗ។ ចំណុច(ក) គឺសំណើសុំដកវិធានការការពារឯកសារលេខ F23 ។ ចំណុច(ខ) សំណួររបស់ចៅក្រម។

អ៊ីចឹងរបៀបវារៈហ្នឹង គឺមានចំនួនប្រាំចំណុចធំៗនេះ។ អ៊ីចឹងចូលដល់របៀបវារៈទីពីរ គឺសូមធ្វើការពិភាក្សាគ្នាអំពីកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខ ដែលខាងតុលាការកំពូលយើងបានជូនដល់ អស់លោក លោកស្រី នៅពេលមុននេះ។ អ៊ីចឹងសូមអញ្ជើញពិនិត្យ ហើយនិងសូមអញ្ជើញធ្វើការពិភាក្សា។

[០៩:១១:៤១]

**លោក អាន់ត្រូ ខេលី៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រី ជាទីគោរព, ដោយសារយើងទាំងអស់គ្នាហាក់ដូចជាអៀនខ្មាសក្នុងការនិយាយលើកដំបូងក្នុងការពិភាក្សាថ្ងៃនេះ ខ្ញុំសូមលើកឡើងនៅថ្ងៃនេះ។

ចំពោះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ នេះ ដែលវគ្គទីពីរយើងឃើញថា ចាប់ផ្តើមម៉ោងប្រាំបួនលើបញ្ហាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សហព្រះរាជអាជ្ញា និងសហសេវិករបស់ខ្ញុំបានធ្វើការបែងចែកទៅលើកម្មវត្ថុដែលយើងនឹងលើឡើងនៅថ្ងៃនោះ។ ខ្ញុំនិងនិយាយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅថ្ងៃនោះ។

[០៩:១២:២៧]

ប្រសិនបើអស់លោក លោកស្រីពិនិត្យមើលដីកាកំណត់កាលបរិច្ឆេទសវនាការ លោកចៅក្រមបានទទួលស្គាល់នៅក្នុងកថាខណ្ឌទី៣ថា លោកស្នើសុំឲ្យសហមេធាវី និងសហព្រះរាជអាជ្ញាធ្វើការផ្តល់យោបល់ទៅលើចំណុចចំនួនបីពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

ខ្ញុំមិនធ្វើការសម លើកឡើងទៅលើចំណុចនេះទេ ប៉ុន្តែវាមានចែងច្បាស់នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការ។ ហើយប្រសិនបើអស់លោក លោកស្រីពិនិត្យទៅលើកាលវិភាគកំណត់រយៈពេលនោះសហព្រះរាជអាជ្ញាទទួលបាន៣០នាទីក្នុងការធ្វើសេចក្តីសន្និដ្ឋាន។ ហើយខ្ញុំស្នើសុំ ថាឲ្យបន្ថែមរយៈ

ពេល១៥នាទីបន្ថែមទៀតទៅលើសាមសិបនាទីឲ្យយើងខ្ញុំធ្វើសេចក្តីសន្និដ្ឋាន។

[០៩:១៣:៣០]

នៅក្នុងនេះគឺយើងខ្ញុំត្រូវបានស្នើសុំឲ្យធ្វើការផ្តោតទៅសំណួរមួយចំនួន ដែលអង្គជំនុំជម្រះចង់ឲ្យយើងលើកឡើងដោយយើងមិនចាំបាច់ផ្តោតសំខាន់ទៅលើសេចក្តីសន្និដ្ឋាននោះទេ។ ហើយយើងដឹងថាមានចំណុចមួយចំនួនចង់ឲ្យយើងខ្ញុំឆ្លើយតបទៅលើចំណុចទាំងអស់នោះ។ ដូច្នេះ ខ្ញុំស្នើសុំរយៈពេល១៥នាទីបន្ថែមទៀតទៅរយៈពេលសាមសិបនាទី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ខ្ញុំអំមិញស្តាប់មិនច្រទ្បំទេ គឺលោកសហព្រះរាជអាជ្ញាអន្តរជាតិ គឺសុំស្នើឲ្យបន្ថែមសារណារបស់លោកនោះ គឺនៅថ្ងៃទី២៩ ហើយសំណើហ្នឹងគឺសុំបន្ថែម១៥នាទី បន្ថែមទៀត ហើយសម្រាប់តែថ្ងៃមួយហ្នឹងទេ ឬក៏ថ្ងៃផ្សេងទៀតដែរ? ប្រហែលជាខ្ញុំស្តាប់មិនទាន់ ប្រហែលជាតែថ្ងៃ-- ពេលហ្នឹងមួយទេតាមមើលទៅ ចាប់ពីម៉ោងប្រាំបួនដប់នាទីទៅម៉ោងប្រាំបួនសែសិប ហើយនិងសុំថែម១៥នាទី។ អ៊ីចឹងបើសិនជា-- មានតែប៉ុណ្ណឹងទេគឺចាំពិនិត្យទៅសំណើទាំងអស់ ហើយយើងខ្ញុំនឹងជូនដំណឹងនៅពេលក្រោយ។

[០៩:១៥:០៩]

**លោក អាន់ត្រូ ខេលី៖**

ខ្ញុំគោរពតាមការសម្រេចរបស់លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រី។

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ែនស្គី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំតំណាងក្រុមពីរនៃដើមបណ្តឹងរដ្ឋប្បវេណី យើងសង្កេតឃើញថា នៅថ្ងៃទីបី គឺថ្ងៃទីបី ខែ-- ថ្ងៃទី៣០ ខែ មីនា ឆ្នាំ ២០១១ ដែលពេលដែលពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលនោះក្រុមទាំងបី គឺបីក្រុម មានរយៈពេល ៤០នាទី ធ្វើសេចក្តីសន្និដ្ឋាន លើកឡើងអំពីបណ្តឹងសាទុក្ខរបស់យើងខ្ញុំ។

យើងកត់សម្គាល់ឃើញថា ក្រុមទីមួយបានលើកឡើងលើបណ្តឹងសាទុក្ខប្រឆាំងទៅនឹងភាពអាចទទួលយកបាន សេចក្តីសម្រេចទៅលើភាពអាចទទួលយកបាននៃឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

ក្រុមទីពីរបានលើកឡើងផងដែរ ទាក់ទងទៅនឹងបណ្ដឹងសាទុក្ខប្ដឹងលើសំណង។ ហេតុដូច្នេះ យើងខ្ញុំសូមលើកឡើងថា យើងខ្ញុំសូមថ្លែងអំណរគុណ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលអាចផ្ដល់ឲ្យយើងខ្ញុំនូវរយៈពេល១៥នាទី បន្ថែមទៀត ដើម្បីឲ្យយើងខ្ញុំអាចធ្វើសេចក្ដីសន្និដ្ឋានលើកឡើងទៅលើបណ្ដឹងសាទុក្ខរបស់យើងទាំងពីរបាន។

[០៩:១៦:៥៩]

ហើយខ្ញុំគិតថា ប្រៀបធៀបទៅនឹងរយៈពេលដែលផ្ដល់ជូនទៅលើក្រុមទីមួយ ដែលគេលើកឡើងពាក់ព័ន្ធទៅនឹងបណ្ដឹងសាទុក្ខតែមួយប៉ុណ្ណោះ ហើយលើកឡើងទាក់ទងទៅនឹងកម្មវត្ថុនៃបណ្ដឹងតែមួយ។ ដូច្នេះហើយ វាជាមូលដ្ឋានគួរតែផ្ដល់ឲ្យខ្ញុំរយៈពេល១៥នាទីបន្ថែម ដើម្បីឲ្យយើងខ្ញុំអាចធ្វើសន្និដ្ឋានទៅលើបណ្ដឹងសាទុក្ខរបស់យើងខ្ញុំបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកមេធាវី ការ សាវុត្ថបាទ។

**លោក ការ សាវុត្ថ៖**

សូមគោរពឯកឧត្ដមប្រធាន, ចំពោះខ្ញុំជាមេធាវីការពារជនជាប់ចោទ ក្នុងរយៈពេលនៃបណ្ដឹងសាទុក្ខ ហើយត្រូវបានតុលាការកំពូលបានរៀបចំនេះ គឺថាឲ្យខ្ញុំបាទជាមេធាវីការពារហ្នឹងរយៈពេល៩០នាទី សម្រាប់និយាយអំពីយុត្តាធិការ។

[០៩:១៨:០១]

ខ្ញុំបាទសូមអនុញ្ញាតបន្ថែមថា សូមឲ្យតុលាការកំពូលមេត្តាបន្ថែមពេល៩០នាទីថែមទៀត យ៉ាងហោចក៏៦០ ទៅ ៩០ នាទីថែមទៀត សម្រាប់ឲ្យយើងខ្ញុំនិយាយអំពីយុត្តាធិការបុគ្គលនេះ ហើយនេះជាចំណុចទីមួយដែលខ្ញុំបាទសំណូមពរ។ ព្រោះថា ការនិយាយទៅ វាមិនមែនបានរ៉ាវទៅតែម្ដងទេ កាលណាខ្ញុំនិយាយញាប់ ដូចជានៅសាលាដំបូងអ៊ីចឹង ខាងអ្នកបកប្រែគេស្រែកមកថា ឲ្យយឺតៗ។ សូមឈប់សិន និយាយម្ដងទៀត។ ដូច្នេះហើយ ទាមទារឲ្យមេធាវីនិយាយយឺត។ ដូច្នេះ ការដែលនិយាយយឺតវាអស់ពេលច្រើន ដូច្នេះខ្ញុំសូមឲ្យលោក-- ឯកឧត្ដមប្រធានមេត្តាពិនិត្យកន្លែងហ្នឹង។ គឺសំណូមពរសុំពី៦០ ទៅ ៩០ នាទីបន្ថែមទៀត។ នេះជាចំណុចទីមួយ។

[០៩:១៨:៥២]

ចំណុចទីពីរ ដែលខ្ញុំសូមនិយាយនោះ គឺសូមឲ្យតុលាការកំពូលសម្រេចរឿងអង្គសេចក្ដី ដោយ

ចេញ-- កំពូល សម្រេចរឿងអង្គសេចក្តីហ្នឹងដោយចេញសាលដីកាតែម្តង។ ចំពោះយុត្តាធិការបុគ្គល។ គឺថាសូមឲ្យចេញហ្នឹងសិន គឺថាកាលណាមេធាវីជជែកដេញដោលគ្នាចប់អស់ហើយ ទាំងអស់សវនាការទាំងមូល ខ្ញុំសំណូមពរឲ្យតុលាការកំពូលចេញសាលដីកាមួយសម្រេច ថាតើកូនក្តីខ្ញុំនោះ វានៅក្នុងយុត្តាធិការហ្នឹងឬក៏អត់? ឲ្យសម្រេចអ៊ីចឹងមួយសិន។ ពីព្រោះហេតុអីបានជាខ្ញុំសំណូមពរឲ្យសម្រេចពីរឿងអង្គសេចក្តីនេះសិន ដោយថា ខ្ញុំជាមេធាវីការពារនេះ ខ្ញុំបានប្តឹងសាទុក្ខពីយុត្តាធិការបុគ្គល ខ្ញុំអត់បានប្តឹងសាទុក្ខពីយុត្តាធិការលើបទល្មើសទេ។ ដូច្នេះហើយ បើសិនជាតុលាការកំពូលរកទៅឃើញថា កូនក្តីខ្ញុំនៅក្រៅយុត្តាធិការបុគ្គល ដូច្នេះវាចប់ហើយ។ វាមិនបាច់ទៅជជែកគ្នាពីយុត្តាធិការលើបទល្មើសទៀតទេ។ នេះជាសំណូមពររបស់ខ្ញុំ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២០:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រីមេធាវី។

**លោកស្រី អេលីហ្សាប៊េត រ៉ាបេសាន់ដ្រាតាណា៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីទាំងអស់គ្នា។ ខ្ញុំតំណាងឲ្យក្រុមបីៗ គឺថាបានឆ្លើយតបទៅនឹងសំណួរ គឺថាបានដាក់សារណាស្តីអំពីយុត្តាធិការ គឺយុត្តាធិការលើបុគ្គល។ ហើយគឺថា គេបានឲ្យ នៅថ្ងៃទីមួយ គឺចន្ទ ថ្ងៃទី២៨ មីនា គេបានផ្តល់ពេលវេលាឲ្យយើង ៣០ នាទី ដើម្បីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ខាងមេធាវីការពារក្តី។ ហើយនៅថ្ងៃនេះខ្ញុំបានឮថា ខាងមេធាវីការពារក្តីស្នើសុំបន្ថែមនូវរយៈពេល៦០នាទីបន្ថែមទៀតទៅលើបញ្ហាយុត្តាធិការនេះ គឺជាបញ្ហាបន្ទាន់បង្ខំដែលមានសារៈសំខាន់។ ដូច្នេះ យើងខ្ញុំជាមេធាវីនេះក៏ស្នើសុំពេលវេលាបន្ថែមសមាមាត្រដូចគ្នាដែរ ដើម្បីឲ្យយើងទាំងអស់គ្នាអាចបំពេញបន្ថែមនូវសេចក្តីសន្និដ្ឋានរបស់យើងទៅលើបញ្ហាយុត្តាធិការបុគ្គល។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រីសហព្រះរាជអាជ្ញា ជា លាង។

**លោកស្រី ជា លាង៖**

សូមគោរពអង្គប្រជុំទាំងមូល។ ដូចដែល អាន់គ្រូ បានលើកឡើងហើយគឺសហព្រះរាជអាជ្ញាមានការឆ្លើយតបទៅតាមចំណុចមួយៗផ្សេងៗគ្នា។ ដូច្នេះ ខ្ញុំមានការចាប់អារម្មណ៍ទៅលើកាលវិភាគ

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ដែលនៅពេលរសៀលហ្នឹងគឺឲ្យសហព្រះរាជអាជ្ញាធ្វើការឆ្លើយតបទៅនឹងមេធាវីការពារក្តីចំនួន៦០នាទី។ ទីមួយគឺយើងទទួលយកនូវចំនួននាទីនេះ ដោយឯកភាព ប៉ុន្តែអាស្រ័យទៅលើនឹងរបៀបវារៈនៅចំណុចទីបួន។

[០៩:២២:៤៦]

ចំណុចទីបួនហ្នឹងគឺសំណើសុំដាក់ភស្តុតាងបន្ថែម។ សំណើដាក់ភ័ស្តុតាងបន្ថែមនេះវាមានឯកសារច្រើន ដែលមានការច្របូកច្របល់គ្នាបន្តិចចំពោះខ្ញុំ ហើយខ្ញុំសង្កេតឃើញមានឯកសារខ្លះដូចគាត់មានដាក់ហើយ ហើយនិងមានដាក់ទៀត ហើយដូច្នេះយើងគិតថា អាហ្នឹងបើសិនជាអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា នេះជាភស្តុតាងថ្មីនោះ សហព្រះរាជអាជ្ញានឹងសុំបន្ថែមពេលវេលា សុំបន្ថែមពេលវេលាក្នុងករណីដែលតុលាការកំពូលទទួលស្គាល់ឯកសារ ជាឯកសារភស្តុតាងថ្មី។

ប៉ុន្តែផ្ទុយទៅវិញ យើងនឹងពិភាក្សាគ្នានូវកាលវិភាគពេលក្រោយ។ តើភស្តុតាងដែលដាក់នោះតើជាភស្តុតាងថ្មីដែរឬអត់។ បើក្នុងករណីអត់មានភស្តុតាងថ្មីមិនទទួលស្គាល់ទេ ខ្ញុំសូមរក្សាម៉ោងហ្នឹងដដែលក្នុងការឆ្លើយតប។ នេះខ្ញុំសូមរក្សាសិទ្ធិក្នុងការកែប្រែនៅក្រោយពីសេចក្តីសម្រេចរបស់តុលាការកំពូលហ្នឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អំមិញគឺលោកចៅក្រមមីឡាត ចង់បានយោបល់។ សូមអញ្ជើញ!

[០៩:២៤:១៤]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

អរុណសួស្តីអស់លោក លោកស្រី។ ខ្ញុំមានសំណួរមួយសួរទៅកាន់គ្រប់ភាគីទាំងអស់។

ទីមួយ ពាក់ព័ន្ធទៅនឹងសំណើសុំរយៈពេលបន្ថែមពីសហព្រះរាជអាជ្ញាលើកឡើង ហើយចំពោះសេចក្តីសន្និដ្ឋាន ដែលចង់លើកឡើងពាក់ព័ន្ធទៅនឹងវិសាលភាពនៃបណ្តឹងសាទុក្ខរបស់គាត់នោះ គឺដូច្នេះសហព្រះរាជអាជ្ញាគឺបានស្នើសុំរយៈពេលបន្ថែម១៥នាទី។ ដូច្នេះ ខ្ញុំចង់សួរទៅកាន់ក្រុមមេធាវីការពារក្តីថាតើមេធាវីការពារក្តីមិនធ្វើការតវ៉ាលើកឡើងទៅចំណុចសំខាន់ៗលើអង្គសេចក្តីពាក់ព័ន្ធទៅនឹងឧក្រិដ្ឋ-កម្មប្រឆាំងមនុស្សជាតិដែរឬទេ? ហើយនៅពេលដែលមានការស្នើសុំបន្ថែមដូច្នេះ ថាតើក្រុមមេធាវីការពារក្តីហ្នឹងយល់យ៉ាងម៉េចដែរ ពាក់ព័ន្ធទៅនឹងការបង្ហាញនៅព្រឹកនេះ?

[០៩:២៥:១៧]

សំណួរទីពីរ ខ្ញុំសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។ ប្រហែល ខ្ញុំសូមសួរនៅពេលនេះតែម្តង ហើយបន្ទាប់មកការឆ្លើយហ្នឹង គឺសម្រេចក្រោយពីលោកប្រធានធ្វើការសម្រេចថាឲ្យឆ្លើយ ឲ្យខាងណាឆ្លើយមុន។

ខ្ញុំនៅពេលនេះឆ្ងល់ថា ដោយសារតែក្រុមទីមួយ ភាគច្រើននោះលើកឡើងអំពីភាពអាចទទួលយកបាននៃបណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះហើយសេចក្តីសន្និដ្ឋានរបស់ក្រុមទីពីរនេះវាពាក់ព័ន្ធទៅនឹងការទទួលស្គាល់ទៅលើសាលក្រម ហើយយើងឃើញថាទម្រង់នៃសំណងដទៃទៀតហាក់ដូចជាមិនមានការប្តឹងតវ៉ាទេ។ ហើយថាតើមានការឯកភាពនៅក្នុងចំណោមក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេពាក់ព័ន្ធទៅនឹងរយៈពេលដែលពួកគេចង់លើកឡើងលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់មកទៅលើសំណង។

ដូច្នេះហើយ ថាតើមានការពិភាក្សាគ្នាទទៅលើការបែងចែកនៅក្នុងក្រុមដែរឬទេ? ហើយយើងចង់ដឹងអំពីការឯកភាពគ្នានោះ។ យើងដឹងហើយថា ពេលខ្លះទៅអាចក្រុមទីមួយអាចលើកឡើងអំពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ហើយក្រុមដទៃទៀតគឺឯកភាពដូចគ្នា។ ដូច្នេះហើយក្រុមទីពីរនិងទីបីគេធ្វើការផ្តល់ពេលវេលាលើសេចក្តីសន្និដ្ឋានទាក់ទងទៅនឹងសំណងតែម្តង។

[០៩:២៦:៤៨]

ដូច្នេះហើយ យើងជាចៅក្រមអង្គជំនុំជម្រះតុលាការកំពូលបានគិតគូរទៅលើបញ្ហាហ្នឹងចង់-- ខ្ញុំលើកឡើងបញ្ហាហ្នឹងចង់ឲ្យលោក លោកស្រីពិចារណាមើលផង។

**ប្រធានអង្គជំនុំៈ**

បាទសូមអញ្ជើញលោកមេធាវី។

**លោក កង ឫទ្ធារីៈ**

បាទ, ជាបឋមសូមគោរពឯកឧត្តមប្រធានតុលាការកំពូលនិងអស់លោក លោកស្រីចៅក្រមព្រមទាំងសហព្រះរាជអាជ្ញា ព្រមទាំងអស់លោក លោកស្រីទាំងអស់ដែលមានវត្តមានក្នុងទីនេះ។ ខ្ញុំជាមេធាវីការពារឲ្យជនជាប់ចោទ កាំង ហ្គេកអ៊ាវ (ស៊ុក) ហៅឌុច។ ដោយឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម គឺថា ការពិភាក្សាគ្នាអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះគួរតែធ្វើការពិភាក្សាល្អិតល្អន់ណាតែ១ តុលាការកំពូលចេញសេចក្តីសម្រេចអំពីយុត្តាធិការលើបុគ្គលនេះសិន។ ប្រសិនបើយើងរកទៅមិនឃើញថាមានយុត្តាធិការលើបុគ្គលទេ តើមានហេតុផលអីដែលត្រូវយកទៅធ្វើការពិភាក្សាគ្នា

លើឧក្រិដ្ឋកម្ម លើយុត្តាធិការលើបទល្មើស គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[០៩:២៧:៤៨]

ក៏ប៉ុន្តែ ខ្ញុំក៏មិនរួញរានឹងធ្វើការថ្លែងតបទៅនឹងសហព្រះរាជអាជ្ញា ឬក៏សំណូមពររបស់តុលាការកំពូលអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ក្នុងករណីដែលតុលាការកំពូលចេញសេចក្តីសម្រេចជាសាលដីកាអស់អាជ្ញាជំនុំអំពីយុត្តាធិការលើឋានៈបុគ្គល។ បើសិនជារកឃើញថា សាលាជម្រះក្តីនេះមានយុត្តាធិការលើបុគ្គល កាំង ហ្គេកអ៊ាវ (ស៊ីក) ហៅ ឌុច នោះ នោះយុត្តាធិការលើបទល្មើសនឹងត្រូវពិភាក្សាហើយ។ ហើយខ្ញុំក៏ប្រហែលត្រូវការពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងការធ្វើសេចក្តីថ្លែងការណ៍ចោទប្រកាន់របស់សហព្រះរាជអាជ្ញាអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ។

បាទ សូមអរគុណ។

[០៩:២៨:៣៥]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកមេធាវី ពាក់ព័ន្ធទៅនឹងចំណុចនេះ ដោយសារតែខ្ញុំទទួលបានការលើកឡើងទៅលើចំណុចនេះ វាមិនបញ្ជាក់ទៅលើចំណុចហ្នឹងឲ្យលម្អិតទេ ដូច្នេះហើយទើបយើងបានកំណត់កាលវិភាគបីថ្ងៃសម្រាប់សវនាការរបស់យើង។ ខ្ញុំដឹងថា ក្រុមមេធាវីការពារក្តីនោះ ក៏ចង់តវ៉ាពាក់ព័ន្ធទៅនឹងរឿងក្តីនោះផងដែរ។ ប៉ុន្តែ ខ្ញុំគិតឃើញថាភាគីមិនរំពឹងថា សេចក្តីសម្រេចសាលដីការហ្នឹងទៅលើបញ្ហាហ្នឹង នឹងចេញទៅតាមការចង់បានរបស់ខ្លួននោះឡើយ។

[០៩:២៩:២៣]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមបញ្ជាក់ជូនបន្តិចដែរ គឺយើងខ្ញុំចៅក្រមតុលាការកំពូលទាំងអស់នឹងធ្វើការពិភាក្សាអំពីបញ្ហានេះ បន្ទាប់ពីមានការស្តាប់យោបល់របស់អស់លោកទាំងអស់។ ប៉ុន្តែ ខ្ញុំគិតថាយើងក៏បានរៀបចំជាកាលវិភាគនៃសវនាការរួចហើយដែរ។ ហើយនៅក្នុងហ្នឹងគឺយើងខ្ញុំមានបំណងមួយគ្រាន់តែថា ការសវនាការធ្វើឡើងក្នុងរយៈពេលបីថ្ងៃនេះ គឺធ្វើសរុបរួមតែម្តង។ គឺធ្វើដោយចែកជាផ្នែកៗ ផ្នែកយុត្តា-ធិការមុនគេ គឺយើងត្រូវធ្វើមុនគេ។ ដល់អ៊ីចឹងហើយបានយើងចែកចេញជាមួយថ្ងៃហ្នឹង គឺសម្រាប់ទាក់ទងនឹងបញ្ហាយុត្តាធិការ។ ហើយបន្ទាប់មកទៀត គឺទាក់ទងនឹងបញ្ហាឧក្រិដ្ឋកម្ម។ ហើយបញ្ហាមួយទៀត គឺទាក់ទងនឹងបញ្ហាការកំណត់ទោស ហើយនិងទាក់ទងនឹងបញ្ហាដើមបណ្តឹងរដ្ឋប្បវេណី។ យើង

ធ្វើជារួមគ្នាតែម្តង ក្នុងរយៈពេលបីថ្ងៃនេះ។

[០៩:៣០:៣០]

បន្ទាប់មក បានជាយើងធ្វើការសម្រេចចេញសាលដីកាតែម្តង មិនមានគោលបំណងណាមួយ ដែលសម្រេចអំពីយុត្តាធិការមុនហើយ ហើយយើងសម្រេចជាករណីផ្សេងៗទៀតបន្តបន្ទាប់ គឺយើងអត់មានបំណងធ្វើអ៊ីចឹងទេ គឺទៅតាមកាលវិភាគដែលយើងរៀបចំឡើងនេះ។

អ៊ីចឹងហើយបានថា ខាងមេធាវីការពារក្តីដែលលោកលើកឡើងអំមិញនេះ គឺយើងខ្ញុំនឹងពិភាក្សា ហើយ ប៉ុន្តែយើងខ្ញុំគ្រាន់តែពិនិត្យទៅឃើញថា គួរតែលោកធ្វើការរៀបចំ ទាក់ទងបញ្ហាយុត្តាធិការ ខ្ញុំជឿថាលោកបានធ្វើរួចហើយ។ ប៉ុន្តែ ទាក់ទងនឹងបញ្ហាឧក្រិដ្ឋកម្មដែលខាងសហព្រះរាជអាជ្ញាប្តឹងនោះ គឺលោកគួរតែធ្វើដែរ គឺមិនចាំរង់ចាំដល់ថា តុលាការកំពូលសម្រេចចេញសាលដីលើយុត្តាធិការហើយ បានលោករៀបចំនោះទេ គឺខ្ញុំសង្ឃឹមថា លោកនឹងរៀបចំធ្វើ ហើយស្របពេលនោះ គឺយើងធ្វើទាំងអស់តែម្តង។ នេះគឺជាគំនិតយោបល់របស់ខ្ញុំទេ ហើយចាំបញ្ហានេះ គឺយើងនឹងយកទៅពិភាក្សាទៀត។ ហើយលោកមានយោបល់សូមអញ្ជើញលោក។

[០៩:៣១:៣៧]

**លោក កង ឫទ្ធារី៖**

បាទ, អរគុណចំពោះឯកឧត្តមប្រធានតុលាការកំពូលដែលលោកបានផ្តល់នូវ-- ដូចថាគ្រោងនៅផ្លូវ ផែនទីបង្ហាញផ្លូវមុនស្រេចក្នុងការរៀបចំសវនាការនៅថ្ងៃ៨ មីនា នៅពេលខាងមុខនេះ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសុំទទូចម្តងហើយម្តងទៀត សុំឲ្យពិនិត្យមើលនីតិវិធី ដែលទទួលស្គាល់ជាអន្តរជាតិ ដែលនីតិវិធីដែលត្រឹមត្រូវ។ កាលណាយើងធ្វើការជំនុំជម្រះរួមអ៊ីចឹងវាចំណេញពេលវេលា។ ក៏ប៉ុន្តែ វាមានន័យតាមពិតន័យវារំលោភលើសិទ្ធិបុគ្គល វាហាក់បីដូចជាយើងផ្តល់សច្ចធារណ៍ថា ឌុច មានទោសរួចទៅហើយ ហើយចាប់បង្ខំឲ្យមេធាវីការពារជនជាប់ចោទ ឆ្លើយទៅនឹងយុត្តាធិការរបស់សហព្រះរាជអាជ្ញាតែម្តង។

[០៩:៣២:២៦]

ខ្ញុំគ្រាន់តែសុំឲ្យធ្វើយ៉ាងឲ្យវេទិកានៃការជម្រះក្តីនៅទីនេះ មានតម្លាភាព ហើយអាចទទួលយកបានទាំងជាតិនិងអន្តរជាតិ។ ពីព្រោះថាការធ្វើបង្រួមពេលវេលាខ្លីពេក វាចំណេញពេល យើងទាំងអស់ជាការពិត ហើយខ្ញុំក៏បានត្រៀមរួមហើយ សម្រាប់ការឆ្លើយតបទៅនឹងអ្វីដែលតុលាការកំពូលបានដាក់

ជូនមក ទាំងឧក្រិដ្ឋកម្ម យុត្តាធិការលើបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាំងទោសទណ្ឌដែលត្រូវពិភាក្សាគ្នា។ ប៉ុន្តែ ដូចអស់លោកជ្រាបស្រាប់ហើយ តាមចំណេះដឹងនិងបទពិសោធន៍អស់លោកចៅក្រមនិងសហព្រះរាជអាជ្ញាក៏ដូចគ្នាដែរ។ យើងមិនអាចលើកយកជនណាម្នាក់ដែលនៅក្រៅយុត្តាធិការរបស់យើងយកមកពិភាក្សាអំពីទោសរបស់គេទេ នោះជាការបំពានមួយដែលបង្ហាញឲ្យឃើញច្បាស់ក្រឡែតតែម្តង ជាជាងការសម្រេចក្តីលើយុត្តាធិការជាមនុស្សសិន។ ហើយខ្ញុំគ្រាន់តែទទូចទេ ហើយខ្ញុំគិតថាផ្លូវដែលខ្ញុំដើរនេះ គឺជាផ្លូវដ៏ចង្អៀតមួយ ហើយខ្ញុំនៅតែសង្ឃឹមលើឧត្តមគតិ និងមនសិការវិជ្ជាជីវៈ ប្រកបដោយការយល់ដឹងរបស់សហចៅក្រមបរទេស និងចៅក្រមកម្ពុជា និងសហព្រះរាជអាជ្ញាផងដែរ នឹងពិនិត្យមើលសំណើរបស់ខ្ញុំដែលទោះបីវាចង្អៀត ក៏វាមានន័យត្រឹមត្រូវ ហើយវាមានន័យថា យើងគោរពទាំងអស់គ្នា ចំពោះនីតិវិធីត្រឹមត្រូវ-- *ឌូប្រូសេស* ។ អរគុណ។

[០៩:៣៣:៤៧]

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ឆ្លើយតបទៅនឹងការលើកឡើងរបស់ក្រុមមេធាវីការពារក្តី។ ខ្ញុំសូមធ្វើការបំភ្លឺជំហររបស់អង្គជំនុំជម្រះតុលាការកំពូល។ យើងកត់សម្គាល់ឃើញដូចនូវអ្វីដែលគូសបញ្ជាក់ដោយក្រុមមេធាវីការពារក្តីនេះផងដែរ។ ដូច្នេះ ហើយទើបយើងបានលើកឡើង យើងបានកំណត់បញ្ហាយុត្តាធិការនេះ ដាក់ជជែកគ្នាដេញដោលនៅថ្ងៃដំបូង។

[០៩:៣៤:២១]

តាមការយល់ឃើញរបស់យើង យើងបានធ្វើការកំណត់រយៈពេលហ្នឹង ក្នុងរយៈពេលទាំងបីថ្ងៃនេះ។ ដូចដែលលោកប្រធាននិងចៅក្រម មីឡាត បានលើកឡើង អង្គជំនុំជម្រះចង់ឲ្យភាគីប្រឹងប្រែងតាមវិជ្ជាជីវៈរបស់ខ្លួន លើកឡើងទឡ្ហីករណ៍ដោយផ្ទាល់មាត់ទៅតាមពេលវេលាដែលបានកំណត់។ ប្រសិនបើយើងព្យាយាមធ្វើការពន្យាររយៈពេលដែលយើងបានផ្តល់ជូនរួមហើយទៅតាមសំណើនោះ ខ្ញុំព្រួយបារម្ភថា យើងនឹងធ្វើសវនាការសាទុក្ខរហូតដល់មួយអាទិត្យ ឬក៏ពីរអាទិត្យនោះ។ ចំណុចហ្នឹងយើងមិនចង់ឲ្យមានអ៊ីចឹងទេនៅទីនេះ។ យើងដឹងហើយថា យើងមានសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលយើងបានពិភាក្សាគ្នា ហើយយើងបានពិនិត្យរួចរាល់រួចហើយ។

[០៩:៣៥:៣១]

ខ្ញុំគិតថា យើងបានទទួលស្គាល់យ៉ាងពេញលេញថា រយៈពេលនេះមានលក្ខណៈកម្រិតមែន។

ជាថ្មីម្តងទៀត ខ្ញុំសង្ឃឹមថា អស់លោក លោកស្រីត្រូវគិតគូរពិចារណា ថាតើគួរប្រើរយៈពេលដែលបានផ្តល់ជូននេះតាមលទ្ធភាពល្អបំផុតនោះ តាមរបៀបណា។ យើងខ្ញុំមិនចង់ឲ្យអស់លោក លោកស្រី លើកឡើងសេចក្តីសន្និដ្ឋានរបស់ខ្លួនដដែលៗនៅក្នុងសេចក្តីសន្និដ្ឋានរបស់អស់លោក លោកស្រីនោះទេ។ យើងចុចយកចំណុចណាមួយមកចោទសួរឲ្យលោក លោកស្រីឆ្លើយតបជាក់លាក់តែម្តងដូចបានកំណត់នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការ។

ដូច្នេះហើយ យើងបានជ្រើសរើសយកចំណុចទាំងឡាយ ដើម្បីបញ្ជាក់ឲ្យអស់លោក លោកស្រីបញ្ជាក់ឲ្យបានច្បាស់ ដែលអង្គជំនុំជម្រះតុលាការកំពូលចង់ស្តាប់ការដេញដោលនេះ។

[០៩:៣៤:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ, ដូចជាលោកចៅក្រម ណូហ្គូជិ បានមានប្រសាសន៍អំមិញហ្នឹង គឺថាខាងចៅក្រមតុលាការកំពូលយើងក៏បានធ្វើការប្រជុំច្រើនលើកច្រើនសារណាស់ ក្នុងការរៀបចំកាលវិភាគសម្រាប់សវនាការនេះ ហើយក្នុងគោលបំណងហ្នឹង គឺដូចលោកបានមានប្រសាសន៍អ៊ីចឹង គឺថាសំខាន់បំផុតគឺយើងចង់ឲ្យធ្វើយ៉ាងណា គឺឲ្យភាគីដែលលើកឡើងអំពីទឡ្ហីករណ៍ផ្សេងៗនៅក្នុងរយៈពេលបីថ្ងៃនេះ គឺលើកឡើងនូវចំណុចដែលសំខាន់ៗបំផុត គឺមិនចង់ឲ្យខាងអស់លោកហ្នឹងលើកឡើងដដែលៗ ដូចដែលមានសរសេរនៅក្នុងសារណានៃបណ្តឹងសាទុក្ខរបស់អស់លោក ឬក៏ការឆ្លើយតបរបស់លោកដដែលៗនោះទេ។ គឺសំខាន់ គឺឲ្យផ្ទុះបញ្ចាំងអំពីបញ្ហាណាមួយដែលវាមានលក្ខណៈច្បាស់លាស់មកតុលាការកំពូលយើងដែលជាមូលដ្ឋានតាមផ្លូវច្បាប់ គឺសម្រាប់ឲ្យតុលាការកំពូលពិចារណា ហើយដូចដែលមាននៅក្នុងកាលវិភាគសវនាការយើងដែរ ថានៅក្នុងរបស់យើងនេះ គឺយើងបានបញ្ចូលនៅក្នុងសំណួរមួយចំនួនសម្រាប់ឲ្យអស់លោកធ្វើការឆ្លើយតបទៅនឹងសំណួរហ្នឹង ដើម្បីបំភ្លឺដល់ឡើងសវនាការ ក៏ដូចជាបំភ្លឺនៅលើអង្គជំនុំជម្រះតុលាការកំពូលយើងដែរ គឺក្នុងការសម្រេចក្តីនេះធ្វើម៉េចឲ្យមានភាពយុត្តិធម៌នេះ។

អ៊ីចឹង បើអស់លោក មានយោបល់អ្វីបន្ថែមក៏សូមអញ្ជើញ!

បាទ, សូមអញ្ជើញលោកស្រី ជា លាង។

[០៩:៣៨:០៩]

**លោកស្រី ជា លាង៖**

ខ្ញុំសូមបន្ថែមនូវយោបល់បន្តិចទេ គឺពាក់ព័ន្ធការស្នើសុំរបស់ភាគីទាំងអស់ សូម្បីតែសហព្រះរាជ

អាជ្ញា មេធាវីការពារក្តី ក៏ដូចជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំថាពេលវេលានេះ គួរតែតុលាការកំពូលពិចារណាសម្រេចអនុញ្ញាត ឬក៏មិនអនុញ្ញាត។ ប៉ុន្តែ ភ្ជាប់ជាមួយគ្នាហ្នឹងដែរ ខ្ញុំសង្កេតឃើញនូវកាលវិភាគនេះចំនួនបីថ្ងៃ ហើយនិងមានពេលវេលាកំណត់ច្បាស់លាស់នៅក្នុងនេះ ហើយហ្នឹងម្យ៉ាងទៀត ខ្ញុំបានគិតថាដើម្បីគិតកុំពេលវេលាវាចេះតែពន្យារយូរទៅវែងទៅៗនៅដំណើរការសវនាការនេះ។

[០៩:៣៨:៥៨]

ទីមួយ ខ្ញុំសំណូមពរសុំឲ្យអង្គតុលាការកំពូលទាំងមូលហ្នឹងពិចារណាទៅលើសារណាដែលភាគីទាំងអស់ហ្នឹង បានដាក់រួចហើយ។ អានេះក៏ជាផ្នែកមួយជួយឲ្យដំណើរការយើងបានលឿន។

ទីពីរ គឺចង់សុំឲ្យតុលាការកំពូលហ្នឹងពិនិត្យអ្វីដែលបានលើកឡើងនៅអង្គជំនុំជម្រះសាលាដំបូងរួចហើយមកពិចារណាជាមួយគ្នាដែរ។ នេះក៏ជាចំណុចទីពីរ ដើម្បីជួយជំរុញក្នុងការពិចារណា ដើម្បីសម្រេចរាល់លទ្ធផលចុងក្រោយ។

[០៩:៣៩:២៨]

ហើយទីបី ជាការសំណូមពររបស់ខ្ញុំ ក្នុងករណីដែលភាគីទាំងអស់ មិនថាតែភាគីណាទេ ដែលលើកឡើងនៅចំណុចណាមួយដែលគិតថាចំណុចមួយដដែលៗ។ សុំឲ្យអង្គជំនុំជម្រះហ្នឹង កាត់កន្លែងហ្នឹងចោលតែម្តងទៅ ដើម្បីចៀសវាងនូវការចំណាយពេលវេលា។ អានេះជាសំណូមពររបស់ខ្ញុំ ដោយខ្ញុំពិនិត្យទៅលើកាលវិភាគហ្នឹង ខ្ញុំមានការចាប់អារម្មណ៍ទៅលើផ្នែកនេះ។ ប្រសិនជាក្នុងករណីឲ្យតែលើកដដែលៗទេ វាអាចក្នុងការពន្យារពេល និងការស្នើសុំពេលវេលា វាចេះតែវែងទៅៗ។ នេះជាការចាប់អារម្មណ៍របស់ខ្ញុំ។

**ប្រធានអង្គជំនុំៈ**

បាទ, សូមអញ្ជើញលោកមេធាវី។

**លោក ការ សាវុត្ថៈ**

សូមគោរពឯកឧត្តមប្រធាន! យោបល់របស់ខ្ញុំ វាហាក់ដូចជាផ្ទុយពីយោបល់លោកជំទាវ សហព្រះរាជអាជ្ញា។ ពីព្រោះខ្ញុំយល់ថា ការបើកសវនាការនេះ គឺបើកសវនាការជូនប្រជាជនកម្ពុជា ក៏ដូចជាសាកលលោក ដើម្បីឲ្យគេមើលឃើញថា យើងបានរកយុត្តិធម៌ពិតប្រាកដជូនជនជាប់ចោទ។ ដូច្នេះ យើងមិនគួរណាទៅកេងប្រវ័ញ្ចពេលវេលាដែលថានិយាយវែង និយាយខ្លី អាហ្នឹងខ្ញុំថា ដូចមិនគួរកំណត់

ពីរឿងនេះទេ។ អានេះខ្ញុំគ្រាន់តែជូនជាមតិទៅតុលាការ។ សូមអរគុណ។

[០៩:៤១:០៨]

**លោកស្រី ស៊ីលឃី ស្នូតហ្វ៊ីនស្គី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំឆ្លើយតបទៅនឹងយោបល់របស់លោកស្រីចៅក្រម មីឡាត។

យើងខ្ញុំបានពិចារណារួចរាល់ហើយថា ប្រសិនណានេះវាជាលទ្ធភាពមួយដែលឲ្យយើងខ្ញុំអាចដាក់ជូននូវបញ្ហាទូទៅដែលក្រុមមួយនេះបានដាក់ជូន។ ក៏ប៉ុន្តែ បញ្ហាដែលយើងខ្ញុំបានរៀបចំហើយនេះគឺវាពាក់ព័ន្ធច្រើនទៅនឹងកូនក្តីម្នាក់ៗរបស់យើងខ្ញុំ ហើយស្ថានភាពសម្រាប់កូនក្តីមួយៗរបស់យើងខ្ញុំ គឺវាមានលក្ខណៈខុសៗគ្នា។ ហេតុដូច្នេះ វាជាករណីមួយរបស់កូនក្តីរបស់ខ្ញុំដាច់ពីគ្នា ទាក់ទងទៅនឹងការច្រានចោលមិនទទួលឋានៈរបស់គាត់។ ដូច្នេះសម្រាប់យើងខ្ញុំ គឺថាការយល់ទៅដល់អ្នកដែលបានអាននូវបណ្តឹងសាទុក្ខនោះហើយ។ បើសិនជាណាបានតាមដានបណ្តឹងសាទុក្ខហ្មត់ចត់នោះ គឺមិនអីទេ ប៉ុន្តែសម្រាប់សាធារណជន គឺគាត់មិនបានដឹងបញ្ហានេះទេ។

[០៩:៤២:២៨]

ដោយហេតុដូច្នេះ យើងខ្ញុំសុំសំណើយ៉ាងទទូច ដោយសារបញ្ហារបស់យើងខ្ញុំ វាមានបញ្ហាស្មុគស្មាញផង ហើយនេះជាលើកទីមួយ ដែលបញ្ហាសំណងនេះ គឺថាវាអត់ដែលមានយុត្តិសាស្ត្រអីមួយយកមកធ្វើជាសំអាងទេ។ ហើយតុលាការនេះ ក៏ជាតុលាការមួយដែលពិសេស ហើយវាក៏ជាការប្រសើរដែរឲ្យមានការពិភាក្សាទៅលើបញ្ហាសំណងនេះ ដោយយើងខ្ញុំសុំស្នើថា កុំដាក់កម្រិតបន្តឹងពេលវេលាមកលើភាគីនោះធ្វើអ្វី?

ដូច្នេះ ខ្ញុំនៅតែស្នើសុំឲ្យផ្តល់ពេលវេលាបន្ថែមទៀត។ សុំស្នើយ៉ាងទទូចមេត្តាផ្តល់ពេលវេលាមកដល់ក្រុមយើងខ្ញុំចំនួន១៥នាទីបន្ថែមទៀត។ សូមអរគុណលោកប្រធាន។

[០៩:៤៥:០៣]

**ប្រធានអង្គជំនុំ៖**

តើអស់លោក លោកស្រីមានសំណើអ្វីសុំបន្ថែមឬយ៉ាងណាទេ ទាក់ទងបញ្ហាកាលវិភាគសវនាការនេះទៀត។

បាទ, សូមអញ្ជើញលោកមេធាវី។

**លោក កង ឫទ្ធារី៖**

បាទ, ខ្ញុំបានឯកភាពចំពោះគ្រប់ភាគីទាំងអស់ដែលនិយាយអំពីបញ្ហាពេលវេលា។ ប៉ុន្តែ ខ្ញុំចាប់អារម្មណ៍បន្តិច ត្រង់លោកចៅក្រមបាននិយាយថាចៀសវាងការលើកបញ្ហាដដែលៗ ទាំងសហព្រះរាជអាជ្ញាក៏ដូចគ្នាដែរ។ ប៉ុន្តែ បញ្ហាខ្លះយើងមិនត្រូវប្រិតប្រៀងហួសហេតុពេកលើបញ្ហាដដែលៗហ្នឹង ដែលមានសារប្រយោជន៍ មិនមែនមានន័យថាបញ្ហាដដែលៗអត់សារប្រយោជន៍ទេ។ បញ្ហាដដែលៗមានសារប្រយោជន៍។ ពីព្រោះបញ្ហាដដែលៗនេះ វាជាចំណុចសំខាន់ហើយ ទើបជាមានបញ្ហាដដែលៗត្រូវលើកឡើង។ ប៉ុន្តែ វាមានទទ្ធីករណ៍និងករណីយុត្តិសាស្ត្រខ្លះដែលត្រូវលើកឡើងមកជុំគ្នា ពីព្រោះតុលាការនេះទទួលយកនូវករណីប្រើប្រាស់ច្បាប់ទំនៀមទម្លាប់ អ៊ីចឹងវាត្រូវការករណីដដែលៗខ្លះ។

[០៩:៤៥:០៩]

សម្រាប់ខ្ញុំ ខ្ញុំទាត់ចោលការប្រើប្រាស់ទំនៀមទម្លាប់នេះទៅហើយ ដោយសារតែច្បាប់យើងមិនចែងឲ្យប្រើប្រាស់បែបនេះទេ តាមក្រមព្រហ្មទណ្ឌកម្ពុជា។ ប៉ុន្តែ ខ្ញុំមិនលើកនៅពេលនេះទេ ប៉ុន្តែដោយហេតុថា បើយើងមិនលើកនៅពេលនេះ នឹងធ្វើឲ្យតុលាការកំពូលខ្វះមូលដ្ឋានក្នុងការពិចារណាពីអ្វីដែលហៅថាដដែលៗ។ បើសិនបើ ដដែលមានសារប្រយោជន៍ ហើយវាមានបែបបទវា ជាទទ្ធីករណ៍គាំទ្រផ្សេងៗគ្នា ខ្ញុំថាគួរតែកុំត្បិតត្បៀតពេលវេលា ហើយនិងគួរតែកុំធុញទ្រាន់ក្នុងការស្តាប់នូវអ្វីដែលដដែលៗនេះ។ ដើម្បីផ្តល់យុត្តិធម៌ មិនមែនទៅដល់សម្រាប់តែជនជាប់ចោទដែលខ្ញុំជាអ្នកការពារក្តីឲ្យនោះទេ ប៉ុន្តែវាសម្រាប់ដល់ជនរងគ្រោះផងដែរ។ ពីព្រោះថា ការរកយុត្តិធម៌នៅទីនេះ បើត្បិតត្បៀតពេលវេលាពេក ហាក់ដូចជាយើងបានផ្តល់សច្ចធារណ៍នោះវាហួសហេតុពេកទៅលើនរណាម្នាក់រួចជាស្រេច ហើយថា ភាគីទាំងអស់មិនអាចបញ្ចេញបាននូវយោបល់ដែលតំណាងឲ្យផលប្រយោជន៍គ្រប់ភាគីទាំងអស់បាននៅតុលាការនេះទេ។ សូមអរគុណ។

[៩:៤៦:២២]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ប្រហែលជាអស់លោក លោកស្រីអត់មានយោបល់អីបន្ថែមទៅលើកាលវិភាគសវនាការទៀតទេ ហើយដូច្នេះគឺ ដើម្បីឆ្លើយតបទៅនឹងសំណើទាំងអស់ទាក់ទងទៅនឹងកាលវិភាគនេះគឺអង្គជំនុំជម្រះសូមប្រកាសសម្រាកប្រហែលជាដប់នាទី ដើម្បីយើងខ្ញុំចូលទៅពិភាក្សា។ អ៊ីចឹងសូមសម្រាកសិនបាទ។ សូមអញ្ជើញ!

*(កិច្ចប្រជុំរៀបចំសវនាការសម្រាកពីម៉ោង ៩:៤៧នាទី ដល់ម៉ោង ១០:២២នាទី)*

[១០:២២:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ, សូមបន្តកិច្ចប្រជុំរបស់យើងបន្តទៅទៀត។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការពិភាក្សាអម្បាញមិញនេះ គឺទាក់ទងទៅនឹងសំណើរបស់ខាងសហព្រះរាជអាជ្ញា សំណើរបស់សហមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ក្រុមបី ហើយនិងសំណើរបស់ខាងមេធាវីជនជាប់ចោទ។

អ៊ីចឹងយើងឃើញថា នៅថ្ងៃទីមួយ ហ្នឹង គឺសំណើរបស់មេធាវីជនជាប់ចោទហ្នឹង គឺខាងអង្គជំនុំជម្រះយើងសម្រេចថា នឹងឱ្យពន្យារពេលចំនួន ២០នាទី សម្រាប់ឱ្យខាងសហមេធាវីជនជាប់ចោទ សហមេធាវីការពារជនជាប់ចោទសម្រាប់ធ្វើថ្លែងការណ៍នូវ-- ទាក់ទងនឹងបញ្ហាយុត្តាធិការ។

[០៩:២៣:៥៣]

ឯសហមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីនេះគឺ បន្ថែម ១០នាទី ឱ្យចុះនៅថ្ងៃទី១ ហ្នឹង។ ឯសំណើរបស់លោកសហព្រះរាជអាជ្ញា គឺយើងបន្ថែមឱ្យគាត់ ១៥នាទីទៅតាមសំណើរបស់គាត់ ហើយយើងនៅថ្ងៃទី២ ហ្នឹងសំណើរបស់ខាងសហមេធាវីក្រុមពីរ និងក្រុមបីនេះ គឺយើងសូមបន្ថែមមួយក្រុមហ្នឹងគឺ ១៥នាទីៗ។

[១០:២៤:២៤]

ហើយទាក់ទងនឹងបញ្ហាកាលវិភាគសវនាការនេះដែរ គឺខ្ញុំមាន-- សូមសួរទៅខាងសហមេធាវីការពារជនជាប់ចោទដែរ គឺទាក់ទងនឹងបញ្ហានៅថ្ងៃទីមួយនេះ គឺយើងមានចំណុចមួយដែលទាក់ទងនឹងការថ្លែងៗនៅវេលាម៉ោងប្រាំបួនម្ភៃនាទី ដល់ប្រាំបួនម្ភៃប្រាំនាទី ចំនួន៥នាទី ដែលផ្តល់ឱ្យជនជាប់ចោទ ហើយនៅពេលចុងក្រោយនេះ គឺចម្លើយតបរបស់ជនជាប់ចោទហ្នឹងគឺមាន ៣០នាទី។ អ៊ីចឹង នៅក្នុងពេលវេលានេះ តើយើងគិតថាជនជាប់ចោទគាត់មានបំណងនឹងធ្វើការឆ្លើយតប-- ធ្វើការថ្លែងនៅក្នុងពេលដូចការកំណត់នៅក្នុងកាលវិភាគដែរឬទេ? អានេះគឺ កន្លែងគឺជាជម្រើសទេ បើសិនជាគាត់មិនចង់ធ្វើការថ្លែងក៏អង្គជំនុំជម្រះតុលាការកំពូលមិនបង្ខំគាត់ដែរ។ អ៊ីចឹង សូមឱ្យលោកមេធាវីធ្វើការ-- មានយោបល់បន្តិចទាក់ទងបញ្ហាពីរនេះ។ សូមអរគុណ សូមអញ្ជើញ!

**លោក កង ឫទ្ធារី៖**

បើតាមការសម្ភាសន៍ និងការជួបផ្តល់នឹងការផ្តល់យោបល់របស់ខ្ញុំបាទជូនទៅលោក កាំង ហ្គេក អ៊ាវ ហៅ ឌុច គឺថាប្រហែលជាគាត់មិនជំទាស់ទេ ចំពោះសេចក្តីថ្លែងការណ៍ដែលត្រូវបង្គាប់ដោយ

អង្គជំនុំជម្រះតុលាការកំពូល។ ក៏ប៉ុន្តែ គ្រាន់តែថា ពេលវេលាតិច ឬច្រើនអាហ្នឹងអាស្រ័យដោយបំណងរបស់គាត់ ហើយនិងការសម្រេចរបស់លោកប្រធានចុះ។ សូមអរគុណ។

[១០:២៦:០៥]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសួរនេះគឺ នឹងមានការជជែកគ្នារវាងក្រុមខាងចៅក្រមយើងច្រើនដែរ ទាក់ទងនឹងបញ្ហាហ្នឹងគឺពេលវេលា ហើយជាពិសេសទៀតគឺយើងចង់ឲ្យមានពេលវេលាច្រើនដែរ ប៉ុន្តែដោយសារការរៀបកាលវិភាគទៅនឹងវាមានការលំបាកណាស់ គឺអ៊ីចឹងបើមានការបន្ថែមនេះគឺយើងឡើងរហូតដល់ម៉ោងប្រាំអីហើយ។ អ៊ីចឹងពេលវេលាហ្នឹងយើងអាចបង្កើនទៅតាមហ្នឹង។ អ៊ីចឹង សូមអរគុណដែរ ទាក់ទងរបៀបវារៈទីមួយ-- ទាក់ទងរបៀបវារៈទាក់ទងកាលវិភាគសវនាការនេះ។

[០៩:២៦:៤២]

អ៊ីចឹងបន្តទៅទៀត គឺយើងឆ្លងចូលដល់របៀបវារៈទីបី គឺទម្រង់បែបបទនៃសវនាការបណ្ដឹងសាទុក្ខ។ ចំណុចទីមួយ ហ្នឹងគឺបញ្ហាបទបញ្ជាផ្ទៃក្នុង។ ចំណុចទីពីរ គឺការកំណត់ពេលវេលា។ ចំណុចទីបី កន្លែងអង្គុយសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងបទបង្ហាញរបស់ អាយ. ធី. យូ ។

អ៊ីចឹង សូមអញ្ជើញធ្វើការពិភាក្សាទាក់ទងនឹងបញ្ហាទាំងបួននេះ។

[១០:២៧:១២]

ទាក់ទងនឹងបញ្ហាការ-- បទបញ្ជាសវនាការនេះគឺ អង្គជំនុំជម្រះយើងហ្នឹងគឺបានធ្វើការរៀបចំនូវរបៀបវារៈ របៀបបទបញ្ជាផ្ទៃក្នុងដែលត្រូវអនុវត្តក្នុងសាលសវនាការមួយ ហើយប្រហែលជាខាងមន្ត្រីច្បាប់យើងហ្នឹងគឺបានបញ្ជូនទៅឲ្យអស់លោកហើយ ឬក៏មិនទាន់ខ្ញុំក៏មិន ក្ដាប់បានទេ គឺនៅក្នុងនេះគឺ--

[១០:២៧:៥៤]

ជាទូទៅនឹងហ្នឹងគឺខ្ញុំគ្រាន់តែសូមជម្រាបថា បទបញ្ជាផ្ទៃក្នុងសវនាការនេះ គឺមិនខុសឆ្គង មិនខុសប្លែកពីអង្គជំនុំជម្រះសាលាដំបូងទេ គឺយើងធ្វើប្រហាក់ប្រែលគ្នា។

ប៉ុន្តែ គឺចំណុចមួយដែលជាចំណុចទីមួយ នេះគឺអ្នកដែលមានបំណងចូលរួមនៅក្នុងសាលសវនាការទាំងអស់ គឺត្រូវមានវត្តមានក្នុងសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យបានមុន ឬក៏យ៉ាងយូរបំផុតនឹងត្រឹមម៉ោងប្រាំបីសាមនាទី។

[១០:២៨:២៨]

នេះចំណុចនេះ គឺម្សិលមិញហ្នឹងគឺយើងបានធ្វើការពិភាក្សារបស់ចៅក្រមរបស់តុលាការកំពូលយើងគឺថាឲ្យភាគីទាំងអស់ និងសារធារណជនគឺឲ្យចូលមកយ៉ាងយូរបំផុតហ្នឹងគឺត្រឹមម៉ោងប្រាំបីសាមសិបនាទី ហើយក្រៅពីនុ៎ងទៀត គឺអត់មានអីផ្សេងៗទេ។ គឺខ្ញុំសូមអានទាំងអស់តែម្តងដើម្បីឲ្យអស់លោកពិចារណា ហើយក្រែងលោកមានយោបល់បន្ថែមទៀត។

[១០:២៨:៥៨]

ទី២) គឺអ្នកដែលចូលរួមក្នុងសាលសវនាការនេះ គឺត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ និងសមរម្យជានិច្ច។

ទី៣) ហាមយកម៉ាស៊ីនថតរូបភាព ម៉ាស៊ីនថតវីដេអូរ ឧបករណ៍ថតសំឡេង ឧបករណ៍បំពងសំឡេងគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល។

ទី៤) ហាមជក់បារី ហាមយកចំណីអាហារ ភេសជ្ជៈគ្រប់ប្រភេទចូលក្នុងសាលាសវនាការ។

ទី៥) ហាមយកអាវុធគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែភ្នាក់ងារសន្តិសុខដែលមានសមត្ថកិច្ច។

ទី៦) ហាមប្រើប្រាស់ទូរស័ព្ទគ្រប់ប្រភេទក្នុងសាលសវនាការ ថត ហាមថតរូបភាព ថតសំឡេងតាមគ្រប់មធ្យោបាយ។

ទី៧) ហាមប្តូរកន្លែងអង្គុយ ឬដើររហេតរហូតក្នុងសាលសវនាការ។

ទី៨) ហាមទះដៃ ឬក៏ស្រែកជយឃោស ស្រែកឡូឡា ឬក៏ធ្វើឲ្យមានសំឡេងខ្លាំងនាំឲ្យរំខានដល់ដំណើរការសវនាការ។

ទី៩) ហាមដើរចេញចូលដោយអនាធិបតេយ្យនៅពេលសវនាការ ការចេញចូលត្រូវមានការអនុញ្ញាតពីកម្លាំងសន្តិសុខ រក្សាសណ្តាប់ធ្នាប់ក្នុងសាលសវនាការ។

ទី១០) ហាមកុមារដែលមានអាយុតិចជាង១៦ឆ្នាំ ចូលក្នុងសាលសវនាការ។ កុមារដែលមានអាយុចាប់ពី១៦ ទៅ ១៨ឆ្នាំ អាចចូលក្នុងសាលសវនាការបានប្រសិនបើគាត់មកជាមួយឪពុកម្តាយ ឬអាណាព្យាបាល លើកលែងតែកុមារណាដែលត្រូវចូលរួមក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី ឬជាសាក្សី។

១១) ក្នុងករណីដែលមានបុគ្គលប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុង ប្រធានអង្គជំនុំជម្រះតុលាការកំពូលនឹងចាត់វិធានការដើម្បីរារាំងនិងទប់ស្កាត់ភ្លាមតាមករណីសមស្រប ដោយផ្អែកលើកវិធានផ្ទៃក្នុង

នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបទប្បញ្ញត្តិច្បាប់នៃព្រះរាជណាចក្រកម្ពុជាជាធរមាន។

[១០:៣០:៥៧]

បាទ, អ៊ីចឹងគឺបទបញ្ជាផ្ទៃក្នុងគឺមានចំនួន ១១ចំណុច ហើយបើអស់លោកមានយោបល់អីបន្ថែមបន្ថយអីយ៉ាងម៉េចសូមអញ្ជើញ។

បាទ, អ៊ីចឹងបើសិនជាអត់មានយោបល់អីទេ គឺយើងសម្រេចយកទៅតាមហ្នឹងទៅ ហើយសូមឆ្លងចូលដល់ចំណុច(ខ) គឺពេលវេលា-- ការកំណត់ពេលវេលា។

ដោយសារបញ្ហាពេលវេលា ការកំណត់ពេលវេលានេះគឺជាអ្នករៀបចំឡើងគឺដោយលោក មន្ត្រីច្បាប់ អ៊ីចឹងសូមលោក គ្រីស អាចបញ្ជាក់អំពីបញ្ហាពេលវេលាជូនកិច្ចប្រជុំរបស់យើងនេះជ្រាប។

សូមអញ្ជើញលោក គ្រីស្ត។

**លោក គ្រីស្តហ្វឺ ម៉ាក រីយានៈ**

អរុណសួស្តីលោកប្រធាន សូមអរគុណច្រើន។ អ្វីដែលយើងខ្ញុំជាក្រឡាបញ្ជី អាចធ្វើទៅតាមសមត្ថភាពរបស់យើងនោះ គឺការប្រើជាតារាង ដែលថាភាគីទាំងអស់អាចបើកមើលបាន ហើយយើងប្រើជា*ស៊ុះវ៉េ*។ ឧទារណ៍បើសិនណាជាលោក លោកស្រី នៅសល់រយៈពេលប្រាំនាទី ឬដប់នាទី ឬក៏យើងអាចលើកជាសញ្ញាថា នៅសល់ប៉ុន្មាននាទីទៀត ហើយយើងខ្ញុំក៏ស្នើសុំលោក លោកស្រីមេត្តាសហការជាមួយយើងថា តើក្រុមរបស់លោក លោកស្រីផ្ទាល់អាចនឹងពិនិត្យមើលពេលវេលាដែលបានកំណត់ឲ្យនេះបានទេ? ឧទាហរណ៍ថា ពេលវេលាហ្នឹងវាជិតផុតទៅហើយ ឬក៏ជិតអស់ទៅហើយ។

[១០:៣៣:៤៨]

ទាក់ទងទៅនឹងចម្លើយទាំងអស់ ប្រសិនណាជាលោក លោកស្រីអាចមានសំណួរអីទៅនឹងការ-- គេហៅថាកំណត់ពេល ឬបង្ហាញនូវពេលវេលាដែលបានកំណត់នេះ សូមមេត្តាសួរ។ ឧទាហរណ៍ លោកមកដល់នៅម៉ោងប្រាំសាមសិប នៅថ្ងៃចន្ទ យើងអាចនឹងបើកកុំព្យូទ័រគឺថា បើកអាចផ្តល់ជាលេខសម្ងាត់មកឲ្យយើងខ្ញុំ។

[១០:៣៤:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

**លោក អាន់ទ្រូ ខេលី៖**

អរគុណលោកប្រធាន គ្រាន់តែមានការកត់សម្គាល់ទាក់ទងទៅនឹងការកំណត់ពេលវេលា ឬក៏ការតាមដានពេលវេលានេះ។ ខ្ញុំគិតថា នេះគឺជាកំណត់ពេលវេលាដោយខ្លួនឯង ហើយអ្វីដែលខ្ញុំធ្លាប់ធ្វើគឺថា ខ្ញុំយកនាឡិកាមក ខ្ញុំដាក់នៅលើតុ ឬលើអ្វីដែលខ្ញុំត្រូវនិយាយដើម្បីបង្ហាញ ឬក៏អាចធ្វើការបង្ហាញសញ្ញាថា នៅសល់ដប់នាទី ប្រាំនាទី ខ្ញុំថាដូចជាមិនសមស្របនោះទេ។ យើងអាច-- សហការីរបស់យើងអង្គុយជិតគ្នាហ្នឹង អាចនឹងជួយគ្នាប្រាប់។ យើងអាចគេថា សែលវិចយ្យូលេសិន ការដាក់វិន័យ ឬកំណត់ទៅលើខ្លួនឯងដើម្បីគោរពទៅដល់ពេលវេលានេះ ហើយការសម្រាប់បង្ហាញសញ្ញានេះប្រហែលជាមិនសមស្របទេ ជាពិសេស ទាក់ទងទៅនឹងការមើលឃើញ ពីសាធារណជននេះតែម្តង។

[១០:៣៥:២៥]

**ប្រធានអង្គជំនុំ៖**

អឺខ្ញុំ ម្សិលមិញនេះ គឺខាងមន្ត្រីទាក់ទងនឹងបញ្ហាកុំព្យូទ័រហ្នឹងគឺ គេមានធ្វើបទបង្ហាញមួយទាក់ទងនឹងបញ្ហាការនៅក្នុងកុំព្យូទ័រយើងនេះ គឺមានបញ្ហាការផ្តល់សញ្ញាដែរ។ ឧទាហរណ៍ថា បើសិនជាលោកធ្វើបទបង្ហាញទៅ ធ្វើសេចក្តីថ្លែងទៅវាអាចជិតដល់ម៉ោងដល់អី អ៊ីចឹងក្រឡាបញ្ជីគាត់អាចវាយឈ្មោះបញ្ចូលហ្នឹងទៅ ហើយគ្រាន់តែប្រាប់ថា សល់ប៉ុន្មាននាទីៗនៅក្នុងកុំព្យូទ័រហ្នឹង ហើយនឹងវាចេញទៅក្នុងកុំព្យូទ័រនោះហើយ។ ដូច្នេះ គឺសាធារណជនគាត់អត់ដឹងទេ។ តើអាបញ្ហាការធ្វើអ៊ីចឹង តើវាអាចមានផលប៉ះពាល់អីទេ? ហើយបើអត់មានផលប៉ះពាល់ គាត់អាចធ្វើអ៊ីចឹងបាន។ ប៉ុន្តែគឺលោកមានប្រសាសន៍អំមិញគឺល្អណាស់ បើសិនជាយកនាឡិកាយកមកដាក់នៅនឹងមុខហ្នឹង ហើយលោកធ្វើទៅតាមការកំណត់ពេលវេលានេះគឺ នេះរឹតតែប្រសើរមែនទែន អានេះចៀសវាងការរំឭករបស់អង្គជំនុំជម្រះ។

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ខ្ញុំគ្រាន់តែស្នើសុំឲ្យភាគីទាំងអស់សហការគ្នានៅក្នុងការធ្វើបទបង្ហាញ ឬក៏ការឡើងជំទាស់តវ៉ានៅក្នុងរង្វង់ពេលវេលាដែលបានផ្តល់ជូននេះ។ នៅពេលដែលលោកប្រធានគាត់បានអាន។ ឧទាហរណ៍ថា បើសិនណាជាអាចនឹងអានទៅវាលើសពេលវេលាអីដូច្នេះជាដើម គឺថាយើងនៅក្នុងរយៈពេលមួយថ្ងៃ យើងមានបញ្ហាច្រើនណាស់ដែលត្រូវលើកឡើងមកដេញដោលគ្នា។ ហើយការបញ្ចប់នៅម៉ោងប្រាំល្ងាច ប្រហែលជានេះ គឺជាម៉ោងមួយដែលយឺតបំផុតហើយ ដែលយើងត្រូវបញ្ចប់នៅពេលល្ងាច ដែលសម្រាប់បុគ្គលិក ដែលបំពេញការងារឲ្យអង្គជំនុំជម្រះតុលាការកំពូលយើងនេះ។

[១០:៣៧:៤៣]

អ៊ីចឹងបើសិនណាជាលោក លោកស្រីមើលទៅលើកម្មវិធីនេះទៅ យើងនឹងឃើញថា បើសិនណាជាបទបង្ហាញនេះវាអាចលើសម៉ោងដែលត្រូវបានកំណត់ មានន័យថា លោក លោកស្រីកំពុងតែរំលោភទៅលើការផ្តល់ពេលវេលាដែលបានផ្តល់ជូននេះហើយ។ ដូច្នេះ ខ្ញុំសូមស្នើឲ្យលោក លោកស្រីមេត្តាអនុវត្ត ឬក៏ប្រើប្រាស់នូវជំនាញវិជ្ជាជីវៈរបស់ខ្លួន នៅក្នុងការធ្វើយ៉ាងម៉េចឲ្យការឡើងអាន ឬក៏ការឡើងនិយាយអ្វីមួយនេះគឺស្ថិតនៅក្នុងតែរង្វង់ពេលវេលាកំណត់។

[១០:៣៨:២១]

ខ្ញុំមិនច្បាស់សម្រាប់បញ្ហារឿង *ស្ពះវ័រ* នេះទេ វាអាស្រ័យទៅលើយើងម្នាក់ៗនោះទេ ដោយសារលោក លោកស្រីខ្លះប្រហែលជាមិនធ្លាប់បានប្រើប្រាស់ នៅលើបញ្ហា *ស្ពះវ័រ* នេះទេ ហើយខ្ញុំបានកត់សម្គាល់ថា បើសិនណាខ្ញុំមិនៗប៉ះកុំព្យូទ័រនេះ ក្នុងរយៈពេល១៥នាទីទេ គឺវានឹងត្រូវបិទជាស្វ័យប្រវត្តិតែម្តង។ ដូច្នេះ ប្រហែលជាអ្នកដែលនិយាយគឺថាមិនអាចប៉ះកុំព្យូទ័រនេះទេ ហើយ*ស្គ្រីន* ហ្នឹងក៏វាបិទទៅជាស្វ័យប្រវត្តិទៅ។ ដូច្នេះ ខ្ញុំកត់សម្គាល់ឃើញយោបល់ពីលោកសហព្រះរាជអាជ្ញាអន្តរជាតិ ហើយអង្គជំនុំជម្រះតុលាការកំពូល គឺថានឹងគោរពបញ្ហានេះមិនចង់ធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍ ឬធ្វើឲ្យវាគ្មិនដែលកំពុងមានប្រសាសន៍ហ្នឹង មានការខ្មាសអៀននោះទេដោយការលើកជាសញ្ញាផ្សេងៗដូច្នោះទេ។ ប៉ុន្តែ ពេលខ្លះអ៊ួ! ហើយខ្ញុំប្រហែលជាយើងរកវិធីសាស្ត្រណាដែលមានការគួរសមបំផុត ដែលអាចជាការបង្ហាញក្រដាសតូចមួយក្នុងលក្ខណៈមួយស្ងាត់បំផុត ដើម្បីគ្រាន់តែកេះទៅហើយរំឭកថា លោកអស់ពេលហើយ អស់ពេលនិយាយហើយ។

[១០:៣៩:៤២]

ដូច្នេះ ចំណុចទាំងអស់នេះគឺ គ្រាន់តែធ្វើឡើងដើម្បីក្នុងបំណងរក្សាថា យើងម្នាក់ៗត្រូវបានទទួលឱកាសគ្រប់គ្រាន់ទៅតាមពេលវេលាដែលបានកំណត់ តែបើថាវាលើសពេលវេលាកំណត់ មានន័យថា លោក លោកស្រីក៏កំពុងតែសម្លាប់ពេលវេលារបស់អ្នកដទៃទៀតហើយ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រីសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ស៊ីលយី ស្ទួតហ្វ៊ីនស្គី៖**

សូមអរគុណលោកប្រធាន។

ថាតើត្រូវទេដែលលោកចៅក្រមមានប្រសាសន៍ថា *សុះវែរ* នេះគឺភ្ជាប់ទៅនឹង*ឡូតូស* នេះកម្មវិធី *ឡូតូស* តែម្តង។ ប៉ុន្តែ ខាងមេធាវីខ្លះមិនដែលមាន មិនដែលធ្លាប់បានប្រើប្រាស់ ដូច្នេះមិនមានលទ្ធភាពបើកមើលកម្មវិធី*ឡូតូស* ទៅបាន។ ប្រហែលជាយើងខ្ញុំមិនអាចត្រូវការបញ្ហា *សុះវែរ* នេះទេប្រហែលយើងខ្ញុំនឹងគេថាហៅថា គ្រប់គ្រងខ្លួនឯងតែម្តងក្នុងការរក្សាពេលវេលានេះ ដោយមិនបាច់ចូលទៅមើលកម្មវិធី*ឡូតូស* អីនោះៗទេ ដោយមិនបាច់ប្រើប្រព័ន្ធកុំព្យូទ័រនេះទេ។ សូមអរគុណ។

[១០:៤១:០០]

**លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន៖**

តាមការយល់របស់ខ្ញុំពីខាងផ្នែកអង្គភាព ខាងផ្នែកបំពាក់កុំព្យូទ័រនេះគឺ ប៉ុន្តែប្រសិនណាលោកលោកស្រីមិនចង់ប្រើប្រព័ន្ធ*សុះវែរ* ទេគឺថា យើងខ្ញុំនឹងមិនបាច់ដំឡើងជូនទេ។

[១០:៤១:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណណាស់ ចំពោះការផ្តល់យោបល់ និងមានការមានមតិរបស់អស់លោកអំមិញ គឺខ្ញុំសប្បាយចិត្តណាស់ គឺថាអស់លោកនឹងធ្វើយ៉ាងណា គឺគោរពនូវបញ្ហាពេលវេលា ហើយនិងទៅតាមវិធាននៃវិជ្ជាជីវៈរបស់ខ្លួនទៅតាមការកំណត់របស់កាលវិភាគសវនាការ។

ឆ្លងចូលដល់របៀបវារៈ ចំណុចមួយទៀតគឺទាក់ទងនឹងបញ្ហាកន្លែងអង្គុយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ទាក់ទងនឹងបញ្ហានេះគឺ សូមអញ្ជើញលោក គ្រីស្ត ដែរ ដែលអញ្ជើញធ្វើការបង្ហាញបន្តិចអំពីបញ្ហាកន្លែងដែលសម្រាប់ទទួលដើមបណ្តឹងរដ្ឋប្បវេណី និងចំនួនដែលត្រូវចូលមកអង្គុយនៅក្នុងសាលសវនាការ។ សូមអញ្ជើញ!

[១០:៤២:៣៦]

**លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះតុលាការកំពូល មានឯកសារដែលបញ្ជាក់ថាតើដើមបណ្តឹងរដ្ឋប្បវេណីក្រុមណាដែលមានបំណងចូលរួមមកក្នុងសវនាការលើបណ្តឹងសាទុក្ខចំនួនបីថ្ងៃនេះ។ សម្រាប់ថ្ងៃទីមួយ យើងមានភាគីចំនួន ៨ ដើមបណ្តឹងរដ្ឋប្បវេណី ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨។ ហើយនៅថ្ងៃពុធ ទី៣០ ក៏ដូចគ្នាដែរ។ ដូច្នេះ យើងខ្ញុំសុំឲ្យមេធាវីមេត្តាបញ្ជាក់មកយើងខ្ញុំ ពីរឿងបញ្ហានេះឲ្យបានច្បាស់លាស់។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី។

[១០:៤៣:២១]

**លោកស្រី ស៊ីលឃើស្វូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន។

ខ្ញុំអាចបញ្ជាក់បានថា សម្រាប់ថ្ងៃទីមួយៗនៃសវនាការទាំងបី នេះគឺដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨ នឹងចូលរួម។ ពីម្សិលមិញ យើងបានផ្លាស់ប្តូរកែប្រែឈ្មោះ ប្រសិនខ្ញុំមិនដឹងថា តុលាការកំពូលនឹងទទួលបានឯកសារដែលបានធ្វើបច្ចុប្បន្នភាពកាលពីម្សិលមិញហើយឬនៅទេ? ប៉ុន្តែ យើងមានការផ្លាស់ប្តូរឈ្មោះតែប៉ុណ្ណោះ។ ប៉ុន្តែ ខ្ញុំនឹងអាចជម្រាបជូនទៅខាងក្រឡាបញ្ជីជាមុនបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ទាក់ទងនឹងបញ្ហាដើមបណ្តឹងរដ្ឋប្បវេណី គឺស្នើសុំឲ្យសហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបីក្រុមហ្នឹង គឺធ្វើជាលិខិតឲ្យបានច្បាស់មកថាតើថ្ងៃទីមួយហ្នឹង ត្រូវចូលមេធាវីប៉ុន្មាននាក់? អ្នកនៃ! ដែលចូលដើមបណ្តឹងរដ្ឋប្បវេណីប៉ុន្មាននាក់? ហើយមានឈ្មោះអីខ្លះ? ឲ្យគ្រប់ទាំងបីថ្ងៃហ្នឹងតែម្តង ដើម្បីងាយស្រួលដល់ខាងមន្ត្រីច្បាប់របស់យើងសម្រាប់កត់ត្រាទុក ទាក់ទងនឹងបញ្ហាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលសវនាការនេះ។

[១០:៤៤:៤២]

បាទ, អ៊ីចឹងបើអត់មានអីទៀតទេ គឺយើងអាចចូលទៅដល់បញ្ហាមួយទៀត គឺទាក់ទងនឹងបទបង្ហាញរបស់ អាយ.ធី.យូ។ អ៊ីចឹងមន្ត្រីខាង អាយ.ធី.យូ បើសិនមានអញ្ជើញមក សូមអញ្ជើញធ្វើបទបង្ហាញ។ បាទ សូមអញ្ជើញ!

**លោក គាំ ច័ន្ទមុន្នី៖**

ខ្ញុំបាទឈ្មោះ គាំ ច័ន្ទមុន្នី សូមគោរពប្រធាន លោក លោកស្រីចៅក្រម លោក លោកស្រីសហព្រះរាជអាជ្ញា និងអស់លោក លោកស្រីតំណាងស្ថាប័នពាក់ព័ន្ធទាំងអស់។

មកដល់ពេលនេះ អាយ.ធី.យូ បានខិតខំប្រឹងប្រែងផ្តល់សេវាបកប្រែឲ្យគ្រប់ភាគីទាំងអស់ រួមទាំងការបកប្រែភាសា និងការបកប្រែផ្ទាល់មាត់ផងដែរ។

ខ្ញុំបាទ សូមធ្វើបទបង្ហាញសង្ខេបពាក់ព័ន្ធនឹងការផ្តល់សេវាបកប្រែឯកសារ។ ចំណែកឯការបក

ប្រែផ្ទាល់មាត់នោះនឹងកញ្ញា ស៊ូហ្សាន វ៉ូ គាត់នឹងធ្វើបទបង្ហាញជូននៅពេលដែលខ្ញុំបានបញ្ចប់ការបង្ហាញនេះ។

[១០:៤៥:៤៥]

ពាក់ព័ន្ធទៅនឹងការបកប្រែឯកសារ អាយ.ធី.យូ បានផ្តល់សេវាជាអាទិភាពដល់សំណុំរឿង០០១ ហើយប្រសិនបើមានឯកសារបន្ថែមចាំបាច់សម្រាប់សំណុំរឿង០០១ នេះទៀត អាយ.ធី.យូ សុំការសហការពីភាគីទាំងអស់ឲ្យជូនដំណឹងឲ្យអង្គភាពបកប្រែយើងខ្ញុំឲ្យបានទាន់ពេលវេលាដើម្បីឲ្យអង្គភាពយើងខ្ញុំនេះត្រៀមកម្លាំងបកប្រែជូនតាមសំណើ។

[១០:៤៦:១៨]

ដោយយោងតាមទំហំឯកសារដែលយើងត្រូវបកប្រែនោះ អាយ.ធី.យូ បានស្វះស្វែងរកមធ្យោបាយផ្សេងៗដូចជា ការជ្រើសរើសបុគ្គលិកបកប្រែដែលមានរយៈពេលខ្លីមួយចំនួន ហើយនិងយើងបាន *អៅស៊ុះ* ឯកសារមួយចំនួនទៀតទៅឲ្យក្រុមហ៊ុនផ្សេងៗ ដែលឯកសារទាំងនោះពេលដែលយើងដាក់ *ហ្វាលីង* នៅក្នុង*ស៊ីស្ទិម* របស់យើងត្រូវបានពិនិត្យដោយមន្ត្រីផ្ទៀងផ្ទាត់ឯកសារជាតិ និងអន្តរជាតិដោយជាក់លាក់។ ពាក់ព័ន្ធទៅនឹងការបកប្រែផ្ទាល់មាត់ខ្ញុំសូមអញ្ជើញកញ្ញា ស៊ូហ្សាន វ៉ូ ធ្វើការបទបង្ហាញជូនអង្គប្រជុំ។ សូមអរគុណ។

**កញ្ញា ស៊ូហ្សាន វ៉ូ៖**

អរុណសួស្តីលោកប្រធាន និងអស់លោក លោកស្រីជាទីគោរព។

ខ្ញុំឈ្មោះ ស៊ូហ្សាន វ៉ូ ជាអ្នកបកប្រែភាសាផ្ទាល់មាត់នៅក្នុងអង្គភាពបកប្រែភាសា។ ខ្ញុំចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការក្នុងថ្ងៃនេះតំណាងលោកស្រី មីសែល ឃីតធីង មន្ត្រីសម្របសម្រួលជាន់ខ្ពស់នៅក្នុងអង្គភាពបកប្រែភាសា។

[១០:៤៧:៤៣]

ខ្ញុំនឹងធ្វើការបង្ហាញយ៉ាងខ្លី ទាក់ទងទៅនឹងការផ្តល់សេវាការបកប្រែភាសា ក្នុងសប្តាហ៍ក្រោយនេះ។ នៅពេលនេះយើងខ្ញុំត្រៀមនឹងឆ្លើយតបសំណួរទាំងឡាយ ពាក់ព័ន្ធទៅនឹងការផ្តល់សេវាបកប្រែភាសាផ្ទាល់មាត់ និងការបកប្រែឯកសារ។

នៅពេលនេះ ខ្ញុំសូមបញ្ជាក់ថា វាមិនខុសពីសវនាការលើសំណុំរឿងលេខ០០១ ទេ យើងនឹងបកប្រែទៅជាបីភាសា អង់គ្លេស បារាំង និង ភាសាខ្មែរ។ ប៉ុន្តែ នៅពេលនេះមានចំណុចខុសគ្នា។ មន្ត្រី

បកប្រែរបស់យើង ១០ រូប ដែលកំពុងអង្គុយបកប្រែនៅក្នុងទូក្រោយកន្លែងអង្គុយសម្រាប់សាធារណជន នឹងផ្តល់ការបកប្រែប្រដេញជា ប្រាំភាសា មិនមានន័យថា មិនមានន័យថាពី ខ្មែរ ទៅ អង់គ្លេស, អង់គ្លេស ទៅ ខ្មែរ, បារាំង ទៅ អង់គ្លេស, អង់គ្លេស ទៅ បារាំង, និង បារាំង ទៅ ខ្មែរ។ ដូច្នេះហើយ ការបកប្រែ មួយទៀតការបកប្រែ ខ្មែរ ទៅជា បារាំង នឹងធ្វើការបកប្រែតាមលក្ខណៈបន្តគ្នា។ ភាសាខ្មែរ ដំបូងនឹងបកទៅជាភាសាអង់គ្លេស បន្ទាប់មក អង់គ្លេស នឹងបកប្រែទៅជាភាសាបារាំង។ នេះគឺទាក់ទងទៅនឹង ភាសាខ្មែរ បកប្រែទៅជា ភាសាបារាំង។

[១០:៤៩:០៨]

ខ្ញុំដឹងហើយថា នៅពេលនេះយើងមានការបកប្រែបន្តគ្នា ហើយខ្ញុំក៏សូមឲ្យលោក លោកស្រីចាប់អារម្មណ៍ថា យើងក៏ផ្តល់មន្ត្រីបកប្រែសម្របសម្រួលមួយរូប ដើម្បីជួយបកប្រែនៅពេលពិភាក្សាគ្នា ក្នុងចំណោមក្រុមប្រឹក្សាជំនុំជម្រះ ហើយប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះ ចង់ថយទៅពិភាក្សានោះ យើងនឹងសុំឲ្យអ្នកបកប្រែក្នុងទូមួយរូប ចុះមកធ្វើការផ្តល់សេវាបកប្រែជូនអស់លោក លោកស្រីចៅក្រម ជាក្រុមប្រឹក្សាជំនុំជម្រះ។

ចំណុចយើងពិចារណាទី១ គឺវាជាចំណុចមួយដែលដដែល យើងចង់លើកឡើងដដែល។ យើងខ្ញុំសូមរំឭកឲ្យភាគីទាំងអស់និយាយយឺតៗ ការនិយាយយឺតៗនេះ គឺដើម្បីឲ្យយើងបកប្រែឲ្យចប់សព្វគ្រប់និងត្រឹមត្រូវ។

[១០:៥០:០៣]

ចំណុចនេះមានន័យថា សូមឲ្យលោក លោកស្រីធ្វើការផ្អាកនៅចុងប្រយោគ ឬក៏ចំណុចណាមួយជាក់លាក់នៅក្នុងយោបល់របស់លោកស្រី។

សូមឲ្យលោក លោកស្រីរង់ចាំអ្នកបកប្រែដែលបកប្រែប្រដេញ ឬក៏បកប្រែបន្តគ្នាក៏ដោយ សូមឲ្យគេបកប្រែចប់សិន ដើម្បីឲ្យគាត់ហ្នឹងអាចបកតទៅទៀត ឬក៏សូមលោកស្រីហ្នឹងចាំបន្តិចសិនដើម្បីឲ្យគេបកប្រែទាន់។ ហើយខ្ញុំក៏សូមឲ្យលោក លោកស្រីផ្អាកឲ្យបានយូរបន្តិចដែរចំពោះលោក លោកស្រីដែលនិយាយ-- ទម្លាប់និយាយលឿន។

[១០:៥០:៤២]

លោក លោកស្រី បានកត់សម្គាល់ហើយថា ការបកប្រែទៅជាភាសាមួយនោះវាតែងយូរជាងភាសាដើម។ នៅពេលដែលអ្នកនិយាយម្នាក់បញ្ឈប់ការនិយាយរបស់ខ្លួន អ្នកបកប្រែនៅបន្តបកដដែល។

ហើយចំពោះការបកប្រែភាសាខ្មែរទៅភាសាបារាំងនោះ ជាដំបូងគេបកប្រែពីភាសាខ្មែរទៅអង់គ្លេស បន្ទាប់មក អង់គ្លេសទៅជាភាសាបារាំង។ ដូច្នេះ អ្នកដែលនិយាយសូមឲ្យរង់ចាំ ១៥ ទៅ ៣០ វិនាទីសិន មុនពេលដែលយោបល់ទាំងអស់នោះបានបកប្រែចប់សព្វគ្រប់។

[១០:៥១:១៨]

ប្រសិនបើមានបញ្ហាល្បឿនចំពោះអ្នកបកប្រែគេនឹងជូនដំណឹង ហើយការជូនដំណឹងនេះក៏ជូនដំណឹងតាមរយៈមន្ត្រីតុលាការ ឬក៏តាមរយៈលោកប្រធានអង្គជំនុំជម្រះ។ ចំណុចទីពីរ នឹងជាចំណុចជាក់ស្តែងផងដែរ អ្នកនិយាយម្នាក់ គឺយើងអាចបកប្រែតែអ្នកនិយាយម្នាក់ក្នុងពេលម្តងតែប៉ុណ្ណោះ។

ដូចដែលលោក លោកស្រីបានកត់សម្គាល់ឃើញហើយថា អ្នកបកប្រែគឺ គាត់កំណត់ថានរណាជាអ្នកនិយាយ ជាពិសេសនៅពេលមានការផ្លាស់ប្តូរអ្នកនិយាយនោះ ក៏មានការបញ្ជាក់ផងដែរ។

ឧទាហរណ៍ នៅពេលលោកប្រធាននិយាយជាភាសាខ្មែរ ហើយផ្តល់វេទិកាទៅដល់លោកស្រី ជា លាង និយាយបន្តជាភាសាខ្មែរ អ្នកបកប្រែនឹងកំណត់ថាតើនៅពេលនេះនឹងមានការផ្លាស់ប្តូរអ្នកនិយាយ។ ការធ្វើដូច្នេះដើម្បីឲ្យអ្នកស្តាប់ ហើយអស់លោក លោកស្រីដឹង ហើយជាពិសេសនោះដើម្បីកត់សម្គាល់នៅក្នុងប្រតិចារឹក ហើយឲ្យពាក្យពេចន៍ទាំងឡាយនោះដាក់ចំអ្នកនិយាយ។

[១០:៥២:២៣]

ហេតុដូច្នេះហើយ ប្រសិនបើមនុស្សពីរនាក់និយាយនៅពេលតែមួយដូចជា “ក” និយាយជាន់គ្នាជាមួយនឹង “ខ” ឬក៏ “គ” មកធ្វើកាត់សម្តី។ ដូច្នេះ នៅពេលនោះនឹងមានការនិយាយជាន់គ្នា។ ប្រសិនបើមានករណីបែបនេះ អ្នកបកប្រែនឹងធ្វើកាត់បិទមីក្រូហ្វូន។ យើងដឹងច្បាស់ហើយថា យើងមិនអាចបកប្រែមនុស្សពីរនាក់ ក្នុងពេលតែមួយបានឡើយ។

[១០:៥២:៤៤]

ខ្ញុំសូមនិយាយសង្ខេបទៅលើចំណុចទីបី ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់វីដេអូ។

ប្រសិនបើអ្នកចូលរួមចង់ធ្វើការបញ្ចាំងវីដេអូក្នុងពេលសវនាការ ដោយសង្ឃឹមថា អ្នកបកប្រែហ្នឹងនឹងអាចបកប្រែបណ្តោញទៅលើសំឡេងបាននោះ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ស្ថានភាពរបស់ អាយ.ធី.យូ ដូចតទៅ៖

យើងត្រៀមខ្លួននឹងបកប្រែវីដេអូ ប្រសិនបើយើងអាចមើលវីដេអូនោះមួយថ្ងៃមុន។ ដូច្នេះ យើងសង្ឃឹមថា អាចផ្តល់ឲ្យយើងវីដេអូនេះជា ឌីវីឌី ឬក៏តាមប្រព័ន្ធភ្ជាប់ណាមួយ ដើម្បីឲ្យយើងអាចយល់

ច្បាស់ ហើយដើម្បីឲ្យយើងដឹងថាយើងអាចបកប្រែខ្លឹមសារទាំងអស់នោះបាន។ ហើយនៅពេលដែលយើងមើល យើងអាចកំណត់អំពីចំណុចបច្ចេកទេស ដូចជាពេលខ្លះវាមានសំឡេង ដែលវាឥតប្រយោជន៍ ដែលយើងអាចកត់សម្គាល់មិនអាចបកប្រែបាន។

[១០:៥៣:៤៧]

ប្រសិនបើអ្នកបកប្រែមិនអាចជូនដំណឹងជាមុន ទៅលើវីដេអូនោះទេ យើងនឹងមានការភ្ញាក់-- វានឹងធ្វើឲ្យមានការភ្ញាក់នៅពេលដែលយើងស្នើសុំឲ្យធ្វើការផ្អាកសវនាការ ដើម្បីរៀបចំត្រៀមបកប្រែឯកសារវីដេអូទាំងអស់នោះ។ ដោយសារតែអ្នកបកប្រែគាត់ទទួលចំណុចជាក់លាក់ពីអ្នកនិយាយតែចំណុចមួយចំនួនតែប៉ុណ្ណោះ យើងមិនអាចបកប្រែ ឬក៏អានឲ្យពេញលេញទៅលើចំណុចដកស្រង់មួយចំណុចចេញពីឃ្លានោះទេ។ ដូច្នេះ អ្នកបកប្រែនឹងបកប្រែទៅជាភាសាផ្លូវការរបស់តុលាការ តាមការអានរបស់អ្នកលើកឡើង។

[១០:៥៤:៣៣]

ពាក់ព័ន្ធនឹងចំណុចនេះខ្ញុំសូមរំឭកភាគីទាំងអស់គ្នាថា ប្រសិនបើអានឯកសារ សូមកុំភ្លេចលើកលេខយោងឯកសារ និងលេខទំព័រ ហើយសូមអានលេខ អ៊ី.អ័រ.អ៊ិន ឲ្យបានយឺតៗដើម្បីឲ្យយើងដឹងទាំងអស់គ្នា។ ចំណុចទី៤ និងចំណុចចុងក្រោយដែលខ្ញុំចង់លើកឡើង គឺពាក់ព័ន្ធទៅនឹងការ-- ចំណុចសំខាន់នៃការរៀបចំនៅក្នុងការងាររបស់អ្នកបកប្រែ។ អ្នកបកប្រែ គឺរៀបចំយ៉ាងយកចិត្តទុកដាក់ គឺគេពិនិត្យមើលគ្រប់ឯកសារពាក់ព័ន្ធនៅក្នុងសំណុំរឿង រួមទាំងពិនិត្យមើលឯកសារតាមរយៈ *ហ្សាយឡេប*។ ប៉ុន្តែប្រសិនបើអ្នកចូលរួមអាចផ្តល់កំណត់សម្គាល់សម្រាប់និយាយជាមុន អ្នកបកប្រែអាចរៀបចំត្រៀមខ្លួនជាក់លាក់។ ចំណុចនេះ វាធ្វើឲ្យមានការកើនឡើងនៃគុណភាពការផ្តល់សេវាបកប្រែ។

[១០:៥៥:៣០]

ដូច្នេះ អាយ.ធី.យូ ជំរុញឲ្យភាគីទាំងអស់ផ្តល់ឯកសារ សម្ភារៈ ពាក់ព័ន្ធទៅនឹងសវនាការ ជាពិសេសកំណត់សម្គាល់សម្រាប់លើកឡើងនៅពេលសវនាការ។ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតថា ឯកសារទាំងអស់នេះយើងខ្ញុំនឹងរក្សាការសម្ងាត់តឹងរ៉ឹងបំផុតជាដរាប គឺយើងតែងតែធ្វើដូច្នេះជាដរាប។ ឯកសាររបស់លោក លោកស្រី អាចផ្តល់ជូនជាឯកសារក្រដាសក៏បាន ឬក៏តាមរយៈអេឡិចត្រូនិច។

យើងខ្ញុំស្នើសុំឲ្យអស់លោក លោកស្រីផ្តល់កំណត់សម្គាល់សម្រាប់លើកឡើងនោះមិនថាជាទម្រង់ *ប៊ូឡេត* ចំណុចៗ ឬទម្រង់តេឡេក្រាមនោះទេ យ៉ាងហោចណាស់ឲ្យបានត្រឹមថ្ងៃសុក្រ ទី២៥ ខែ

មីនា ហើយយើងខ្ញុំនឹងរង់ចាំឯកសារចុងក្រោយនៅអាទិត្យក្រោយ។

[១០:៥៦:១៦]

ខ្ញុំសូមបញ្ជាក់ថា ការទទួលបានឯកសារជាបន្តបន្ទាប់នេះគឺ វាល្អជាងការមិនទទួលបានឯកសារអ្វីទាំងអស់ ឬក៏វាល្អជាងការទទួលឯកសារនេះនៅថ្ងៃចុងក្រោយ។ លោក លោកស្រីអាចបញ្ជូនឯកសារទាំងអស់ទៅលោក មួង ណារ៉េត ឬក៏ទៅលោកស្រី មីសែល ឃីតធីង។ ហើយសូមអស់លោក លោកស្រីដាក់ថ្ងៃខែបញ្ជាក់ផង ដើម្បីឲ្យអ្នកបកប្រែដឹងថា ឯកសារណាមួយជាឯកសារចុងក្រោយ។

[១០:៥៦:៤៦]

ខ្ញុំសូមសង្ខេបសរុបថា នៅពេលដែលយើងមានពេលកាន់តែច្រើនសម្រាប់រៀបចំនោះ យើងនឹងផ្តល់សេវាបកប្រែរបស់យើងកាន់តែល្អឡើង។ ដូច្នេះហើយ ខ្ញុំសូមជម្រាបលោកប្រធានថា យើងខ្ញុំរង់ចាំទទួលសំណួរទាំងឡាយពីលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អ៊ីចឹងបន្ទាប់មានការបទបង្ហាញរបស់ខាងអ្នកបកប្រែ គឺសូមអញ្ជើញសមាជិក សមាជិកានៃកិច្ចប្រជុំគឺបើមានសំណួរ ឬក៏មានយោបល់អីឆ្លើយតបទៅនឹងការបទបង្ហាញអំមិញនេះ គឺសូមអញ្ជើញលើកឡើង។

បាទ, សូមអញ្ជើញលោកសហមេធាវី។

**លោក ការ សាវុត្ថ៖**

សូមគោរពឯកឧត្តមប្រធាន និងអង្គប្រជុំទាំងមូល។

ខ្ញុំជាមេធាវីការពារឲ្យជនជាប់ចោទ ហាក់ដូចជាអស់ជម្រើស ហាក់ដូចជាត្រូវតែគោរពតាម ប៉ុន្តែការរកយុត្តិធម៌ឲ្យជនជាប់ចោទ ហាក់ដូចជាមិនបានត្រឹមត្រូវដោយពេលវេលានេះឯង។

[១០:៥៨:០៥]

ខាងតុលាការបានកំណត់ម៉ោងពេលឲ្យមេធាវីនិយាយ ន៎ៈ!ធ្វើម៉េចនិយាយឲ្យបានត្រឹមត្រូវតែក្នុងពេលដែលបានកំណត់។ ដល់ទៅ អាយ.ធី.យូ ថាសូមឲ្យនិយាយមួយៗ យឺតៗ ដើម្បីឲ្យគេកត់ត្រាទាន់ ហើយនិយាយចប់មួយវគ្គអ៊ីចឹងទៅ សូមឲ្យឈប់ប្រហែល ៣០ វិនាទីទៀត។ អ៊ីចឹង វាឃើញថាមានការលំបាកមួយទៅហើយ។ អ្ហ៎! ដល់ទៅអ្នកបកប្រែថាបកប្រែពីខ្មែរហ្នឹង បើខ្ញុំនិយាយខ្មែរហ្នឹង គេបកទៅជាអង់គ្លេស ចាំគេបកជាអង់គ្លេស ចប់បានគេបកជាបារាំង។ ដូច្នេះ គ្រាន់តែអាកន្លែងបក ហើយនិង

អាកន្ទែងគេកត់នែ៎! រង់ចាំគេហ្នឹងវាខាតពេលច្រើនណាស់។ ដូច្នេះការដែលនិយាយទៅ ដើម្បីស្វែងរកយុត្តិធម៌នោះ វាអត់បានអស់ពីចិត្តពីថ្លើម ដើម្បីឲ្យជនជាប់ចោទអស់ចិត្ត ថាមុននឹងគេជាប់គុក នែ៎ត្រូវឲ្យមេធាវីហ្នឹងនិយាយឲ្យវាអស់ចិត្តគេ។ ដូច្នេះ គោរពអត់បាន។ ដូច្នេះទីនេះ ខ្ញុំមិនមែនជាតវ៉ាដើម្បីឲ្យតុលាការតម្រូវមកតាមមតិរបស់ខ្ញុំទេ នេះគ្រាន់តែជាការចាប់អារម្មណ៍មួយ សូមឲ្យតុលាការមេត្តាពិចារណាចុះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកមេធាវី។

**លោក កង ឫទ្ធារី៖**

[១០:៥៩:២៦]

ខ្ញុំមានលក្ខណ:ស្រដៀង។ សូមទោស។ ជាបឋម សូមគោរពលោកប្រធានតុលាការកំពូល និងអង្គប្រជុំទាំងមូលបាទ។

ខ្ញុំយល់ពីស្ថានភាពរបស់ខាង អាយ.ធី.យូ គាត់ប្រឹងប្រែងអស់សមត្ថភាពរបស់គាត់ត្រឹមប៉ុណ្ណឹងមែន ហើយយើងក៏ទទួលស្គាល់នឹងលក្ខណ:ឡូស៊ីកនេះដែរ។ ការងារវាមិនអាចធ្វើឲ្យលើសពីហ្នឹងបានទេ ក៏ប៉ុន្តែការងារពួកខ្ញុំក៏ដូចគ្នាដែរវា ជាពិសេសខ្ញុំជាមនុស្សដែលមានទម្លាប់និយាយលឿន ហើយការងារដែលតុលាការកំពូលបានផ្តល់មកឲ្យខាងមេធាវីការពារជនជាប់ចោទនោះ ក៏វាច្រើនជាងគេទៀតតាមពិតទៅ ឲ្យពន្យល់ពីកថាខណ្ឌ១២ កថាខណ្ឌ-- ឲ្យពន្យល់ច្រើនកថាខណ្ឌមែនទែន ១២, ៦១, ៦២ ដល់កថាខណ្ឌ១០០ ហើយនិងឆ្លើយតបនូវសារណារបស់សហព្រះរាជអាជ្ញាទៀត។ ហើយការឆ្លើយតបហ្នឹង បើសិនជាមានការឆ្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញាតាមបង្គាប់របស់តុលាការកំពូល ដែលមិនមែនជាជំហររបស់សហមេធាវីការពារជនជាប់ចោទនោះទេ វាត្រូវការពេលវែង។ ហើយទម្លាប់ឲ្យនិយាយយឺតនេះវាមានបញ្ហាដែរ តែបើយើងខ្ញុំនិយាយលឿនពេកគេក៏បកប្រែមិនទាន់។

[១១:០០:៣៧]

ប៉ុន្តែអ៊ីចឹងទេ ខ្ញុំបាទសូមសំណូមពរថា ក្នុងករណីចាំបាច់ខ្លះ សុំផ្តល់ឯកសារដែលខ្ញុំបាទបានផ្តល់ទៅដល់អ្នកបកប្រែហើយនោះ សុំបញ្ចូលទៅក្នុងសំណុំរឿងតែម្តងបានទេ? ប្រសិនជាអាចបាន ពីព្រោះថា ការដាក់បែបបទសុំបញ្ចូលទៅក្នុងសំណុំរឿងនេះ ត្រូវបានតុលាការកំពូល ខាងក្រឡាបញ្ជីបានផ្តល់ដំណឹងថាមិនចាំបាច់។ តែកាលណាមិនចាំបាច់អ៊ីចឹង ឲ្យអានតែមាត់ទទេខ្លាចគាត់មានបញ្ហាអ៊ីចឹង

ដូចខាង អាយ.ធី.យូ គាត់និយាយអ៊ីចឹងថា អាចវាបកប្រែមិនទាន់ ហើយកាលណាតែការបកប្រែមិនទាន់ បញ្ហានៅទីនេះមានពណ៌ស្រអាប់ គឺវាមិនមានតម្លាភាព។ ចួនកាលមេធាវីត្រូវលើកទឡ្ហីករណ៍សំខាន់ៗសម្រាប់ជាមូលដ្ឋានដល់តុលាការកំពូលក្នុងការពិចារណា ប៉ុន្តែត្រូវបានអាក់ខាន ឧបសគ្គនោះគឺបញ្ហាបកប្រែ មិនមែនជាសមត្ថភាពរបស់មេធាវីទេ។ នេះជាបញ្ហាដែលត្រូវគិត។

[១១:០១:២៧]

ដូច្នេះ បើសិនជាអនុញ្ញាតឲ្យពួកខ្ញុំដាក់ជូននូវសេចក្ដីពន្យល់កថាខណ្ឌ តាមតែលោកប្រធានតុលាការកំពូលបានបញ្ជានោះ ខ្ញុំបាទសូមដាក់មុនពេលអង្គសវនាការបានបើកឡើងនៅថ្ងៃ២៨ នេះបាទ ដាក់ជូនជាភាសាអង់គ្លេស ដែលក្រុម អាយ.ធី.យូ បានជួយបកប្រែហើយហ្នឹង គឺដាក់ជូននៅក្រឡាបញ្ជីតែម្ដង ហើយពួកខ្ញុំប្រហែលជាអាននិងពន្យល់ខ្លះៗ ដើម្បីដាក់កំណត់គោរពតាមម៉ោង និងតាមបទបញ្ជារបស់តុលាការកំពូល។ បាទ, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ទាក់ទងនឹងបញ្ហានេះគឺ ខ្ញុំ បើខ្ញុំស្ដាប់មិនច្រឡំទេ គឺស្អីដែលលោកមេធាវីចង់ធ្វើសេចក្ដីថ្លែងនៅថ្ងៃទី២៨ នៅក្នុងពេលសវនាការហ្នឹង អ៊ីចឹងគាត់លោកធ្វើជាលាយលក្ខណ៍អក្សរហើយ ហើយចង់ដាក់មកខាងតុលាការកំពូលអ្ហ្នា? មានន័យអ៊ីចឹងអ្ហេ?

[១១:០២:០០]

បាទ, សូមអញ្ជើញលោកស្រីមេធាវី។

**លោកស្រី អេលីហ្សាប៊េត រ៉ាបេសាន់ដ្រាតាណា៖**

ខ្ញុំសូមធ្វើអន្តរាគមន៍ ធ្វើការកត់សម្គាល់មួយចំនួនទាក់ទងទៅនឹងបទពិសោធន៍ នៃការជម្រះសេចក្ដីរឿង០០១ នេះ។ ខ្ញុំអាចនិយាយបានថា មានការភាសាផ្លូវការជាបី បីភាសា គឺ ភាសាអង់គ្លេស ភាសាបារាំង ហើយនិងភាសាខ្មែរ។ ក៏ពុំមានការបកប្រែដោយផ្ទាល់ពី ខ្មែរទៅបារាំង នោះទេ។ កាលពីសំណុំរឿង០០១នេះ គឺជាបញ្ហាស្មុគស្មាញមួយ ពីព្រោះថា កាលនោះមានជាញឹកញយនូវការសុំឲ្យកែប្រែ ហើយនិងការបញ្ជាក់ឲ្យច្បាស់លាស់ទាក់ទងនឹងការបកប្រែនេះ ពីព្រោះថាមានការបកប្រែមិនសូវត្រូវចំៗ។ ឧទាហរណ៍ដូចជា ការបកប្រែរវាងភាសាបារាំង ហើយនិងភាសាអង់គ្លេស។

[១១:០៣:៥២]

ដូច្នេះ ខ្ញុំសូមដោយគោរព ចាប់ពីពេលនេះទៅសូមចង្អុលបង្ហាញទៅដល់អង្គជំនុំជម្រះថា ការ

សម្រាកនិយាយឈប់ពេក សម្រាកបន្តិចៗនេះជាការចាំបាច់ណាស់ ពីព្រោះថានៅពេលដែលចោទសំណួរ គឺថានៅពេលដែលការបកប្រែនោះ នៃចម្លើយបកជាភាសាបារាំងនោះ បន្ទាប់ពីបានគេបកប្រែជាភាសាអង់គ្លេស ហើយនោះ វាជាទៅៗ-- ពេលមកដល់-- ពេលដែលបកប្រែមកនោះ គេចូលដល់សំណួរបន្ទាប់បាត់ទៅហើយ ហើយយើងមិនទាន់ការបកប្រែជាផ្លូវការជាភាសាបារាំងនោះផង។

ដូច្នេះ ខ្ញុំដឹងអំពីកំហិតពេលវេលា ដែលបានលើកឡើងដោយភាគីការពារក្តី។ ក៏ប៉ុន្តែ ខ្ញុំគិតថាវាមិនចាំបាច់នោះទេក្នុងការគោរពលើថា រឿងសំណួរនិងចម្លើយរាល់ដងនោះ ហើយនិងការឈានចូលទៅសំណួរបន្ទាប់មកទៀតនោះ ដើម្បីឲ្យការបកប្រែជា ភាសាបារាំង នោះមានលក្ខណៈគ្រប់គ្រាន់។

[១១:០៥:00]

ហើយយើងមិននិយាយនៅពេលដែលថា ការបកប្រែជាភាសាបារាំងមិនទាន់បកហើយនោះ នេះគឺជាការកត់សម្គាល់ដោយគោរពដែលកើតចេញពីការបទពិសោធន៍របស់ខ្ញុំ កើតពីសំណុំ០០១ ហើយយើងមិនចាំឃាត់មិនឲ្យគេនិយាយរាល់ដងនោះទេ។

**ប្រធានអង្គជំនុំ៖**

អានេះគឺជាបញ្ហាមួយដែរ ដែលយើងកើតក្នុងសាលាក្តីខ្មែរក្រហមរបស់យើង គឺទាក់ទងបញ្ហាការបកប្រែផ្ទាល់ពីខ្មែរទៅបារាំងនេះ។ គឺធ្វើម៉េចគឺនៅក្នុងស្ថានភាពរបស់យើងនេះ យើងមិនអាចរកអ្នកបកប្រែបាន។ ដូច្នេះហើយគឺមានការលំបាក។ អ៊ីចឹងហើយ គឺការដែលនិយាយថ្លែងឡើង គឺវាត្រូវមានការឆ្លងកាត់ភាសាពីខ្មែរទៅអង់គ្លេស ហើយពីអង់គ្លេសទៅបារាំង។ អានេះគឺជាការឆ្លងកាត់ពីរបីភាសាហើយ ដូច្នេះហើយមានការលំបាក។

[១១:០៥:0៤]

អ៊ីចឹង គឺដើម្បីឲ្យមានការបកប្រែហ្នឹង ធ្វើទៅដោយត្រឹមត្រូវទៅតាមពាក្យពេចន៍ភាសានោះ គឺគួរតែមានការនិយាយហ្នឹងគឺមួយៗហើយ ប៉ុន្តែជាទូទៅវាអាស្រ័យទម្លាប់របស់មនុស្សទៀតផង។ គឺអ្នកខ្លះហ្នឹង កាលណាធ្លាប់និយាយលឿន ហើយបើសិននិយាយមួយៗ និយាយមិនចេញទៅវិញក៏មានដែរ ហើយអ្នកខ្លះគឺនិយាយច្រើនតែមួយៗអ៊ីចឹង បើនិយាយញាប់ ក៏និយាយមិនចេញដែរ។ អានេះវាជាលក្ខណៈចរិត វាកើតចេញពីចរិត។ ប៉ុន្តែទោះជាយ៉ាងណានេះក្តី ខ្ញុំសូមសំណូមពរធ្វើយ៉ាងណា សូមឲ្យគឺ-- ខ្ញុំហើយជាអ្នកនិយាយញាប់ជាងគេ ដូចលោកប្រធាន និល ណុន អ៊ីចឹង គឺគាត់-- លោកនិយាយញាប់ណាស់។ ហើយអ៊ីចឹងគឺមានការកែ ខ្ញុំក៏កែដែរ គឺកែមកនិយាយយឺតៗដើម្បីធ្វើយ៉ាងម៉េច គឺស្ថិតនៅ

ក្នុងស្ថានភាពមួយដែលយើងត្រូវតែហាត់ពត់ការនិយាយរបស់យើង ធ្វើយ៉ាងម៉េចវាស្របទៅនឹងពេលវេលា ស្របនឹងទីកន្លែងផង។

[១១:០៧:០១]

អ៊ីចឹងហើយបានខ្ញុំ-- ឥឡូវនេះ ខ្ញុំនិយាយយឺតៗជាងមុន ប៉ុន្តែពិបាកបន្តិចដែរ ខ្ញុំសូមជម្រាបកាលណាៗនិយាយយឺត វាដូចអាការនឹកឃើញ អាស្ទីចង់និយាយតទៅមុខ ច្រើនតែដាច់ៗ។ អ៊ីចឹងហើយអានេះវាលំបាកបន្តិច គ្រាន់តែថាសុំធ្វើការព្យាយាមថា សុំឲ្យនិយាយរៀងយឺតបន្តិចដើម្បីងាយស្រួលដល់អស់លោកខាងបកប្រែ ធ្វើម៉េចគឺថាការបកប្រែគាត់ចង់ធ្វើម៉េចឲ្យបានស្របទៅនឹងពាក្យពេចន៍ដែលគាត់ត្រូវបកឲ្យចំហ្នឹងតែម្តង បើមិនអ៊ីចឹងទេគាត់ពិបាកណាស់។ ដូចជាការនិយាយទៅ មិនទាន់ផ្អាកបន្តិចផង ស្រាប់តែនិយាយបន្តទៅទៀត។ ដូច្នេះ គាត់ពិបាកក្នុងការតាមដាន ឬអ្នកដែលនិយាយក្រោយហ្នឹងណាស់។

[១១:០៧:៤៣]

អ៊ីចឹងសំណូមពរធ្វើម៉េច គឺសុំឲ្យនិយាយយឺត។ ហើយខ្ញុំសូមសំណូមពរដែរ បើសិនជាមានការនិយាយទៅវារៀងលឿនបន្តិច ហើយអ្នកបកប្រែគេផ្តល់សញ្ញាឲ្យខ្ញុំ គឺខ្ញុំសូមទោសដែរ គឺថាសូម-- ខ្ញុំសូមកាត់ធ្វើម៉េចគឺសូមឲ្យលោកហ្នឹង គឺសូមឲ្យនិយាយយឺតឡើងវិញ។ អានេះគឺជាការរំឭកទេ មិនមែនជាការដាក់ពិន័យ ឬការព្រមានអីទេ គឺគ្រាន់តែជាការរំឭក ថាធ្វើម៉េចដើម្បីឲ្យបានស្តាប់បាននូវខ្លឹមសារឲ្យត្រឹមត្រូវតែប៉ុណ្ណឹងទេ គឺក្នុងគោលបំណងល្អទេ។ សូមអរគុណដែរ។

អស់លោកមានយោបល់អីទៀតទេ ទាក់ទងបញ្ហាខាងបកប្រែនេះ?

បាទ, សូមអញ្ជើញលោកស្រីចៅក្រម។

[១១:០៨:៤៩]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តាមការពិភាក្សានៅក្នុងអង្គជំនុំជម្រះតុលាការកំពូល យើងមិនសង្ឃឹមថាភាគីនឹងដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែម ឬកំណត់សំគាល់បន្ថែមនោះទេ យើងស្វាគមន៍ប្រសិនបើចង់ធ្វើដូច្នោះ។ ឧបសម្ព័ន្ធដែលបានផ្តល់ជូននៅក្នុងកំណត់ហេតុនៃឯកសារបណ្តឹងសាទុក្ខនោះ យើងដឹងហើយថាភាគីមានបំណងក្នុងការដាក់សេចក្តីសង្ខេបទៅលើសេចក្តីសន្និដ្ឋានដើមរបស់ខ្លួន អមជាប់ទៅនឹងឯកសារទាំងឡាយ។ យើងនឹងទទួលចំពោះកំណត់សំគាល់ជាលាយលក្ខណ៍អក្សរទាំងអស់នោះ ដែលខ្លួនយល់

ឃើញថាចង់ដាក់ជូន ហើយផ្ដល់ជូនជាមុនខាងអង្គភាពបកប្រែ ក្នុងគោលបំណងជួយសម្រួលនៃការផ្ដល់ និងការបកប្រែទៅជាភាសាឲ្យត្រឹមត្រូវ។ យើងខ្ញុំស្វាគមន៍។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា។

[១១:១០:០៦]

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។

កម្មវត្ថុនៃបណ្ដឹងសាទុក្ខនៅក្នុងសវនាការនូវអាទិត្យក្រោយនេះ វាពាក់ព័ន្ធទៅនឹងយុត្តិសាស្ត្រពីតុលាការអន្តរជាតិជុំវិញពិភពលោក។ ចំណុចសំខាន់ដែលខ្ញុំគិតថា អាចធានាថា អ្នកច្បាប់ទាំងអស់គ្នានេះនៅទីនេះ ជាពិសេសនៅដែលយោងទៅលើករណីយុត្តិសាស្ត្រទាំងឡាយនៅក្នុងសាលាក្ដីអន្តរជាតិនានានោះ។ ដូចដែលយើងបានពិភាក្សាហើយ ការបកប្រែទៅជាភាសានិងតាមរយៈការបកប្រែបន្តនេះ ខ្ញុំសូមបញ្ជាក់អ៊ីចេះថា រឿងក្ដីដែលលើកឡើងពីតុលាការនានានោះ គឺយើងគួរតែបញ្ជាក់ ជាពិសេសសម្រាប់ឲ្យលោក លោកស្រីចៅក្រមពិនិត្យមើលប្រតិចារឹកនៅពេលក្រោយនោះ គឺយើងស្នើសុំថាឲ្យភាគីធ្វើការប្រកបឈ្មោះផងដែរ លើកចំណុចយោង លេខទំព័រ ហើយនិងសាលក្រម ឬសាលដីកាដាក់លាក់និងថ្ងៃចេញសាលដីកា សាលក្រមទាំងអស់នោះ។

[១១:១១:១៦]

ខ្ញុំគិតថា ទោះបីជាអ្នកច្បាប់ សហព្រះរាជអាជ្ញា ចៅក្រម ឬភាគីទាំងអស់មិនផ្ដល់កំណត់សម្គាល់ជាលាយលក្ខណ៍អក្សរក៏ដោយ ការផ្ដល់លេខយោង ថ្ងៃកំណត់សម្គាល់ អ៊ីចឹងគឺវាមានសារៈសំខាន់។ ដូច្នេះ ហើយពេលខ្លះទៅ យើងដឹងថាវាមានការពិបាកដែរ ដែលយើងនិយាយចេញពីឯកសារដែលរៀបចំរួចរាល់ជាស្រេចនោះ។ នៅពេលដែលយើងក្រោកឈរ ហើយយើងនិយាយទៅតាមកំណត់សម្គាល់ ហើយយើងដឹងថាវាជាចំណុចសំខាន់និងចាំបាច់សម្រាប់យើង។ ប៉ុន្តែ ប្រតិចារឹកដែលកត់ត្រានៅក្នុងនោះ វាហ្នឹងកំណត់សម្គាល់បញ្ជាក់នូវអ្វីដែលយើងបានលើកឡើងយ៉ាងច្បាស់លាស់។

ដូច្នេះ ខ្ញុំគិតថា យើងឲ្យភាគីផ្ដល់ជាលេខយោង លេខទំព័រ ឬក៏កំណត់សំគាល់នៅលើសាលក្រមដើម្បីឲ្យយើងមាននៅក្នុងប្រតិចារឹក។ សូមអរគុណ។

[១១:១២:១៤]

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ពាក់ព័ន្ធទៅនឹងការលើកឡើងរបស់ខាងសហព្រះរាជអាជ្ញាអន្តរជាតិ ខ្ញុំនៅមានចម្ងល់ផងដែរ ថាតើយើងធ្វើបានដែរឬទេ ប្រសិនបើយើងយោងទៅលើលេខយោងជើងទំព័រនៅក្នុងសេចក្តីសន្និដ្ឋានដើម ក្នុងករណីដែលលោកចង់លើកឡើងយុត្តិសាស្ត្រអន្តរជាតិ។ ខ្ញុំគិតថា រឿងក្តីភាគច្រើនដែលលោកលើកឡើងនៅក្នុងអាទិត្យក្រោយនេះ គឺបានសរសេរយោងនៅក្នុងសេចក្តីសន្និដ្ឋានរបស់លោករួចទៅហើយ។ ដូច្នេះ ប្រសិនបើយើងលើកឡើងតែលេខយោង ឬក៏ចំណងជើងនៃឯកសារ។ល។ នោះជាពិសេសលេខយោងជើងទំព័រនោះ ជាជាងការប្រកបឈ្មោះពេញលេញនិងលម្អិតនោះ ថាតើបើធ្វើអ៊ីចឹងទៅ គិតថាបានទេ?

[១១:១៣:១៧]

**លោក អាន់ឌ្រូ ខេលី៖**

ខ្ញុំគិតថា វាអាចធ្វើទៅបាន ប៉ុន្តែក្នុងលក្ខណៈកម្រិត។ ខ្ញុំនឹងព្យាយាមធ្វើដូច្នេះ។ ប៉ុន្តែយើងចាំថា នៅពេលដែលអង្គជំនុំជម្រះចោទជាសំណួរមួយចំនួនទៅកាន់ភាគី ពេលខ្លះទៅវាអាចនាំឲ្យមានការពាក់ព័ន្ធទៅនឹងរឿងក្តី និងលេខយោងនៅក្នុងឯកសារទាំងអស់នោះ។ ជាការពិត ដើម្បីជាការសម្រួលទៅលើការយោងដូច្នេះនោះ គឺយើងខ្ញុំអាចធ្វើការពិនិត្យមើលសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ហើយយើងខ្ញុំធ្វើទៅតាមហ្នឹង។ ខ្ញុំអាចធ្វើតាមទាំងពីរវិធីនេះតែម្តង។

ខ្ញុំសូមបញ្ជាក់លោកចៅក្រម ណូហ្គូជិ ថា ខ្ញុំនឹងធ្វើការយោងទៅលើយុត្តិសាស្ត្រទាំងអស់នោះក្នុងលក្ខណៈមួយមិនច្រើនទេ។ សូមអរគុណ។

[១១:១៤:២៧]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ដោយសារយើងអត់មានបញ្ហាអីទាក់ទងនឹងបញ្ហា អាយ.ធី.យូ នេះទៀតទេ គឺសូមឆ្លងចូលដល់របៀបវារៈមួយទៀត។ គឺរបៀបវារៈទីបួន គឺសំណើដាក់ភស្តុតាងបន្ថែម ហើយនៅក្នុងនោះគឺមានជនជាប់ចោទហើយនិងដើមបណ្តឹងរដ្ឋប្បវេណី។

ហើយទន្ទឹងនឹងនេះ គឺខ្ញុំខាងអង្គជំនុំជម្រះតុលាការកំពូលហ្នឹង យើងបានធ្វើការពិភាក្សាអំពីបញ្ហាសំណើដាក់បន្ថែមនូវភស្តុតាងនេះ។ ប៉ុន្តែ គ្រាន់តែថាសេចក្តីសម្រេចរបស់យើង យើងមិនទាន់ធ្វើចេញនៅឡើយទេ ហើយអង្គជំនុំជម្រះសូមជម្រាបដល់ភាគីទាំងអស់ថា នៅក្នុងអាទិត្យគឺយើងនឹងចេញ

សេចក្តីសម្រេចទាក់ទងនឹងបញ្ហាសំណើសុំដាក់ភស្តុតាងបន្ថែមនេះហើយ។ មិនឲ្យហួសអាទិត្យហ្នឹងទេ ប្រហែលជាស្អែក ខានស្អែកនេះ យើងអាចចេញបាន។ ហើយប្រសិនអស់លោកមានបញ្ហាអីទាក់ទងនឹងបញ្ហាសំណើសុំដាក់ភស្តុតាងបន្ថែមទៀត គឺសូមអញ្ជើញលើកឡើង។

បាទ, សូមអញ្ជើញលោកមេធាវី។

**លោក កង ឫទ្ធារី៖**

បាទ, ដោយសារតែភាគីខាង--

សូមគោរពឯកឧត្តមប្រធាន។ ខ្ញុំបានយល់ស្របចំពោះការលើកឡើងជារបៀបវារៈក្នុងការដាក់សំណើសុំដាក់ភស្តុតាងបន្ថែមនេះ ពីព្រោះថាភាគីខាងសហមេធាវីខ្ញុំបាទនេះ បានដាក់ភស្តុតាងពីរទៅចូលទៅក្នុងតុលាការកំពូលដើម្បីពិនិត្យឡើងវិញ។ ហើយភស្តុតាងអស់នេះ វាមានសារប្រយោជន៍ណាស់ជាភស្តុតាងដោះបន្ទុក ដែលខកខានមិនត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតទេ។ ដូច្នេះប្រសិនបើមានការទាត់ចោលណាមួយចំពោះការដាក់ភស្តុតាងថ្មីនេះ វារំលោភបំពានលើមាត្រា៥៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាហើយ។ នេះគ្រាន់តែជាការរំឭកទេបាទ។ ហើយថាការដាក់ភស្តុតាងថ្មីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបាទពិភាក្សា សូមផ្តល់យោបល់ថា គួរគប្បីទាត់ចោល ពីព្រោះថានោះជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាទេ មិនមែនជាកាតព្វកិច្ចតាមផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។ សូមអរគុណ។

[១១:១៦:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា ជា លាង។

**លោកស្រី ជា លាង៖**

សូមគោរពអង្គប្រជុំសាជាថ្មីម្តងទៀត។

អ្វីដែលខ្ញុំបានស្តាប់អំម្បាញ់មិញនេះ គឺលោកប្រធានបានលើកឡើងអំពីការបង្ហាញភស្តុតាង និងមានបំណងចេញសេចក្តីសម្រេចតែម្តង។ ដូច្នេះ អ្វីដែលយើងបានគិតគ្នាជាមួយនឹងខាងសហព្រះរាជអាជ្ញានេះ ការប៉ាន់ស្មានរបស់យើងគិតថា នឹងមានការផ្តល់យោបល់នៅពេលប្រជុំនេះ។ ប៉ុន្តែ ប្រសិនជាអង្គជំនុំជម្រះតុលាការកំពូលថា នឹងចេញសេចក្តីសម្រេចនៅពេលក្រោយ សហព្រះរាជអាជ្ញានឹងសុំដាក់សំណើ ឬក៏មានការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរទៅលើឯកសារទាំងឡាយដែលខាងមេធាវី

ការពារជនជាប់ចោទនេះ នៅពេលឆាប់ៗនេះ នៅមុនសវនាការនៅតុលាការកំពូល។ ដោយសារយើងមានបំណងចង់ពន្យល់ ឬក៏មួយចង់ឲ្យជាយោបល់ទៅលើឯកសារទាំងអស់ដែលមេធាវីការពារក្តីហ្នឹងដែលបានដាក់នៅក្នុងសំណើរឿង។ អានេះជាសំណួមពរ។ ចាស៎, សូមអរគុណ។

[១១:១៨:២០]

**ប្រធានអង្គជំនុំ៖**

ជាទូទៅ គឺខ្ញុំគិតកត់សំគាល់ឃើញថា នៅពេលដែលភាគីមួយបានដាក់សំណើមក ហើយខាងភាគីហ្នឹង គាត់តែងតែបញ្ជូនឯកសារហ្នឹងទៅឲ្យភាគីដទៃទៀត ដែលពាក់ព័ន្ធ។ អ៊ីចឹង ភាគីដទៃទៀត គឺមានសិទ្ធិក្នុងការឆ្លើយតបទៅនឹងសំណើផ្សេងៗមកដែរ។ ដូច្នេះ បើសិនជាខាងសហព្រះរាជអាជ្ញាមានបំណងនឹងដាក់សារណាឆ្លើយតបទៅនឹងសំណើរបស់ភាគី គឺសូមដាក់ឲ្យបានមុនពេលដែលអង្គជំនុំជម្រះយើងធ្វើការសម្រេច។ ហើយមិនអ៊ីចេះទេ យើងមិនអាចទទួលយកបានទេ។ អ៊ីចឹង សូមសហព្រះរាជអាជ្ញាហ្នឹង យើងអាចដាក់ឲ្យបានលឿនមក។

**លោកស្រី ជា លាង៖**

អង្គជំនុំជម្រះមានបំណងសម្រេច សម្រេចមុនថ្ងៃ២៨ ឬយ៉ាង-- មុនថ្ងៃបើកសវនាការ ឬមួយយ៉ាងម៉េច? ដោយសម្រេចទៅលើឯកសារភស្តុតាងថ្មីបន្ថែមនេះ។

[១១:១៩:១៥]

**ប្រធានអង្គជំនុំ៖**

បាទ, ខ្ញុំ ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹង គឺថាសំណើវាមានខាងដើមបណ្តឹងរដ្ឋប្បវេណី និងសំណើរបស់ខាងជនជាប់ចោទដែលសុំដាក់ភស្តុតាងថ្មី ហើយសំណើនេះយើងខ្ញុំនឹងពិភាក្សា និងសម្រេចចេញជាដីកាសម្រេចថា ទទួលយក ឬមិនទទួលយក។ អ៊ីចឹងហើយបើសិនជាខាង-- នៅក្នុងអាទិត្យនេះមានន័យថា មុនៗថ្ងៃ២៨ មុនថ្ងៃ២៨។ ដូច្នេះ បើសិនជាខាងសហព្រះរាជអាជ្ញាមានបំណងនឹងដាក់ គឺសូមដាក់ឲ្យបានឆាប់។ បាទ, ប៉ុណ្ណឹង។

បាទ, សូមអញ្ជើញលោកស្រីមេធាវី។

[១១:១៩:៥៩]

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្គី៖**

សូមអគុណលោកប្រធាន។ ខ្ញុំសូមទាញការចាប់អារម្មណ៍ពីអស់លោក លោកស្រីលើឯកសារ

F20 ដែលវាពាក់ព័ន្ធទៅនឹងដីកាកំណត់កាលបរិច្ឆេទសវនាការ។

នៅក្នុងចំណុច៥ ចែងអំពីដើមបណ្តឹងរដ្ឋប្បវេណី ចំណុច(ក) បានលើកឡើងថា៖ “ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់ភស្តុតាងបន្ថែម” ហើយក៏សូមឲ្យយើងធ្វើការលើកឡើងហេតុអ្វីបានជាភស្តុតាងទាំងអស់នោះមិនមាននៅក្នុងពេលជំនុំជម្រះ។

យោងតាមដីកាកំណត់កាលបរិច្ឆេទសវនាការនេះ គឺបានជូនដំណឹងនូវថ្ងៃទី៤ ខែមីនា។ យោងតាមដីកានេះ យើងបានត្រៀមរៀបចំនូវសេចក្តីសន្និដ្ឋានរបស់យើង យើងកំពុងតែរៀបចំនូវសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ ហើយយើងក៏ចង់ធ្វើការពន្យល់អំពីការអញ្ជើញរបស់អង្គជំនុំជម្រះឲ្យធ្វើការបង្ហាញទៅលើចំណុចនេះ។

ដូច្នេះហើយ ខ្ញុំនៅពេលនេះយល់ឃើញថា អង្គជនុំជម្រះតុលាការកំពូលនឹងសម្រេចត្រឹមអាទិត្យនេះ លើភាពអាចទទួលយកបាននៃភស្តុតាងបន្ថែមនេះ ថាតើភស្តុតាងទាំងអស់នោះមាននៅពេលជំនុំជម្រះឬក៏យ៉ាងណា? ខ្ញុំនៅពេលនេះសូមលើកជាចម្ងល់ថា គឺថាវាស៊ីចង្វាក់គ្នាយ៉ាងម៉េចទៅនឹងការអញ្ជើញនៅក្នុង-- ដូចបានកំណត់នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការ យើងខ្ញុំព្យាយាមគោរពតាមទៅលើការអញ្ជើញឲ្យលើកឡើងនោះ។ ដូច្នេះហើយ ខ្ញុំសូមលើកឡើងថា ខ្ញុំសូមគោរពតាមនូវដីកាកាលបរិច្ឆេទនេះ ហើយយើងខ្ញុំនឹងផ្តល់ការឆ្លើយតបនៅពេលដែលលោកចៅក្រមសួរ ហើយនឹងគោរពទៅតាមសេចក្តីសម្រេចប្រសិនបើមានការសម្រេចបែបណានោះ។ សូមអរគុណ។

[១១:២២:១៣]

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ពាក់ព័ន្ធទៅនឹងបញ្ហានេះ យើងខ្ញុំជាអង្គជំនុំជម្រះបានពិភាក្សាគ្នាកាលពីម្សិលមិញ។ ជាការពិតដូចដែលបានគូសបញ្ជាក់នៅក្នុងដីកានោះ យើងបានអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីឲ្យធ្វើការបញ្ជាក់បំភ្លឺអំពីភស្តុតាងបន្ថែមនេះ ប៉ុន្តែក្រោយពេលដែលយើងចេញដីកាកំណត់កាលបរិច្ឆេទនៅថ្ងៃទី៤ ខែមីនា។ យើងបានទទួលនូវការពន្យល់លម្អិត តាមរយៈការសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

[១១:២២:៥៧]

ខ្ញុំគិតថា នៅពេលនេះអង្គជំនុំជម្រះទទួលបានព័ត៌មានលម្អិតចប់សព្វគ្រប់ គ្រប់គ្រាន់ហើយ ហើយយើងក៏យល់អំពីភាពចាំបាច់នៃភស្តុតាងទាំងអស់នេះ។ នេះគឺជាស្ថានភាពផ្លាស់ប្តូរមួយ។ អ្វីដែលយើងបានគិតគូរនោះ គឺអំពីភាពចាំបាច់សម្រាប់ភាគីទាំងអស់ឲ្យដឹងជាមុនថា តើសេចក្តីសន្និដ្ឋានបន្ថែម

ពាក់ព័ន្ធទៅនឹងភស្តុតាងបន្ថែមនោះនឹងអាចទទួលយកបានឬក៏យ៉ាងណា? ប្រសិនបើភាគីមិនដឹងជាមុនទទៅលើបញ្ហាហ្នឹង ភាគីនឹងធ្វើការចំណាយរយៈពេលច្រើននៅក្នុងពេលវេលាដែលយើងខ្ញុំបានកំណត់ហ្នឹង ធ្វើការបញ្ជាក់យុត្តិកម្មនូវភស្តុតាងបន្ថែមដែលចង់លើកឡើងនេះ។

[១១:២៤:០០]

ប្រសិនបើភាគីទាំងអស់បានដឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះជាមុននោះ ដូច្នេះពេលវេលាទាំងអស់ហ្នឹងអាចសន្សំសំចៃសម្រាប់ភាគីទាំងអស់ ហើយប្រសិនបើអង្គជំនុំជម្រះរបស់យើងខ្ញុំអាចសម្រេចជាមុននោះ គឺនៅពេលនោះយើងមិនធ្វើការស្តាប់នូវទឡ្ហីករណ៍ណាទាំងឡាយដែលមិនចាំបាច់ពាក់ព័ន្ធទៅនឹងភស្តុតាងដែលត្រូវបានបដិសេធចោលរួចទៅហើយនោះ។ នេះជាឧទាហរណ៍។

នៅពេលនេះ គឺយើងមានដីកាកំណត់កាលបរិច្ឆេទមួយដែលពិបាកដែរក្នុងការពន្យារពេលសម្រាប់ភាគីទាំងអស់ ហើយជាពិសេសដើម្បីសម្រាប់ពន្យាររយៈពេលធ្វើសេចក្តីសន្និដ្ឋាន។

[១១:២៤:៥០]

អង្គជំនុំជម្រះសង្ឃឹមថា សេចក្តីសម្រេចដែលនឹងធ្វើឡើងមុនពេលចាប់ផ្តើមសវនាការលើបណ្តឹងសាទុក្ខ ជាពិសេសសេចក្តីសម្រេចលើភស្តុតាងថ្មីនេះ នឹងអាចជួយពេញលេញទៅលើការលើកឡើងចំពោះអង្គសេចក្តី ហើយវាអាចបន្ថែមជាការបញ្ជាក់បំភ្លឺទៅលើភស្តុតាងបន្ថែមដែលនឹងដាក់នេះ។ ដូច្នេះអង្គជំនុំជម្រះពិចារណាទាំងផលប្រយោជន៍ និងផលវិបាកទៅលើភស្តុតាងថ្មីនេះ ហើយអង្គជំនុំជម្រះបានសម្រេចក្នុងផលប្រយោជន៍ពាក់ព័ន្ធទៅនឹងភស្តុតាងបន្ថែមទាំងអស់នេះ ឬក៏ភស្តុតាងដែលវាអាចជាន់គ្នា វាអាចជាគុណវិបត្តិសម្រាប់យើង។

អ្វីដែលខ្ញុំលើកឡើងនេះ ក៏ជាការចង់លើកឡើងពីលោកប្រធានដូច្នេះផងដែរ។ សូមអរគុណ។

[១១:២៥:៥៦]

**លោកស្រី ស៊ីលយ៉ស្ទត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតជម្រាបជូនអស់លោក លោកស្រីចៅក្រមថា មានតែក្រុមទីមួយ និងទីពីរនៃដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះដែលត្រូវបានអង្គជំនុំជម្រះអញ្ជើញតាមរយៈក្រឡាបញ្ជី។ ឲ្យក្រុមទីមួយ និងទីបី ធ្វើការដាក់សេចក្តីសន្និដ្ឋានលើការស្នើសុំដាក់ភស្តុតាងថ្មី។ នៅពេលនោះយើងខ្ញុំទទួលបានការចោទសួរថា តើវាជាកំហុស ឬក៏យ៉ាងណា? ហើយយើងក្រុមទីពីរនោះ ប្រសិនបើស្នើសុំនោះ គឺយើងនឹងដាក់ជូន។ ខ្ញុំអាចធ្វើការពិនិត្យមើលទៅលើអ៊ីម៉ែលវិញប្រសិនបើ

ចាំបាច់ នៅពេលនោះគឺខ្ញុំបានបញ្ជាក់ថាក្រុមទីពីរមិនទទួលបានការអញ្ជើញ-- មិនធ្វើការអញ្ជើញក្រុមទីពីរនោះទេ ហើយយើងអង្គជំនុំជម្រះមិនស្នើសុំយើងខ្ញុំឲ្យធ្វើការលើកឡើងបញ្ហាហ្នឹងនៅពេលសវនាការនោះឡើយ។ ករណីនេះ គឺកើតឡើងកាលពីពីរសប្ដាហ៍មុន តាមរយៈការឆ្លើយឆ្លងគ្នានៅក្នុងអ៊ីម៉ែល។

[១១:២៧:១៩]

ដូច្នេះនៅពេលនេះ ថ្ងៃដូចជាហាក់ដូចជាថ្ងៃចុងក្រោយហើយ ចំពោះក្រុមទីពីររបស់យើងខ្ញុំ វាជាការភ្ញាក់ផ្អើលមួយនៅពេលដែលយើងទទួលការជូនដំណឹងនូវថ្ងៃនេះ ជាថ្ងៃចុងក្រោយគឺថ្ងៃពុធ ដែលថាយើងមិនត្រូវបានទទួលឱកាសតាមរយៈដីកាកាលកំណត់កាលបរិច្ឆេទនេះ ក្នុងការលើកឡើងទៅលើបញ្ហានេះ។ ទោះបីជាខ្ញុំយល់ថា គុណប្រយោជន៍សម្រាប់ការជូនដំណឹងឲ្យយើងដឹងជាមុននេះ នៅមុនពេលសវនាការថា តើភស្តុតាងនោះទទួលបាន ឬមិនទទួលបាននោះជាសន្សំពេលវេលាសម្រាប់យើង។ យើងយល់ដូច្នោះ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំមានការស្ទាក់ស្ទើរក្នុងការស្នើសុំអង្គជំនុំជម្រះឲ្យពិចារណាថា យើងនៅពេលនោះត្រូវបានដកចេញមិនឲ្យលើកឡើងសេចក្ដីសន្និដ្ឋានរបស់យើងលើករណីហ្នឹង។ យើងដឹងហើយថា ក្រុមដទៃទៀតទទួលបានការអញ្ជើញពីអង្គជំនុំជម្រះឲ្យលើកការសន្និដ្ឋានលើករណីហ្នឹង។ សូមអរគុណ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ដោយមានការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមធ្វើការលើកឡើង-- ឆ្លើយតបទៅនឹងលោកស្រីស្ទួតហ្សីនស្គី។ លោកស្រី ស្ទួតហ្សីនស្គី យើងទទួលស្គាល់ថា យើងមានការយល់ច្រឡំច្របូកច្របល់ទៅលើបញ្ហាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដីកាកំណត់កាលបរិច្ឆេទ យើងគួរតែបញ្ជាក់ឲ្យបានមុនទៅលើបញ្ហាហ្នឹង។ ប៉ុន្តែយ៉ាងណាក៏ដោយ សូមកុំឲ្យមានការយល់ច្រឡំទៅលើបញ្ហាហ្នឹង។ យើងព្យាយាមដោះស្រាយទៅលើបញ្ហានេះដើម្បីកុំឲ្យមានគុណវិបត្តិ ឬក៏ដើម្បីជាប្រយោជន៍ទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ ហើយទើបយើងរង់ចាំដល់ពេលសវនាការនេះ។

[១១:២៨:១៥]

ក្នុងករណីដែលយើងអាចផ្ដល់ទទួលយកការលើកឡើងនិងការស្នើសុំនៅក្នុងសេចក្ដីសន្និដ្ឋាននោះគឺយើងនឹងធ្វើការសម្រេចទៅតាមហ្នឹង។

**លោកស្រី ស៊ីលយី ស្ទួតហ្សីនស្គី៖**

ខ្ញុំគិតថា នេះជាដំណោះស្រាយសម្រាប់យើងហើយ។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រីមេធាវី។

[១១:២៩:៤១]

**កញ្ញា ម៉ុច សុវណ្ណារី៖**

សូមគោរពលោកប្រធានអង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតឲ្យនាងខ្ញុំនិយាយ។ អ៊ីចឹង នៅក្នុងពេលនេះ គឺខ្ញុំចង់លើកឡើងជាសំណូមពរទាក់ទងជាមួយនឹងរបៀបនៃការបង្ហាញភស្តុតាងថ្មីនោះ។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសាលាកំពូលសម្រេចថាទទួលភស្តុតាងថ្មីនេះ ឬក៏ក្នុងករណីដែលមិនទាន់សម្រេច ហើយត្រូវសម្រេចនៅដំណាក់កាលនៃអង្គសេចក្ដីតែម្ដង។

[១១:៣០:០៨]

ដោយយោលទៅលើសារៈសំខាន់នៃការផ្ដល់ដំណឹងទៅដល់សាធារណជន ហើយនិងជួយសម្រួលទៅដល់លក្ខណៈនៃការពន្យល់និងបង្ហាញភស្តុតាង ដូច្នេះនាងខ្ញុំស្នើសុំអង្គជំនុំជម្រះតុលាការកំពូលផ្ដល់នូវជំនួយនៅក្នុងការធ្វើការបង្ហាញភស្តុតាងនោះ តាមរយៈមន្ត្រីតុលាការដើម្បីឲ្យសាធារណជនគាត់អាចបានដឹង ហើយគាត់អាចបានយល់ពីភស្តុតាងថ្មីនោះ។ ចាំ, នាងខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អំមិញនេះ គឺខ្ញុំសូមឆ្លើយតបបន្តិច។ គឺទាក់ទងទៅនឹងបញ្ហាសំណូមពរដល់អង្គជំនុំជម្រះឲ្យផ្ដល់ជំនួយតាមរយៈមន្ត្រីតុលាការហ្នឹង ខ្ញុំមិនយល់ទេ តើគួរតែពន្យល់ឲ្យបានជ្រាបបន្តិច គឺថាចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលហ្នឹងធ្វើរបៀបម៉េច? គឺអត់ទាន់យល់ទេអំមិញនេះ។ គឺសូមបញ្ជាក់ម្ដងទៀត។

[១១:៣១:០៩]

**កញ្ញា ម៉ុច សុវណ្ណារី៖**

ជំនួយដែលនាងខ្ញុំស្នើតាមរយៈមន្ត្រីតុលាការហ្នឹង ឧទាហរណ៍ដូចជា នៅក្នុងក្រុមរបស់នាងខ្ញុំបានដាក់នូវភស្តុតាងថ្មី ដូចជារូបភាព ឬឯកសារមួយចំនួន។ អ៊ីចឹង នាងខ្ញុំស្នើសុំឲ្យខាងមន្ត្រីតុលាការគាត់ជួយនៅក្នុងការបង្ហាញឯកសារនោះតាមរយៈឧបករណ៍ ឧទាហរណ៍ដូចជាមាននៅទីនេះ ដើម្បីឲ្យអេក្រង់ដែលសាធារណជនគាត់នៅខាងក្រៅ គាត់អាចបានមើលឃើញនូវឯកសារទាំងអស់ហ្នឹង ហើយជួយទៅដល់គាត់នៅក្នុងការយល់ឯកសារទាំងអស់ហ្នឹង ហើយក៏ដូចជាជួយដល់នាងខ្ញុំនៅក្នុងការពន្យល់ថាឯកសារហ្នឹងវាគឺមានសារៈសំខាន់យ៉ាងណា? ដើម្បីគាំពារដល់ពាក្យសុំតាំងខ្លួនរបស់ដើមបណ្ដឹងរដ្ឋ-

ប្បូណីដែលជាកូនក្តីរបស់ខ្ញុំ។ ចាំ, សូមអរគុណ។

[១១:៣១:៥០]

**ប្រធានអង្គជំនុំ៖**

លោកស្រីចង់ឲ្យជំនួយផ្នែកច្បាប់-- អ្ហ៎ុះ! ខាងមន្ត្រីច្បាប់របស់តុលាការកំពូលយើងនេះ នៅពេលដែលធ្វើសវនាការហ្នឹងជួយបង្ហាញនៅក្នុងអេក្រង់នៅលើឯកសារ ឬក៏ភស្តុតាងដែលលោកស្រីបានដាក់បន្ថែម អ៊ីចឹង?

អ៊ំមិញលោកមេធាវី សូមអញ្ជើញ!

[១១:៣២:១៧]

**លោក ការ សាវុត្ថ៖**

សូមគោរពឯកឧត្តមប្រធាន និងសូមគោរពអង្គប្រជុំ, អម្បាញ់មិញនេះ ឯកឧត្តមប្រធាន បានឲ្យខាងសហព្រះរាជអាជ្ញាដាក់ការឆ្លើយតបចំពោះភស្តុតាងថ្មីនេះឲ្យបានឆាប់ៗ។ ក៏ប៉ុន្តែ ខ្ញុំសុំឲ្យឯកឧត្តមប្រធានមេត្តាពិនិត្យលើវិធាន១០៨ ចំណុច(៧) នៅពីរបន្ទាត់ចុងក្រោយនៃអាចំណុច(៧) ហ្នឹង។ ព្រោះចំណុច(៧)ហ្នឹងក្នុងវិធានហ្នឹង គេបាននិយាយថា៖ "ភាគីផ្សេងទៀត ដែលរងការប៉ះពាល់ដោយសេចក្តីស្នើសុំនេះ អាចធ្វើការឆ្លើយតបក្នុងរយៈពេល១៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីស្នើសុំនោះ"។ ហើយភាគីយើងខ្ញុំបានស្នើសុំ គឺជាភាសាខ្មែរថ្ងៃ២៥ ខែ២ ២០១១ ហើយនៅថ្ងៃ២៨ ខែ២ ២០១១ បានបកប្រែជាភាសាអង់គ្លេសហើយ បានបញ្ជូនទៅខាងគ្រប់ភាគី។

ដូច្នេះ សូមឲ្យឯកឧត្តមប្រធានមេត្តាពិនិត្យមើល តើពីថ្ងៃដែលខ្ញុំជូនដំណឹងរហូតមកទល់ពេលនេះ តើផុតរយៈពេល១៥ថ្ងៃហើយឬនៅ? សូមលោកប្រធានមេត្តាពិចារណា។ សូមអរគុណ។

[១១:៣៣:៥០]

**ប្រធានអង្គជំនុំ៖**

បាទ, នេះគឺជាការពិនិត្យមើលដែរទាក់ទងទៅនឹងបញ្ហាពេលវេលាក្នុងការដាក់ឯកសារ មិនមែនថាអង្គជំនុំជម្រះគឺ-- ការទទួលយកមកពិនិត្យ ហើយដើម្បីសម្រេច មិនមែនថាឲ្យតែទទួលមកគឺអាហ្នឹងសុទ្ធតែត្រឹមត្រូវទាំងអស់ហ្នឹងទេ គឺមិនមែនមានន័យអ៊ីចឹងទេ។ អ៊ីចឹង គឺថាបើគាត់មានបំណងដាក់ធម្មតាគឺត្រូវគោរពតាមវិធាន ទៅតាមសេចក្តីណែនាំអនុវត្ត។ អ៊ីចឹងបើសិនបើមានការដាក់ទៅវាអាចលើសឬក៏ហួសពេលកំណត់ អ៊ីចឹងតុលាការក៏ត្រូវពិចារណាផងដែរ។ អ៊ីចឹងបានថា នេះគឺជាសំណូមពររបស់

ខាងមេធាវីការជនជាប់ចោទ និងសំណើសុំរបស់ខាង-- សំណើសុំឆ្លើយតបរបស់ខាងសហព្រះរាជអាជ្ញា។ អ៊ីចឹង អត់អីទេ ចាំអង្គជំនុំជម្រះនឹងធ្វើការពិនិត្យ ហើយនិងធ្វើការពិចារណា។

សូមអញ្ជើញលោកស្រីមេធាវី។

[១១:៣៤:៤៨]

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ ជាដំបូង ខ្ញុំសូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រមនៅក្នុងកិច្ចប្រជុំនេះ ហើយខ្ញុំឡើងមកនេះ ខ្ញុំមាន-- ខ្ញុំចង់ស្នើសុំឲ្យលោកប្រធានជួយបញ្ជាក់ទៅលើចំណុចមួយក្រែងលោនាងខ្ញុំស្តាប់មានការភ័ន្តច្រឡំ។ ទាក់ទងទៅនឹងអម្បាញ់មិញ លោកប្រធានបានលើកឡើងមុននឹងបន្តិច លោកប្រធានបានលើកឡើងថា នឹងអនុញ្ញាតឲ្យខាងការិយាល័យសហចៅក្រម-- អឺ!សហព្រះរាជអាជ្ញាដាក់នូវភស្តុតាងថ្មីបន្ថែម។ តើពិតជាអ៊ីចឹងមែន ឬក៏ម៉េច? ក្រែងលោខ្ញុំស្តាប់មានការភ័ន្តច្រឡំ ព្រោះអីបើសិនជាក្នុងករណីបែបហ្នឹងមែន នាងខ្ញុំសួរបន្តថា តើការកំណត់នេះធ្វើគឺចំពោះតែការិយាល័យសហព្រះរាជអាជ្ញា ឬក៏មួយចំពោះភាគីដទៃទៀតដែរ ដែលមានឱកាសក្នុងការដាក់ឯកសារបន្ថែមថ្មី មុននឹងខាងអង្គជំនុំជម្រះតុលាការកំពូលធ្វើការសម្រេចទៅលើសំណើថ្មីៗរបស់ភាគីផ្សេងៗទៀត ដែលបានស្នើសុំ។

សុំលោកប្រធានជួយបញ្ជាក់។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអរគុណ។ ហើយតាមពិតលោក-- លោកស្រីមេធាវីសូមបញ្ជាក់អំពីឈ្មោះផងក្រោយហើយសូមបញ្ជាក់ក្រុមមេធាវីផង ព្រោះខាងខ្ញុំហ្នឹងអត់ស្គាល់ទេ អត់ដឹងថាឈ្មោះអី? ហើយនៅក្រុមមួយ ក្រុមពីរ ឬក្រុមបីទេ? ដូច្នេះខ្ញុំអត់ទាន់ស្គាល់ទេ តាមពិតទៅ?

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។ អំមិញហ្នឹងខ្ញុំមានការភ្លេចភ្លាំងក្នុងការបង្ហាញឈ្មោះដែរ។ នាងខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីតំណាងឲ្យក្រុមមួយ។

[១១:៣៦:២៨]

**ប្រធានអង្គជំនុំ៖**

តាមពិតទៅ គឺទាក់ទងនឹងសំណើរបស់ខាងសហព្រះរាជអាជ្ញាអំមិញនេះ គឺវាមានបញ្ហាមួយ

គឺថា ខាងសហមេធាវីជនជាប់ចោទគាត់ចង់ដាក់ភស្តុតាងបន្ថែម ឯខាងដើមបណ្តឹងរដ្ឋប្បវេណីក៏មានបំណងនឹងសុំដាក់ភស្តុតាងបន្ថែមដែរ។ អ៊ីចឹងហើយខាងលោកព្រះរាជអាជ្ញាហ្នឹង គាត់លើកឡើងជាយោបល់ថា គាត់មិនទាន់បានដាក់នូវសារណាឆ្លើយតបទៅនឹងសំណើសុំដាក់ភស្តុតាងថ្មីបន្ថែមរបស់ខាងជនជាប់ចោទនោះទេ។ ដូច្នេះហើយគាត់មានបំណងនឹងដាក់សារណាបន្ថែម សារណាឆ្លើយតប មិនមែនសារបន្ថែមទេ សារណាឆ្លើយតបទៅនឹងសំណើសុំដាក់ភស្តុតាងថ្មីរបស់ខាងជនជាប់ចោទ ខាងសហមេធាវីជនជាប់ចោទ។ គឺមិនមែនមានន័យថាខាងសហព្រះរាជអាជ្ញាហ្នឹង គាត់ដាក់នូវភស្តុតាងបន្ថែមទៀតទេ។ មិនមែនមានន័យអ៊ីចឹងទេ។ ដូច្នេះ គ្រាន់តែជាការបញ្ជាក់ឲ្យបានច្បាស់ថា គាត់អត់មានសំណើសុំដាក់ភស្តុតាងថ្មីបន្ថែមទេគឺខាងសហព្រះរាជអាជ្ញាហ្នឹង។ គឺថាបើលោកស្រីច្បាស់ហើយសូម-- អឺ! បើមិនទាន់ច្បាស់ សូមអាចមានយោបល់បន្ថែម។

[១១:៣៧:៤៣]

**លោកស្រី ទី ស្រ៊ីនណា៖**

នាងខ្ញុំច្បាស់ហើយ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រី ជា លាង ។

**លោកស្រី ជា លាង៖**

ក្រោយពីបានស្តាប់ការផ្តល់យោបល់របស់ភាគីទាំងអស់ហ្នឹង ខ្ញុំហាក់ដូចជាចាប់អត់ទាន់បាន អ្វីដែលខ្ញុំបានលើកឡើងនិយាយអម្បាញ់មិញនេះ ខ្ញុំ-- ដោយផ្អែកទៅលើ *អាចេនដា* ដែលចែកឲ្យ។ គឺខ្ញុំមិនមនាបំណងដាក់ភស្តុតាងថ្មីទៀតទេ អានេះជាជំហររបស់ខ្ញុំ។ ប៉ុន្តែខ្ញុំមានបំណងកត់សម្គាល់ក្នុងការដែលឲ្យយោបល់។ ឧទាហរណ៍ថា ខាងមេធាវីជនជាប់ចោទ គាត់ដាក់ភស្តុតាងថ្មីប្រាំនៅ ក្នុងនោះដែលខ្ញុំសង្កេតមើល។ ហើយខ្ញុំឃើញនៅក្នុងនេះ ដែលខ្ញុំគិតថានៅពេលប្រជុំនេះនឹងមានការផ្តល់យោបល់របស់ភាគីនីមួយៗ។ អ៊ីចឹង ខ្ញុំរង់ចាំពេលហ្នឹងថា យើងគួរឲ្យយោបល់យ៉ាងដូចម្តេច នៅពេលប្រជុំចំពោះភាគីទាំងអស់ហ្នឹង អានេះជាការរង់ចាំរបស់ខ្ញុំ។

[១១:៣៨:៤៧]

អ៊ីចឹង សុំកុំឲ្យមានការច្រឡំថាមានបំណងភស្តុតាងថ្មី។ អ្វីដែលមេធាវីលើកឡើងអំមិញ ខ្ញុំមានការអត់ច្បាស់ខ្លួនឯង ខ្ញុំថាតើមេធាវីមានបំណងដាក់ភស្តុតាងថ្មីថែមទៀត ឬមួយក៏យ៉ាងម៉េច? ខ្ញុំដូចជា

មិនច្បាស់ចំពោះខ្លួនឯងទេឥឡូវហ្នឹង ខ្ញុំលើកអត់មានចង់ថា ឲ្យការផ្ដល់ភស្តុតាងថ្មីមានចេះជាបន្តបន្ទាប់នោះទេ។ គឺថាអ្វីដែលបានដាក់កន្លងមកហើយ គឺយើងត្រឹមចប់ប៉ុណ្ណឹង ហើយនូវការកត់សម្គាល់របស់ខ្ញុំ ហើយនឹងចង់យោបល់នៅពេលអង្គប្រជុំនេះថា អំពីភស្តុតាងប្រាំ ដែលមេធាវីការពារក្ដីដែលបានដាក់បញ្ចូលនេះ តើសហព្រះរាជអាជ្ញាយល់យ៉ាងម៉េច? ជាការផ្ដល់យោបល់ទេ អានេះជាការកត់សម្គាល់ ទោះបីការសម្រេចហ្នឹងជាអង្គជំនុំជម្រះរបស់តុលាការកំពូលមានសិទ្ធិក្នុងការសម្រេចទេ គ្រាន់ថាការឲ្យយោបល់។ អានេះសូមឲ្យមានបញ្ហាហ្នឹងឲ្យច្បាស់គ្នា ដោយសារស្ដាប់ទៅ ខ្ញុំដូចជាពិបាកបន្តិចហើយ អំមិញហ្នឹង ដូចចាប់អត់ទាន់អំមិញ។ ចាំ, សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤០:៥១]

**ប្រធានអង្គជំនុំ៖**

អឹចឹង សូមអញ្ជើញលោក គ្រីស្ដ។

**លោក គ្រីស្ទហ្វឺ ម៉ាក រីយានៈ**

សូមអរគុណលោកប្រធាន។ គេបានស្នើសុំឲ្យខ្ញុំចែករំលែកកាលបរិច្ឆេទទាក់ទងទៅនឹងសំណើនូវការផ្ដល់នូវការជូនដំណឹង សំណើស្ដីពីការផ្ដល់ជូនដំណឹង។ ជនជាប់ចោទបានស្នើសុំដាក់ គឺយើងដាក់ឯកសារF2/2។ ឯកសារ F2/2 គឺជាភាសាខ្មែរហ្នឹងបានដាក់នៅថ្ងៃទី២៥ ខែកុម្ភៈ ប៉ុន្តែមិនបានជូនដំណឹងរហូតមកដល់ថ្ងៃទី៩ ខែមីនា ទើបបានជូនដំណឹង។ ដូច្នេះ ខ្ញុំគិតថានឹងបានទទួលចម្លើយទៅនឹងការចង្អុលបង្ហាញឯកសារនេះហើយ។

ហើយសំណើជាភាសាអង់គ្លេសគឺនៅថ្ងៃទី២០ ខែកុម្ភៈ បានដាក់ថ្ងៃ២០ កុម្ភៈ រួចរាល់អស់ហើយជូនដំណឹងនៅថ្ងៃទី១១ ខែមីនា។ ហើយអនុលោមយោងតាមវិធាន១០៨(៧) គឺថាមានការឆ្លើយតបទៅនឹងសំណើសុំនេះ។

[១១:៤២:២៧]

លោក លោកស្រី ប្រហែលបានដឹងហើយ គឺថាសេចក្ដីណែនាំវិធានផ្ទៃក្នុងវិសោធនកម្មលើកទីប្រាំមួយនៅខែមីនា ថ្ងៃទី២ ប៉ុន្តែភាគីខ្លះមិនបានទទួលវិសោធនកម្មវិធានផ្ទៃក្នុងនេះរហូតមកដល់--ហើយខ្ញុំជម្រាបថាអង្គជំនុំជម្រះតុលាការកំពូលមិនទាន់បានសម្រេចទៅលើករណីពិសេសនេះនៅឡើយទេ ទាក់ទងទៅនឹងកាលបរិច្ឆេទ នៅពេលដែលរយៈពេល១៥ថ្ងៃត្រូវចាប់ផ្ដើមនៅថ្ងៃដែលអត្ថបទជាភាសា

អង់គ្លេសត្រូវបានជូនដំណឹងមក ឬក៏ថាអត្ថបទជាភាសាអង់គ្លេសត្រូវបានជូនដំណឹងមកនោះ។ ហើយប្រសិនជាតុលាការកំពូលលអនុញ្ញាត ខ្ញុំសូមចែករំលែកព័ត៌មានទាក់ទងទៅនឹងសំណើរបស់ភាគី។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៥:១៨]

**លោក គ្រីស្តូហ្វឺ ម៉ាក វីយ៉ាន៖**

លោកប្រធានខ្ញុំសូមបញ្ជូនថា រយៈពេល១៥ថ្ងៃ តើរយៈពេល១៥ថ្ងៃហ្នឹង ចាប់ផ្តើមនូវខែមីនា ទី ១១ នៅពេលដែលសំណើសុំជាភាសាអង់គ្លេសត្រូវបានជូនដំណឹងមករហូត ហើយខាង ក.ស.ព គាត់មានរយៈពេល១៥ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងសំណើសុំនេះ។

[១១:៤៦:០៥]

**ប្រធានអង្គជំនុំ៖**

លោកមានយោបល់ទេ? សូមអញ្ជើញលោកមេធាវី។

**លោក ការ សាវុត្ថ៖**

សូមគោរពឯកឧត្តមប្រធាន និងអង្គជំនុំជម្រះ។ ខ្ញុំសូមស្នើឲ្យលោកប្រធានមេត្តាពិនិត្យមើលសេចក្តីណែនាំអនុវត្តវិសោធនកម្មលើកទីប្រាំមួយត្រង់ចំណុច៨(៤)១ ពីព្រោះថាប្រសិនបើព្រះរាជអាជ្ញាសហព្រះរាជអាជ្ញាបានដាក់ពាក្យមកក្នុងសេចក្តី-- ភស្តុតាងថ្មីនោះ ព្រះរាជអាជ្ញាដាក់មក ខាងមេធាវីការពារក្តីនេះ ក៏មានសិទ្ធិឆ្លើយតបក្នុងរយៈពេលប្រាំថ្ងៃដែរ។ ហើយអ៊ីចឹង សូមឲ្យឯកឧត្តមប្រធានមេត្តាពិនិត្យ មានពេលប្រាំថ្ងៃឯណា ដល់ថ្ងៃសវនាការ២៨ ទៅហើយ។ នេះគ្រាន់តែខ្ញុំលើកឡើងដើម្បីឲ្យឯកឧត្តមប្រធានមេត្តាពិនិត្យនិងពិចារណា។ បាទ, សូមអរគុណ។

[១១:៤៧:១២]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងហើយបាន ខ្ញុំកំពុងតែពិចារណាជាមួយលោកចៅក្រមខាងអង្គជំនុំជម្រះតុលាការកំពូលនេះទាក់ទងទៅនឹងបញ្ហាពេលវេលានេះ។ យើងមិនមែនថាយកមកយើងសម្រេចទទួលយក ឬម៉េចទេ? គឺយើងយកមកពិចារណា។ ប៉ុន្តែ ខ្ញុំគ្រាន់តែមានយោបល់មួយថាតើខាងព្រះរាជអាជ្ញាដែលមានគោលបំណងនឹងដាក់នោះ គឺអាចដាក់នៅពេលណា? ពីព្រោះដូចគ្នាហើយ ព្រោះនៅថ្ងៃ២៨ យើងនឹងចាប់ផ្តើមសវនាការហើយ។ អ៊ីចឹងហើយគឺថា យើងហើយនិងតុលាការកំពូលយើងអត់ទាន់ចេញសេចក្តី

សម្រេចហ្នឹង។ អ៊ីចឹងហើយបានថា តើមានបំណងដាក់ហ្នឹង គឺចង់ដាក់ថ្ងៃណា?

[១១:៤៧:៥៧]

**លោកស្រី ជា លាង៖**

ខ្ញុំក៏មានបំណងថាចង់ឲ្យបានលឿនដែរ ពីព្រោះខ្ញុំក៏ត្រូវការសេចក្តីសម្រេចរបស់តុលាការកំពូល ដើម្បីក្នុងការសវនាការថ្ងៃ២៨ ហ្នឹងដែរ។ ដូច្នេះ ខ្ញុំនឹងព្យាយាមនៅធ្វើឲ្យហើយនៅប្រហែលជាចុងអាទិត្យនេះ ដោយសារតែបញ្ហាដែលពិបាក គឺពិបាកពីរភាសា។ ពីរភាសាធ្វើមួយហើយ ត្រូវចាំភាសាមួយទៀតដែលបកប្រែ អាហ្នឹងហើយដែលជាបញ្ហាចំពោះខ្ញុំ។ ខ្ញុំសព្វថ្ងៃ ខ្ញុំពិបាកណាស់អំពីភាសានេះ។

[១១:៤៨:៣១]

តាមជាទូទៅ គឺខ្ញុំបានពង្រាងហើយទៅហើយ ដែលខ្ញុំគិតថានឹងផ្តល់យោបល់នៅពេលប្រជុំឥឡូវនេះ។ ប៉ុន្តែ ដោយសារតុលាការកំពូលបានសម្រេចថានឹងចេញសេចក្តីសម្រេច ដូច្នេះយើងមិនដេញដោលក៏ត្រូវការ ការផ្តល់យោបល់ពេលនេះ ហើយខ្ញុំនឹងរៀបជាលាយលក្ខណ៍ជាអក្សរតែម្តង ហើយព្យាយាមធ្វើដល់ចុងអាទិត្យនេះ អានេះដូចដែលលោកមេធាវីគាត់ថាគាត់ត្រូវការពេល ខ្ញុំក៏ត្រូវការពេលដូចគ្នា។ ហើយដូចយើងដឹងថាពីការលំបាកភាសានោះ វាពិបាកណាស់។ ដូចឯកសារនេះខ្ញុំខាងខ្មែរបានទៅ គាត់ទើបថ្ងៃ១១ ខែ៣ ទើបបានទទួល អាហ្នឹងមិនដឹងគិតថាម៉េច អានេះជាការគិតរបស់ខ្ញុំ និងការព្យាយាមរបស់ខ្ញុំដើម្បីធ្វើឲ្យបានសម្រេចក្នុងការងារនេះ។ ចាំ, សូមអរគុណ។

[១១:៤៩:១៦]

**ប្រធានអង្គជំនុំ៖**

យើងខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងកាលវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលយើងដាក់រួចហើយ គឺថាថ្ងៃច័ន្ទ យើងនឹងធ្វើសវនាការហើយ។ ហើយដូច្នេះហើយ គឺយើងមិនរង់ចាំទៀតទេនូវពេលវេលាដែលអនុញ្ញាតឲ្យខាងព្រះរាជអាជ្ញាធ្វើដាក់ការ-- អឺ!ការដែលថាយោបល់ទៅលើសំណើនោះ។ ដូច្នេះហើយ គឺបើសិនជាគាត់អាច លោកសហព្រះរាជអាជ្ញាអាចដាក់ទាន់ គឺយើងខ្ញុំនឹងទទួលយកមកពិចារណា ប៉ុន្តែបើដាក់មិនទាន់ទេ យើងខ្ញុំនឹងសម្រេចហើយ។ អានេះគឺ ខ្ញុំសូមជម្រាបជាមុនអ៊ីចឹង ដើម្បីឲ្យការងារនេះយើងអាចប្រព្រឹត្តទៅតាមគម្រោងការងាររបស់យើង។

[១១:៥០:១០]

អ៊ីចឹង បញ្ហាការ សំណើសុំដាក់សារណា-- អ៎! ភស្តុតាងបន្ថែមនេះ គឺយើងអត់មានយោបល់

អីបន្ថែមពីហ្នឹងទៀតទេ គឺអត់មានទេ យើងឆ្លងចូលដល់របៀបវារៈមួយទៀត គឺបញ្ហាផ្សេងៗ។ គឺបញ្ហាផ្សេងៗនេះ យើងមានពីរគឺ៖

ក) គឺទាក់ទងនឹងសំណើសុំដកវិធានការការពារឯកសារ F23។ ហើយចំណុចមួយទៀតគឺសំណួររបស់ចៅក្រម ដែលយើងត្រូវធ្វើការពិភាក្សានៅពេលនេះដែរ។

[១១:៥០:៤៦]

ហើយខ្ញុំសូមជម្រាបផងដែរថា សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ គឺបានធ្វើសំណើមកអង្គជំនុំជម្រះតុលាការកំពូល សុំដកវិធានការការពាររបស់ខ្លួនចំពោះដើមបណ្ដឹងរដ្ឋប្បវេណី E2/62។ ហើយខាងអង្គជំនុំជម្រះ តុលាការកំពូលយើងក៏បានធ្វើពិភាក្សាហើយដែរ ប៉ុន្តែ គ្រាន់តែថាសេចក្ដីសម្រេចយើងមិនទាន់បានធ្វើនៅឡើយទេ។ ប្រហែលជាយើងអាចនឹងធ្វើជាមួយគ្នានឹងសេចក្ដីសម្រេចទាក់ទងនឹងសំណើដាក់ភស្តុតាងបន្ថែមនេះ យើងនឹងធ្វើជាមួយគ្នាដែរ ទាក់ទងនឹងសំណើសុំដកវិធានការការពារខ្លួននេះ។ ហើយបើអស់លោកមានយោបល់អី សូមអញ្ជើញ!

បាទ សូមអញ្ជើញលោកសហព្រះរាជអាជ្ញា។

[១១:៥១:៥៥]

**លោកស្រី ជា លាង៖**

ខ្ញុំចង់មានសំណួរបញ្ជាក់បន្ថែមទៅខាងអង្គជំនុំជម្រះតុលាការកំពូល ពីព្រោះសេចក្ដីសម្រេចអំពីភស្តុតាងថ្មីនេះវាពាក់ព័ន្ធនឹងសវនាការនៅថ្ងៃច័ន្ទ។ ក្នុងករណីដែលទទួលយក ឬក៏មិនទទួលយក។ ដូច្នេះខាងសហព្រះរាជអាជ្ញាហ្នឹងក៏មានគំនិតគិតថា ត្រូវការលឿនដែរដើម្បីឲ្យខ្ញុំរៀបចំនិងការឆ្លើយតបនូវការបង្ហាញនូវភស្តុតាងថ្មីនេះ។ អ៊ីចឹង ខ្ញុំថា គិតថានឹងព្យាយាមរហូតដល់ថ្ងៃសុក្រនេះនឹងចេញឲ្យបានហើយតែទន្ទឹមនឹងនេះដែរ ក៏សុំឲ្យអង្គជំនុំជម្រះតុលាការកំពូលហ្នឹងសម្រេចឲ្យបានលឿនដែរ ពីព្រោះថ្ងៃច័ន្ទនេះដល់ថ្ងៃសវនាការហើយ ដូច្នេះរកពេលសម្រាប់ខ្ញុំរៀបចំហ្នឹងក៏អត់មានដែរ បើនិយាយមែនទែនទៅ អានេះជាការលំបាកមែនទែន។ ចា៎, សូមអរគុណ។

[១១:៥២:៤៩]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ហាក់បីដូចជាពេលវេលាខ្លីមែនទែនសម្រាប់ការដាក់ចម្លើយតប ដែលខាងមេធាវីការពារក្ដីគាត់បានលើកឡើងអម្បាញ់មិញនេះ។ ប្រហែលជាយើងព្យាយាមពន្លឿននូវដំណើរការនីតិវិធីនេះ ប្រហែល

ឬក៏យើងអាចរង់ចាំរហូតទៅដល់ថ្ងៃច័ន្ទ ទើបទទួលបាននូវសារណានេះ។ ប្រសិនណាជាខាង ក.ស.ព គឺថាទាមទារត្រូវតែមានការឆ្លើយតបពីមេធាវីការពារក្តីនោះ ហើយយើងអាចនឹងសន្សំពេលវេលាទៅលើការបកប្រែបានផង។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៤:៣៧]

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

នៅក្នុងកាលៈទេសៈបែបនេះ អ្វីដែលអង្គជំនុំជម្រះចង់ស្នើសុំនោះ គឺម្យ៉ាងគឺយើងពេញចិត្តចំពោះការដាក់ចម្លើយរបស់ខាងការិយាល័យសហព្រះរាជអាជ្ញាឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។ សង្ឃឹមថា អាចដាក់នៅថ្ងៃសុក្រនេះបានតែម្តង ដាក់ថ្ងៃសុក្រហើយ ពេលព្រឹកទៀត។ ហើយអង្គជំនុំជម្រះនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីពិនិត្យមើលទៅលើសារណានេះ នឹងសម្រេចទៅលើបញ្ហានេះ និងខ្លឹមសារនេះ ក្នុងរសៀលថ្ងៃសុក្រដដែលនេះដែរ។ ក៏ប៉ុន្តែ គ្រាន់តែធានាឱ្យបានច្បាស់ថា ភាគីទាំងអស់ គឺនឹងត្រូវបានជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការកំពូល ហើយតុលាការកំពូលនឹងអានសេចក្តីសម្រេចរបស់ខ្លួននៅព្រឹកថ្ងៃច័ន្ទ នៃថ្ងៃសវនាការនេះតែម្តង។

ដូច្នេះភាគីទាំងអស់ គឺថានឹងមិនមានការមន្ទិលសង្ស័យទៅលើសេចក្តីសម្រេចស្តីអំពីភស្តុតាងថ្មីនេះទេ មុននឹង ក.ស.ព លើកឡើងនូវសារណាផ្ទាល់មាត់តែម្តង។ ហើយប្រសិនដែលអាចទទួលបានប្រហែលជាយើងអាចនឹងចាប់ផ្តើមសវនាការបន្ទាប់ពីនោះតែម្តង។

[១១:៥៦:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី។

**លោក កង ឫទ្ធារី៖**

ខ្ញុំសូមគោរពលោកប្រធាន។ សូមអរគុណដែលផ្តល់ឱកាសឱ្យខ្ញុំបានឆ្លើយតបនឹងសហព្រះរាជអាជ្ញា។ ព្រោះថាបើតាមយោបល់ខ្ញុំបាទ គឺថាសូមឱ្យបញ្ចប់ត្រឹមតែប៉ុណ្ណឹងតែម្តង ពីព្រោះបើកាលណាការិយាល័យសហព្រះរាជអាជ្ញាមានសិទ្ធិដាក់កំណត់សម្គាល់ ឬសារណាតបទៅនឹងការដាក់ភស្តុតាងថ្មីនោះ ពួកខ្ញុំផ្លាស់សិទ្ធិបាត់ទៅហើយ។ មានពេលឯណា គាត់ដាក់ព្រឹកថ្ងៃសុក្រ ហើយស្អែកឡើងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃច័ន្ទយើងសវនាការបាត់ទៅហើយ ពួកខ្ញុំប្រាំថ្ងៃមានសិទ្ធិ ឯសិទ្ធិប្រាំថ្ងៃរបស់ខ្ញុំនៅ

ឯណា? បាត់អស់រលីងទៅហើយ ហើយយូរណាស់ហើយអត់ដាក់ មកតវ៉ាគ្នា។ ពួកខ្ញុំដាក់យូរណាស់មកហើយ ភស្តុតាងអស់នុ៎ង។

ដូច្នេះ សូមឱ្យតុលាការកំពូលចេញសេចក្តីសម្រេចតែម្តងទៅ។ កុំចាំបាច់រង់ចាំការិយាល័យសហព្រះរាជអាជ្ញាដាក់ទេ។ បាទ, អរគុណ។

[១១:៥៦:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ, ចាំតុលាការកំពូលនឹងធ្វើការពិចារណា។

អ៊ីចឹង ខ្ញុំទាក់ទងនឹងបញ្ហាសំណើសុំដកវិធានការ ការពារនេះ យើងអត់មានអី មានយោបល់អីបន្ថែមទេ ហើយការសុំដកវិធានការការពារនេះ គឺខាងអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការពិភាក្សារួចហើយ។ ប៉ុន្តែគ្រាន់តែថា សេចក្តីសម្រេចយើងអត់ទាន់បានធ្វើការបកប្រែ។ ដូច្នេះ គឺវាអាចចេញនៅពេលឆាប់ៗនេះហើយ។

ទាក់ទងទីពីរទៀត គឺជាបញ្ហាសំណួរ របស់ចៅក្រម ហើយបញ្ហាសំណួរចៅក្រមនេះ គឺលោកចៅក្រមនៅអង្គជំនុំជម្រះតុលាការកំពូលនឹងមានយោបល់។ សូមអញ្ជើញ!

[១១:៥៧:៥៤]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ដើម្បីសម្រួលទៅដល់សំណើសុំពេលវេលាបន្ថែមពីបណ្តាភាគីទាំងអស់ ខ្ញុំកំពុងតែគិតថា ប្រហែលជាថា ការផ្តល់ឱកាស និងផ្តល់ពេលវេលានៅក្នុងសារណាបណ្តឹងសាទុក្ខ ខ្ញុំសូមលើកជាសំណួររបស់ខ្ញុំក្នុងពេលនេះតែម្តង។ ដូច្នេះ ភាគីអាចនឹងឆ្លើយតបនូវផ្នែកណាពាក់ព័ន្ធនៅក្នុងសារណារបស់ខ្លួនដោយមិនបាច់ពាក់ព័ន្ធទៅនឹងការឆ្លើយឆ្លងគ្នា ហើយចំណុចនេះមិនបានដាក់នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការនៅឡើយទេ។ ហើយយើងដឹងថា ចំណុចនេះគឺមិនទាន់ច្បាស់លាស់នៅឡើយ។ អ៊ីចឹង បានជាយើងមានកិច្ចប្រជុំនេះ។

[១១:៥៨:៥០]

បន្ថែមទៅនឹងដីកាកំណត់កាលបរិច្ឆេទសវនាការនេះ គឺថាមានលើកឡើង ដែលភាគីទាំងអស់មានលើកឡើងនៅក្នុងដីកាកំណត់កាលបរិច្ឆេទដែរ គឺថាខាង ក.ស.ព ក៏ដូចជាភាគីទាំងអស់នឹងអញ្ជើញឱ្យឆ្លើយតបទៅនឹងបញ្ហានេះ ថាតើវាជាបញ្ហា ឬក៏អត់នៅក្នុង-- ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

ជាតិ ហើយអ្វីដែលយើងបានដាក់នៅក្នុងដីកាកំណត់កាលបរិច្ឆេទនេះ គឺពាក់ព័ន្ធជម្លោះប្រដាប់អាវុធ។ ហើយអ្វីដែលយើងចង់មានចំានោះគឺ និយាយអំពីការឈ្លានពាន ដែលមានឧបសម្ព័ន្ធដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មសង្គ្រាមនេះ។

[១១:៥៩:៣៧]

ទាក់ទងទៅនឹងនិយមន័យនៃ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ដែលនឹងត្រូវយកមកពិចារណានៅក្នុងរឿងក្តីនេះ ផ្តើមចេញអំពីធម្មនុញ្ញរបស់តុលាការ *នូរ៉ឹមប៊ឺក*។ ដូច្នេះចំណុចបន្ទាប់ ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ដែលនៅក្នុងយុត្តាធិការរបស់តុលាការនេះ ដូចដែលមហាសន្និបាតអង្គការសហប្រជាជាតិលើកឡើងនៅក្នុងគោលការណ៍របស់តុលាការ *នូរ៉ឹមប៊ឺក* ដែរ។ ទាក់ទងចំណុចនេះ យើងចង់បានមតិយោបល់ផ្សេងៗ ពីខាងភាគីពាក់ព័ន្ធទាំងអស់។

[១២:០០:១៦]

ទីពីរ យើងសូមអញ្ជើញជនជាប់ចោទនិងសហព្រះរាជអាជ្ញា ថាតើបទរំលោភសេពសន្ថវៈវាស្ថិតនៅក្នុងបញ្ហាយុត្តាធិការពេលវេលាដែរឬក៏យ៉ាងណានោះ? ក៏ប៉ុន្តែ-- ហើយខ្ញុំក៏ចង់ស្តាប់ពីភាគីទាំងអស់ដែរ ថាតើបទល្មើសនៃការធ្វើទុក្ខបុកម្នេញ ឬសញ្ញាណនៃការធ្វើទុក្ខបុកម្នេញ គឺថាមានការបញ្ជាក់ រឹងមាំដែរឬអត់នៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នេះ?

[១១:០០:៤៦]

ទាក់ទងទៅនឹងការផ្តន្ទាទោស យើងបានអញ្ជើញហើយនៅក្នុងដីកាកំណត់កាលបរិច្ឆេទនេះ គឺជាពិសេសអញ្ជើញខាង ក.ស.ព ឲ្យបញ្ជាក់លម្អិតទៅលើច្បាប់ទាក់ទងទៅនឹងក្រម ជាពិសេសទាក់ទងទៅនឹងក្រមព្រហ្មទណ្ឌនូវចន្លោះរវាងការចេញសាលក្រមរបស់សាលាដំបូង បន្ទាប់ពីនេះ។ ហើយជាពិសេសបំផុត សំណួររបស់ខ្ញុំទាក់ទងទៅនឹងអ្វីដែលលើកឡើងនៅក្នុងសារណារបស់ ក.ស.ព កថាខណ្ឌ ១២៧ ទាក់ទងទៅនឹងចំណុចជាក់លាក់មួយចំនួនដែល ក.ស.ព បានលើកឡើងថា ច្បាប់ស្តីអំពីការបង្កើត អ.វ.ត.ក គឺជាច្បាប់ពិសេស។ ហើយបើដូច្នេះទេ វាមិនប៉ះពាល់ទៅនឹងការកែប្រែថ្មី វិសោធនកម្មថ្មីមាននៅក្នុងក្រមព្រហ្មទណ្ឌនោះទេ។

[១២:០២:០៩]

ដូចតាមការយល់ឃើញរបស់ខ្ញុំ គឺយើងសូមឲ្យដើមបណ្តឹងសាទុក្ខនេះបង្ហាញ ថាតើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនេះ ដែលពាក់ព័ន្ធទៅនឹងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋ

កម្មសង្គ្រាម និងបទប្រល័យពូជសាសន៍ ជាពិសេសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាបទល្មើស-- វា-- បទប្បញ្ញត្តិនេះជាបទប្រសាសន៍-- ទាក់ទងបទប្បញ្ញត្តិ ទាក់ទងទៅនឹងបទប្បញ្ញត្តិពិសេស ទាក់ទងទៅនឹងបទប្បញ្ញត្តិនៃច្បាប់ស្ដីអំពីការបង្កើត អ.វ.ត.ក គឺមាត្រា៣៩(ថ្មី) នៃច្បាប់ អ.វ.ត.ក។ ថាតើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនោះវាពិសេសយ៉ាងណា បើប្រៀបធៀបទៅនឹងបទប្បញ្ញត្តិនៃការផ្ដន្ទាទោសនៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក?

[១២:០៣:០០]

ខ្ញុំមានសំណួរពីរ ទាក់ទងទៅនឹងការដាក់ជាទាសករ គឺដូចខាងក្រោមនេះឯង៖

ទី១) គឺដើមបណ្ដឹងសាទុក្ខ ត្រូវបានអញ្ជើញឲ្យផ្ដល់ជាយោបល់ផ្សេងៗអំពីការខ្វះចន្លោះរវាងវិសាលភាពនៃដីកា ក៏ដូចជាការដាក់ជាបទល្មើសនៃការដាក់ជាទាសករ ហើយនិងការ-- និងបណ្ដឹងសាទុក្ខនេះ។ ប្រហែលវាជាការ ខ្ញុំយល់ច្រឡំទេយ៉ាងមើល៍ទៅ ខ្ញុំចង់បានគំនិតយោបល់ពីការិយា ល័យសហព្រះរាជអាជ្ញា ថាតើ ក.ស.ព យល់ឃើញដូចម្ដេចចំពោះបទល្មើសនៃការដាក់ជាទាសករនៅ ក្នុងដីកាដំណោះស្រាយនេះ? ថាតើ ក.ស.ព ពិចារណាថា វាកម្រិតចំពោះអ្នកជាប់ឃុំឃាំងមួយចំនួនជាក់លាក់ណានោះ? ថាតើអ្នកជាប់ឃុំឃាំងជាក់លាក់មួយចំនួនឬ?

[១២:០៤:១៤]

ហើយទាក់ទងទៅនឹងការដាក់ជាទាសករនេះផងដែរ ខ្ញុំស្នើសុំឲ្យបណ្ដឹងសាទុក្ខពន្យល់ទៅលើអង្គហេតុនៃរឿងក្ដីដែលមាននៅចំពោះមុខយើងទាំងអស់គ្នានេះ គឺថាគាត់មានការព្រួយបារម្ភរវាងអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ ហើយនិងការដាក់ឲ្យទៅជាទាសករ។ មិនមែនក្នុងអត្ថន័យ គេហៅថាអរូបីនោះទេ ប៉ុន្តែនិយាយទៅលើ សំដៅទៅលើអង្គហេតុដែលមាននៅក្នុងរឿងក្ដីនេះតែម្ដង។

[១២:០៤:៥៧]

នេះគឺជាសំណួរដែលខ្ញុំដាក់ជូនទៅសហព្រះរាជអាជ្ញា ក៏ដូចជាខាងមេធាវីការពារក្ដីផងដែរ បើសិនណាជាខាងមេធាវីការពារក្ដីមានចេតនាឆ្លើយតបទៅនឹងសំណួរ ដែលខ្ញុំលើកឡើងទាំងអម្បាលម៉ាននេះ។ ហើយខ្ញុំក៏សុំស្នើសុំសួរជាក់លាក់ឲ្យឆ្លើយនូវសំណួរមុន ទាក់ទងទៅនឹងបទដ្ឋាននៃការបង្ហាញភស្តុតាង។ ថាតើមូលដ្ឋានច្បាប់អីដែលដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើង ទាក់ទងទៅនឹងបទដ្ឋាននៃការបង្ហាញភស្តុតាង ដែលថាការតាមទាររបស់គាត់នោះ គឺថាគួរតែយកមកអនុវត្តនៅក្នុងរឿងក្ដីនេះ? ហើយតើការជូនដំណឹងបែបណាដែរដែលគាត់ចង់បានពីសាលាដំបូង ដែលគាត់ថាចង់ឲ្យផ្ដល់ព័ត៌មាន

នេះមកឲ្យគាត់ក្នុងរឿងដដែលនេះ?

[១២:០៥:៥៧]

នេះទាក់ទងទៅនឹងសេចក្តីសម្រេចរងការជំទាស់របស់សាលាដំបូង ដែលសាលាដំបូងបានអនុវត្ត បទដ្ឋានខ្ពស់ពេក-- បទដ្ឋាននៃការផ្តល់ភស្តុតាងនេះខ្ពស់ពេក នៅពេលអនុវត្តការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរ ទាក់ទងទៅនឹងទាំងផ្នែកនីត្យានុកូលភាព ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសំណង។ ថាតើមានមូលដ្ឋានណាដែរ ទាក់ទងទៅនឹងបទដ្ឋាននៃការបង្ហាញភស្តុតាងនេះ? ហើយវានឹងមានការជូនដំណឹងបែបណាដែរ ដែលដើមបណ្តឹងសាទុក្ខ គាត់រំពឹងចង់បានទៅនឹងចំណុចទាំងនេះ?

[១២:០៦:៤៣]

ហើយចំណុចចុងក្រោយ ដើមបណ្តឹងសាទុក្ខពីក្រុមពីរ និងក្រុមបី ក៏ត្រូវបានអញ្ជើញឲ្យមកជួយដល់តុលាការយើងនេះ មកដល់តុលាការកំពូលនៅក្នុងការលើកឡើង ថាតើពួកគាត់ចង់បានអ្វីទាក់ទងទៅនឹងការកំណត់នៅក្នុងសាលក្រមដែលបានកំណត់មកនេះ? ថាតើគាត់យល់ឃើញយ៉ាងម៉េចចំពោះផ្នែកនេះនៅក្នុងសាលក្រម? ហើយនេះគឺជាសំណួរ ដែលខ្ញុំស្នើសុំនៅក្នុងសវនាការលើបណ្តឹងសាទុក្ខនេះជាមុន ដែលវាចំណុចនេះ គឺថាធ្វើបែបនេះ វាអាចនឹងជួយដល់ភាគីទាំងអស់ ហើយវាជួយដល់ពេលការសន្សំពេលវេលានៅក្នុងពេលសវនាការផងដែរ។

[១២:០៧:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម សោម សិរិវឌ្ឍ។

**ចៅក្រម សោម សិរិវឌ្ឍ៖**

ខ្ញុំជាអ្នកទទួលបន្ទុកខាងផ្នែកយុត្តាធិការបុគ្គល ជាមួយនឹងលោកចៅក្រម ចាយ៉ាស៊ីញហ៍។

ខ្ញុំមានសំណួរចំនួនបួន សម្រាប់លើកឡើងជូនភាគីទាំងអស់។ ខ្ញុំសូមលើកឡើងអំពីសំណួរទីមួយ ដែលពាក់ព័ន្ធជាមួយនឹងសហមេធាវីការពារក្តីជនជាប់ចោទ សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី។

សំណួរនេះគឺថា សូមផ្តល់យោបល់ថា តើពាក្យមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងកិច្ចព្រមព្រៀងនិងច្បាប់ អ.វ.ត.ក គឺជាលក្ខខណ្ឌយុត្តាធិការ

មួយដែលជាកម្មវត្ថុនៃការពិនិត្យលើយុត្តាធិការ ឬជាការណែនាំចំពោះឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតដែលមិនមែនជាការពិនិត្យលើយុត្តាធិការដែរឬទេ?

[១២:០៨:៥៩]

សំណួរទីពីរៈ សំណួរទីពីរនេះសម្រាប់ចំពោះសហមេធាវីការពារក្តីជនជាប់ចោទ។ សំណួរនោះគឺសូមធ្វើការពន្យល់អំពីភាពពាក់ព័ន្ធទៅនឹងការយោង ទៅលើគោលការណ៍នីត្យានុកូលភាពនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ។ ឧទាហរណ៍ កថាខណ្ឌទី១៤ កថាខណ្ឌទី៦១, ៦២ កថាខណ្ឌទី៦៧, កថាខណ្ឌទី៩៥ និងទី១០០ និងការឆ្លើយរបស់ជនជាប់ចោទ។ ឧទាហរណ៍ កថាខណ្ឌទី១២ ឯកសារលេខ S14។

ចំពោះសំណួរទីបី ក៏សម្រាប់ចំពោះសហមេធាវីការពារក្តីជនជាប់ចោទដែរ គឺថាសំណួរនោះគឺសូមពន្យល់ពីការពាក់ព័ន្ធនៃកថាខណ្ឌទី១៥ នៃសារណាបណ្តឹងសាទុក្ខ ឯកសារ S14។

សំណួរទីបួន ក៏ចំពោះសហមេធាវីការពារក្តីជនជាប់ចោទដែរ។ សំណួរគឺ សូមពន្យល់ពីការពាក់ព័ន្ធលើអត្ថន័យ នៃសំណើក្នុងកថាខណ្ឌទី១១០(ខ) នៃសារណាបណ្តឹងសាទុក្ខ ឯកសារលេខ S14។

សូមអរគុណ។

[១២:១០:២៧]

**ចៅក្រម អាកនីស្តា ក្លូណូវីកកា មីឡាត៖**

លោក អាន់ឌ្រូ ខេលី ចំពោះកថាខណ្ឌអំមិញចុងក្រោយហ្នឹង គឺ១៣៥ ដែលពាក់ព័ន្ធទៅនឹងទាសភាព អំពើទាសភាព។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី។

**កញ្ញា ម៉ុច សុវណ្ណារី៖**

អរគុណឯកឧត្តមប្រធាន។ នាងខ្ញុំសូមស្នើសុំឲ្យបញ្ជាក់ពីលោកស្រីចៅក្រម ទាក់ទងជាមួយសំណួរចុងក្រោយ។ សំណួរទីបី ដែលគាត់ចង់សួរទៅដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ និងក្រុមបី។ សូមឲ្យគាត់បានបញ្ជាក់សំណួរឡើងវិញ។

[១២:១១:២៤]

**ចៅក្រម អាកនីស្តា ក្លូណូវីកកា មីឡាត៖**

ក្រុមទីមួយនិងទីបី បានស្នើសុំអំពីមធ្យោបាយនៃ-- ក្រុមទីពីរ និងក្រុមទីបី បានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខដែលថា លើកឡើងអំពីទម្រង់នៃសំណងក្នុងលក្ខណៈមួយដែលបានបង្កើតឡើង។

នៅពេលនេះ គឺយើងស្នើសុំដើមបណ្តឹងសាទុក្ខឲ្យបញ្ជាក់ឲ្យបានច្បាស់ ហើយធ្វើការពង្រួមសំណើរបស់ខ្លួនក្នុងពាក្យពេចន៍មួយជាក់លាក់ដែលថា ខ្លួនចង់ថា ចង់ឲ្យសេចក្តីសម្រេចនៅក្នុងសាលដីកានោះយ៉ាងម៉េចតាម ចំពោះការផ្តល់ជូនទៅលើបញ្ហាសំណងនេះ?

[១២:១៣:០០]

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងអស់លោក លោកស្រី គ្មានយោបល់អ្វីបន្ថែមទៀតទេសម្រាប់កិច្ចប្រជុំនេះ។ បើអ៊ីចឹងយើង-- បាទៗ លោកមេធាវីសូមអញ្ជើញ! សូមលោកមេធាវី ហុង គឹមសួន មុន។

**លោក ហុង គឹមសួន៖**

សូមអរគុណឯកឧត្តមប្រធាន។ សូមអរគុណនិងសូមគោរពឯកឧត្តមប្រធាន ព្រមទាំងអង្គប្រជុំជាទីគោរព។ ខ្ញុំបាទមេធាវី ហុង គឹមសួន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នៃក្រុមពីរផង និងក្រុមបួនផង។ តែដោយសារក្រុមបួនមិនបានធ្វើបណ្តឹងសាទុក្ខនៅលើសាលក្រម។ ប៉ុន្តែនៅពេលនេះ ខ្ញុំបាទសំណើ ជាសំណើទេ ដោយសារយោងទៅតាមគោលការណ៍នៃក្រម ឬក៏នីតិវិធីនៃតុលាការជាតិកម្ពុជា មានន័យថា ភាគីនៅក្នុងរឿងមួយដែលសាលាដំបូងបានសម្រេចជាសាលក្រមទៅលើអង្គសេចក្តីរួចហើយ ហើយមានភាគីផ្សេងៗទៀតនៅក្នុងសំណុំរឿងបានធ្វើបណ្តឹងឧទ្ធរណ៍ ឬសាទុក្ខ។ ដូច្នេះ ភាគីដែលទាក់ទិននៅក្នុងសំណុំរឿង ទោះខ្លួនមិនបានប្តឹងឧទ្ធរណ៍ទៅលើចំណុចក៏ដោយ ក៏នៅតែជាភាគី។ ពីព្រោះ មានន័យថា សាលក្រមរបស់សាលាដំបូងមិនទាន់ចូលជាស្ថាពរនៅឡើយទេ។ អ៊ីចឹងភាគីទាំងឡាយត្រូវរង់ចាំការសម្រេចក្តីរបស់តុលាការជាន់ខ្ពស់តទៅទៀត។

[១២:១៤:៤៥]

ក្នុងនេះដែរ ខ្ញុំបាទមានជាសំណូមពរមួយ ដោយខ្ញុំបាទបានទទួលដំណឹង តាមរយៈអង្គភាពគាំពារជនរងគ្រោះ ដែលបានទទួលបន្តពីខាង *ផាប់ប្លីក អាហ្វែរ* ឬក៏ខាងផ្នែកខាងរៀបចំ ផ្នែកមន្ត្រីសាធារណៈរៀបចំសាលសវនាការនេះ។ ខ្ញុំបាទមិនច្បាស់ទេ គ្រាន់តែថាបានមើលអ៊ីម៉ែលរបស់ខាងអង្គភាពគាំពារជនរងគ្រោះ មិនបានទទួលយកការស្នើសុំដាក់ឲ្យមានកន្លែងអង្គុយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមទីបួន ដែលគាត់រង់ចាំការសម្រេចក្តីរបស់តុលាការកំពូល លើវាសនាអនាគត

របស់គាត់ស្ដីអំពីភាពយុត្តិធម៌ ទាំងការផ្ដន្ទាទោស ទាំងសំណងទាំងឡាយ ដែលភាគីដទៃទៀតមាន ក្រុមមួយ ក្រុមពីរ ក្រុមបី បានប្ដឹងសាទុក្ខទៅលើសំណងរដ្ឋប្បវេណី និងអំពីការច្រានចោលដើមបណ្ដឹងរដ្ឋប្បវេណី។

[១២:១៥:៥៤]

ក្នុងនេះ ខ្ញុំបាទសូមជម្រាបឯកឧត្ដម និងអង្គប្រជុំជ្រាបថា ក្រុមទីបួន មានន័យថាដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទីបួន មិនមានដើមបណ្ដឹងណាមួយត្រូវបានតុលាការច្រានចោលពីភាពជាដើមបណ្ដឹងរដ្ឋប្បវេណីទេ មានន័យថា គាត់បានទទួលសិទ្ធិស្របច្បាប់ហើយ ហើយទាក់ទងទៅលើបណ្ដឹងទាមទារសំណងរដ្ឋប្បវេណី គាត់មិនបានប្ដឹងទេ។ ប៉ុន្តែ គាត់ទទួលយកការផ្ដន្ទាទោសទៅលើជនជាប់ចោទ ដែលសាលាដំបូងបានផ្ដន្ទាទោស។ ត្រង់នេះហើយ ដែលគាត់មិនបានប្ដឹងសាទុក្ខទៅលើបណ្ដឹងអំពីសំណងទេ ប៉ុន្តែ គាត់រង់ចាំ។

ដូច្នេះ ក្នុងនេះខ្ញុំបាទ សូមឲ្យឯកឧត្ដមប្រធានមេត្តាទទួលអនុញ្ញាតឲ្យគាត់ដែលជាដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងនាមជាភាគី មានសិទ្ធិចូលរួមក្នុងសវនាការតុលាការកំពូលខាងមុខនេះ ដោយមានសិទ្ធិអង្គុយនៅក្នុងបន្ទប់សវនាការតាមការរៀបចំ ដូចក្រុមមួយ ក្រុមពីរ ក្រុមបី ក្រុមបួន ឬក៏នៅក្នុងបន្ទប់សាធារណៈនេះ ដើម្បីតាមយក តាមដានស្ដាប់ ឬក៏ទទួលយកព័ត៌មាន ស្ដីពីការសម្រេចចុងក្រោយរបស់តុលាការកំពូលនេះ ហេតុនេះខ្ញុំបាទសំណូមពរឲ្យក្រុមបួន យ៉ាងដូច្នេះ។ សូមអរគុណ។

[១២:១៧:៤៥]

**ប្រធានអង្គជំនុំៈ**

តាមពិតទៅ គឺសម្រាប់ក្រុមបួននេះ គឺគាត់អត់បានធ្វើបណ្ដឹងសាទុក្ខមកតុលាការកំពូលទេ ដូច្នេះនៅក្នុងសំណុំរឿងក្រោយនេះ គឺគាត់មិនអាចចូលរួមនៅក្នុងសាលសវនាការក្រោយនេះបានទេ។ ដោយហេតុធ្វើម៉េច កន្លែងយើងវាមានកន្លែងតិចណាស់។ អ៊ីចឹងហើយបានជាក្រុមមួយ ក្រុមពីរ ក្រុមបី នេះ គឺយើងបានធ្វើការរៀបចំឲ្យបែកចែករំលែកពេលវេលាគ្នា សម្រាប់ម៉ោងអង្គុយបំពេញកន្លែង។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏តាមខ្ញុំក្ដាប់បាននៅផ្នែកកិច្ចការសាធារណៈថា សម្រាប់សាធារណជន និងសម្រាប់ភាគីដើមបណ្ដឹងខ្លះដែលមិនបានចូលរួមផ្ទាល់នៅក្នុងទីសវនាការនេះ គឺអាចអង្គុយនៅខាងកៅអីខាងក្រៅ គឺអង្គុយនៅខាងកៅអីសាធារណជនបាន។

ដូច្នេះ បើសិនជាគាត់មានបំណងនឹងចូលរួមក្នុងការស្ដាប់អង្គសវនាការ ដែលប្រព្រឹត្តទៅនៅថ្ងៃទី

២៨ រហូតដល់ថ្ងៃទី៣០ នេះ គាត់អាចជម្រាបជូនទៅខាងផ្នែកកិច្ចការសាធារណៈជ្រាប ដើម្បីគាត់មានសិទ្ធិនៅក្នុងការចូលរួមនៅក្នុងការកន្លែងដែលសម្រាប់អង្គុយនៅក្នុងកន្លែងសាធារណជននេះ។ ប្រហែលជាខាងកិច្ចការសាធារណហ្នឹង គេរៀបចំកៅអីបម្រុងទុកហើយ។ ដូច្នេះ គឺសូមឱ្យមេធាវី ហុង គឹមសួនហ្នឹងគឺសូមទាក់ទងទៅខាងផ្នែកការិយាល័យ ខាងផ្នែកអង្គភាពសាធារណៈទៅ គេអាចរៀបចំទីកន្លែងឱ្យគាត់ហើយ។ ដូច្នេះមិនមានជាបញ្ហាអីទេ។

[១២:១៩:២៣]

**លោក ហុង គឹមសួនៈ**

សូមអគុណឯកឧត្តមប្រធាន។ ក៏ប៉ុន្តែនៅក្នុងនេះ ពេលវេលាដែលខាង *ផាប់ប្លីក អាហ្វែរ* ដែលគេរៀបចំនេះ វាហួសពេលវេលទៅហើយ។ តែខ្ញុំបាទបានដាក់សំណើទាំងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានចំនួនប្រាំនាក់តែប៉ុណ្ណោះ។ ខ្ញុំបាទគិតថាបើមិនបានអង្គុយនៅក្នុងបន្ទប់សវនាការនេះ ក៏មានកៅអីសម្រាប់ពួកគាត់ នៅក្នុងបន្ទប់សាធារណៈខាងមុខនេះដែរ។ ប៉ុន្តែឥឡូវនេះ នៅក្នុងអ៊ីម៉ែលដែលជូនមកព្រឹកនេះ គឺមិនមានទាំងមេធាវី មិនមានទាំងដើមបណ្តឹងទៅទៀត ព្រោះមានន័យថាពេញអស់ទៅហើយកៅអីនោះ។ អ៊ីចឹង ឈ្មោះដែលខាងអង្គភាពគាំពារជនរងគ្រោះទទួលលើកមុន ទើបតែបានផ្តល់ដំណឹងមកថ្ងៃនេះ គឺហួសពេលសុំទៅហើយ។ អ៊ីចឹងហើយ ទើបខ្ញុំបាទសំណើនេះសុំទៅខាងលោកឯកឧត្តមប្រធាននិងអង្គប្រជុំនៅពេលនេះ ដើម្បីសម្រេចឱ្យបានគាត់មកអង្គុយនៅក្នុងបន្ទប់សាធារណៈនេះផង។ សូមអរគុណ។

[១២:២០:៥៤]

**ប្រធានអង្គជំនុំៈ**

សូមជម្រាបទៅដល់លោកមេធាវីថា ចាំបញ្ហានេះ គឺសូមឱ្យខាងមន្ត្រីច្បាប់ ខាងតុលាការកំពូលគឺធ្វើការទាក់ទងជាមួយនឹងខាងប្រធានផ្នែកកិច្ចការសាធារណៈហ្នឹង ដើម្បីឱ្យគាត់អាចធ្វើការរៀបចំ ឬក៏បើសិនជាពេញហើយ អាចបន្ថែមកៅអីយ៉ាងណា គឺដើម្បី គឺលោកស្នើសុំអំមិញ គឺប្រាំនាក់ទេ។ អ៊ីចឹងអ្ហេស?

**លោក ហុង គឹមសួនៈ**

បាទៗ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ដើម្បីឲ្យខាងមន្ត្រីច្បាប់ ខាងខ្ញុំនេះគឺទាក់ទងជាមួយលោក រាជ សម្បត្តិ ដើម្បីជួយរៀបចំធ្វើយ៉ាងណាដើម្បីឲ្យបានកៅអីសម្រាប់គាត់អង្គុយ សម្រាប់ចូលរួមការមើលសវនាការរបស់យើងនេះ ចាំខាងលោកក្រឡាបញ្ជី និងខាងលោក ស៊ា ម៉ៅ នេះ គឺជាអ្នករៀបចំ។

អ៊ីចឹងគឺមានបញ្ហាទីទៀតទេ?

[១២:២១:៤៥]

**លោក ហុង គីមសួន៖**

បាទ ខ្ញុំបាទសូមអរគុណឯកឧត្តមប្រធានបានជួយជ្រោមជ្រែងនៅក្នុងរឿងនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញ!

**លោកស្រី ស៊ីលឃីស្ទួត ហ្សឺនស្តី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយដោយខ្លីៗ។ ខ្ញុំសូមបញ្ជាក់បំភ្លឺមួយ នៅពេលដែលខ្ញុំបានមើលអ៊ីម៉ែល បញ្ជូនមកពីអង្គភាពជនរងគ្រោះបានលើកឡើងថា ខាងកិច្ចការសាធារណៈមិនអនុញ្ញាតឲ្យមេធាវីក្រុមទីបួនអង្គុយនៅទីសាធារណៈនេះទេ។ ដូច្នេះហើយ វាជាបញ្ហាមួយបារម្ភផងដែរ។

មានកន្លែងអង្គុយនៅទីសាធារណជននោះ គឺសម្រាប់តែដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមេធាវីក្រុមទីបួនមិនអនុញ្ញាតឲ្យអង្គុយនៅក្នុងនុ៎ងទេ។

នៅក្នុងអ៊ីម៉ែលនោះវាផ្ទុះបញ្ចាំងពីការជូនដំណឹងពីខាងកិច្ចការសាធារណៈមកឲ្យយើងដឹងទៅលើករណីនេះ។ សូមអរគុណ។

[១២:២៣:០០]

**ប្រធានអង្គជំនុំ៖**

ក្រុមបួនហ្នឹង គឺលោកស្រីបញ្ជាក់មើល៍ មេធាវីក្រុមបួនមានប៉ុន្មាននាក់នុ៎ង ដែលមានបំណងអង្គុយនុ៎ង?

**លោក ហុង គីមសួន៖**

សូមអនុញ្ញាតឯកឧត្តមប្រធាន ដោយសារអម្បាញ់មិញជាភាសាអង់គ្លេសហ្នឹង ខ្ញុំឲ្យគាត់ជួយជម្រាបជូនឯកឧត្តម។ ឥឡូវនេះ ខ្ញុំបាទបានយល់នៅក្នុងដែរ មិនមែនតែចំពោះដើមបណ្តឹងរដ្ឋប្បវេណី

ក្រុមបួនទេ មេធាវីផង។

មេធាវីក្រុមបួន មានឈ្មោះ ខ្ញុំបាទ ហុង គីមសួន ជាមេធាវីជាតិ។ មេធាវី ព្យែរអូលីយេ សួរ ជាមេធាវីអន្តរជាតិ មេធាវីជាតិហ្នឹង លោក គង់ ពិសី។ ប៉ុន្តែនៅក្នុងនេះ មានតែមេធាវី ព្យែរអូលីយេ សួរទេ ដែលគាត់ចង់មកចូលរួមអង្គុយក្នុងនេះដែរ។ ដោយសារខ្ញុំបាទមានតួនាទីពីរក្រុម អ៊ីចឹងខ្ញុំបាទនៅក្នុងក្រុមពីរ។ ក្រុមពីរ ហើយក្រុមបួន សម្រាប់លោក ព្យែរអូលីយេ សួរ ។ សូមអរគុណ។

[១២:២៣:៥៦]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង អំមិញនេះគឺសល់តែលោកមេធាវីអន្តរជាតិម្នាក់ទេ ដែលមានបំណងនឹងចូលរួមហ្នឹង។ អ៊ីចឹងទាក់ទងនឹងបញ្ហាមេធាវីដែលគាត់មានបំណងនឹងចូលរួមក្នុងការស្តាប់សវនាការនេះ គឺខ្ញុំគិតថាចាំឲ្យខាងមន្ត្រីច្បាប់យើងខ្ញុំហ្នឹង នឹងជម្រាបជូនខាងលោក រាជ សម្បត្តិ ដែរ ហើយសុំឲ្យលោក រាជ សម្បត្តិ រៀបចំយ៉ាងណាគឺដើម្បីឲ្យគាត់ គឺមានកៅអីសម្រាប់អង្គុយដើម្បីនៅខាងផ្នែកសាធារណជននោះ ដើម្បីឲ្យគាត់តាមដានសវនាការបាន។

អ៊ីចឹង យើងនឹងឲ្យខាងមន្ត្រីច្បាប់យើងហ្នឹង គឺរៀបចំជូនបាទ។

សូមអញ្ជើញ សហព្រះរាជអាជ្ញា។

[១២:២៦:១៦]

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលយើងមើលទៅលើសំណួរទាំងឡាយ ដែលលោកស្រីចៅក្រម មីឡាត បានដាក់ជូនភាគីនោះ ខ្ញុំសូមបញ្ជាក់បំភ្លឺសំណួរទីមួយ ដើម្បីឲ្យខ្ញុំយល់ឲ្យច្បាស់។

ខ្ញុំយល់ឃើញថា លោកស្រីចៅក្រមមិនចង់ស្តាប់នូវសេចក្តីសន្និដ្ឋានទាក់ទងទៅនឹងចំណុចទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្ម-- និងជម្លោះប្រដាប់អាវុធនៅក្នុងយុត្តាធិការពេលវេលាតុលាការនេះទេ។

សេចក្តីសន្និដ្ឋានរបស់យើង ពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ គឺបាទ ខ្ញុំសូមអនុញ្ញាតសូមឲ្យលោកស្រីចៅក្រមបញ្ជាក់បំភ្លឺឲ្យខ្ញុំឲ្យបានច្បាស់ត្រង់ចំណុចហ្នឹង។

[១២:២៧:១០]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំសូមបំភ្លឺ។ អ្វីដែលយើងបញ្ជូនដីកាកំណត់កាលបរិច្ឆេទនោះ គឺការឲ្យលើកឡើងលម្អិតទៅលើលក្ខខណ្ឌចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សនិងជម្លោះប្រដាប់អាវុធ។ នៅពេលដែលយើងសរសេរបញ្ចូលដូច្នោះ យើងបានមើលអំពីលក្ខខណ្ឌដែលកើតចេញពីច្បាប់នៅតុលាការ *នូរ៉ឹមប៊ឺក* ដែលនៅទីនោះ គឺមិនបានបង្ហាញអំពីលក្ខខណ្ឌចំណងទំនាក់ទំនងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធនោះទេ។ ប៉ុន្តែ ក៏គេបង្ហាញអំពីលក្ខខណ្ឌនៅក្នុងយុត្តាធិការរបស់តុលាការនៅពេលនោះជាពិសេសទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព។

[១២:២៨:០៣]

បញ្ហាមួយទៀតលេចចេញមកពីអង្គបុរេជំនុំជម្រះ ហើយសេចក្ដីសម្រេចនោះ ក៏បានសម្រេចរបស់អង្គបុរេជំនុំជម្រះបានលើកឡើងលម្អិតទៅលើចំណុចហ្នឹង។ នៅក្នុងនោះមានចម្ងល់សង្ស័យ ថាតើលក្ខខណ្ឌតម្រូវនៃចំណងទាក់ទងនេះ ត្រូវតែជាលក្ខខណ្ឌទាមទារនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែរឬទេ?

ដូច្នេះហើយ យើងខ្ញុំស្នើសុំ និងស្វាគមន៍ជំហររបស់ខាងសហព្រះរាជអាជ្ញាលើចំណង លក្ខខណ្ឌចំណងទាក់ទងនេះ ថាយ៉ាងម៉េច? ដោយយើងចងចាំថា នៅពេលដែលយើងនិយាយអំពីចំណងទាក់ទង គឺយើងនិយាយអំពីគោលការណ៍របស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ។ មិនមែនចំណងទាក់ទងជម្លោះប្រដាប់អាវុធទេ គឺចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ។

[១២:២៨:៥៤]

យើងដឹងហើយថា យុត្តិសាស្ត្រមកពីគោលការណ៍ *នូរ៉ឹមប៊ឺក* មួយចំនួន គឺវាពាក់ព័ន្ធទៅនឹងចំណងទាក់ទងជម្លោះប្រដាប់អាវុធតែប៉ុណ្ណោះ។ ប៉ុន្តែយ៉ាងណាក៏ដោយ គឺគេបង្ហាញចំណងទាក់ទងនៅក្នុងសង្គ្រាមឈ្លានពាន។ ហើយគេមិនបានបង្ហាញថា វាមានចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរឬទេ?

ដូច្នេះហើយ យើងត្រូវតែគិតថា តើចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ និងជម្លោះប្រដាប់អាវុធនោះ តើទាមទារដែរឬទេ?

**លោក អាន់គ្រូ ខេលី៖**

សូមអរគុណ លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី។

[១២:២៩:៣៣]

**លោក កង ឫទ្ធារី៖**

បាទ ខ្ញុំមេធាវីការពារជនជាប់ចោទក៏មានសំណួរទៅលើស្រីចៅក្រមដែរបាទ។ ថាមូលហេតុអ្វីបានជាខាងចៅក្រមមានការចាប់អារម្មណ៍? ឬក៏មានការបកប្រែខុសអម្បាញ់មិញហ្នឹង អំពីថាមហាសន្និបាតអង្គការសហប្រជាជាតិឲ្យចងភ្ជាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅនឹងជម្លោះប្រដាប់អាវុធ ឬក៏សង្គ្រាម? ក៏ប៉ុន្តែបើតាមការសិក្សារបស់ខ្ញុំ ដូចជាមិនមែនអ៊ីចឹងទេ អង្គការសហប្រជាជាតិ ក្រុមប្រឹក្សាច្បាប់បានចេញក្រឹត្យលេខ១០ បានទម្លាក់ចោលនូវទំនាក់ទំនងសង្គ្រាម ឬសម្ព័ន្ធភាពសង្គ្រាមទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺមិនចងភ្ជាប់ទេ។

ផ្ទុយទៅវិញ នូរីមប៊ឺក តូក្យូ និង យូហ្គោស្លាវី ទេ ដែលតាមទំនៀមទម្លាប់របស់ ច្បាប់ទំនៀមទម្លាប់នោះ គាត់បានបង្កើតឡើងនៅក្នុងលក្ខន្តិកៈគាត់ ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ វាចងភ្ជាប់ទៅនឹងជម្លោះប្រដាប់អាវុធ ឬក៏សង្គ្រាមស៊ីវិល ឬក៏សង្គ្រាមឈ្លានពានឆ្លងព្រំដែនរដ្ឋ។ បើសិនខ្ញុំមិនច្រឡំទេ។

[១២:៣០:២៨]

ក៏ប៉ុន្តែ ដោយហេតុថានៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ បានចែងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ ទំនងជាមិនពិចារណាទៅលើជម្លោះប្រដាប់អាវុធទេ។ ហេតុនេះសូមលោកស្រីមេត្តាផ្តល់ចម្លើយផង ព្រោះខ្ញុំក៏ព្រៀងនឹងសេចក្តីថ្លែងការណ៍តបទៅនឹងសហព្រះរាជអាជ្ញានៅថ្ងៃសវនាការផងដែរ។ បាទ, អរគុណ។

[១២:៣០:៥៦]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សេចក្តីសន្និដ្ឋានហ្នឹង នឹងធ្វើឡើងនៅថ្ងៃទី២៨ និងថ្ងៃបន្តបន្ទាប់។ នៅពេលនេះ ខ្ញុំគ្រាន់តែជូនដំណឹងអំពីករណីនេះទៅដល់ភាគី ថាតើគួរតែផ្តោតចំណុចណា? ការចាប់អារម្មណ៍របស់ចៅក្រម

របាយការណ៍ គឺវាកើតចេញពីរឿងក្តីនៅចំពោះមុខយើង ដែលនៅក្នុងរឿងក្តីនេះចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយសាលាដំបូងរកឃើញថា ជនជាប់ចោទមានបទល្មើសទាំងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។

ដូច្នេះហើយ អង្គជំនុំជម្រះចង់យល់ និងចង់ឲ្យដឹងស៊ីជម្រៅទៅលើករណីទាំងពីរនេះ។ ថាតើការកាត់ទោសនោះ វាសមស្របដែរឬទេ? ដោយយើងពិចារណាថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ ត្រូវបានប្តឹងសាទុក្ខដោយខាងសហព្រះរាជអាជ្ញា។

[១២:៣១:០០]

យើងនៅពេលនេះ ស្នើសុំបញ្ជាក់បំភ្លឺលើករណីនេះ ហើយមេធាវីការពារក្តី យើងដឹងហើយលើកឡើងអំពីគោលការណ៍នីត្យានុកូលភាពដោយមិនមានការបញ្ជាក់លម្អិត។ ឆ្លងតាមរយៈនេះហើយ ទើបយើងកំណត់ក្នុងដីកាកំណត់កាលបរិច្ឆេទ ហើយនិងយើងសួរបញ្ជាក់បំភ្លឺទៅលើចំណុចនេះ។

យើងដឹងហើយថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺមានការប្តឹងដោយវាពាក់ព័ន្ធទៅនឹងការកាត់ទោសទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ។

[១២:៣២:៣៨]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង នាពេលប្រជុំមួយព្រឹកនេះ គឺអស់លោក លោកស្រីទាំងអស់ដែលបានចូលរួម គឺបានធ្វើការពិភាក្សាគ្នាយ៉ាងផុលផុស ហើយដើម្បីយើងដោះស្រាយនូវបញ្ហាមួយចំនួន ហើយក្នុងន័យមួយគឺដើម្បីឲ្យសវនាការយើងប្រព្រឹត្តទៅដោយរលូន ហើយឆាប់រហ័យ ហើយប្រកបដោយយុត្តិធម៌ផង ហើយនិងអាចដោះស្រាយនូវបញ្ហាមួយចំនួនដែលអាចកើតឡើងនៅក្នុងពេលសវនាការ។

ហើយនាពេលនេះដែរ ខ្ញុំសូមអរគុណចំពោះកិច្ចប្រជុំដែលយើងសម្រេចបាននៅព្រឹកនេះ។ ហើយអ៊ីចឹងសូមបិទកិច្ចប្រជុំនៅពេលនេះតែម្តង ហើយសូមសម្រាក។

សូមអរគុណ៕

*(កិច្ចប្រជុំរៀបចំសវនាការបញ្ចប់នៅម៉ោង១២:៣៣នាទី)*